مدرسة اهل البيت

صلوات الله عليهم

# សាលា អាស្ហ់លុល-បៃត៏

## សៀវភៅសិក្សា ប្រវត្តិសាស្ត្រ (تَارِيْخ)

## ថ្នាក់ទី ៥ (អាយុ ៩-១០ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

**សិក្សាសាសនា**

# បញ្ជីមាតិកា


មេរៀនទី ១ ដែនដីអារ៉ាប៊ីមុនសម័យអ៊ីស្លាម ........................................................ ៤
មេរៀនទី ២ គូស្វយ់ កូនរបស់ គីឡាប់ (قُصَيُّ بْنُ كِلَابٍ) ............................................... ៨
មេរៀនទី ៣ ហ្វាស៊្ញីម កូនរបស់ អាប់ឌូ ម៉ាណាហ្វ់ (هاشم بن عبد مناف) ..................... ១១
មេរៀនទី ៤ អាុប់ឌុល-មុត្តត៉្លិប កូនរបស់ ហ្វាស៊្ញីម - ភាគ ១ ........................... ១៦
មេរៀនទី ៥ អាុប់ឌុល-មុត្តត៉្លិប កូនរបស់ ហ្វាស៊្ញីម - ភាគ ២ ........................... ១៩
មេរៀនទី ៦ អាុប់ឌុល-មុត្តត៉្លិប កូនរបស់ ហ្វាស៊្ញីម - ភាគ ៣........................... ២៣
មេរៀនទី ៧ អាុប់ឌុល-មុត្តត៉្លិប កូនរបស់ ហ្វាស៊្ញីម - ភាគ ៤........................... ២៧
មេរៀនទី ៨ កំណើតព្រះសាស្ដាមូហ៊្ាំម៉ាដ្ឌ់ صلى الله عليه وآله وسلم .................................................. ៣៣
មេរៀនទី ៩ កុមារភាពរបស់ព្រះសាស្ដាមូហ៊្ាំម៉ាដ្ឌ់ صلى الله عليه وآله وسلم ........................................ ៣៧
មេរៀនទី ១០ អាប៊ូ ត៉្លិប និង ព្រះសាស្ដាមូហ៊្ាំម៉ាដ្ឌ់ صلى الله عليه وآله وسلم .................................. ៤១
មេរៀនទី ១១ យុវភាពរបស់ព្រះសាស្ដាមូហ៊្ាំម៉ាដ្ឌ់ صلى الله عليه وآله وسلم ........................................ ៤៥
មេរៀនទី ១២ សៃយីដ្ឋាស៊្ 
ខ៌ទីយ៉ាស៊្ سلام الله عليها - ភាគ ១ ............................................ ៥០
មេរៀនទី ១៣ សៃយីដ្ឋាស៊្ ខ៌ទីយ៉ាស៊្ سلام الله عليها - ភាគ ២ ............................................ ៥៤
មេរៀនទី ១៤ ព្រះសាស្ដា អាដ្ញាំ عليه السلام - ភាគ ១ ....................................................... ៥៩
មេរៀនទី ១៥ ព្រះសាស្ដា អាដ្ញាំ عليه السلام - ភាគ ២ ....................................................... ៦២
មេរៀនទី ១៦ ព្រះសាស្ដា អាដ្ញាំ عليه السلام - ភាគ ៣ ....................................................... ៦៦
មេរៀនទី ១៧ ព្រះសាស្ដា អ៊ីដ្ទរីស عليه السلام .............................................................. ៧២
មេរៀនទី ១៨ ព្រះសាស្ដា នុះហ៊្ عليه السلام .................................................................... ៧៦
មេរៀនទី ១៩ ព្រះសាស្ដា ហ៊្ូដ្ឋ عليه السلام ..................................................................... ៨១
មេរៀនទី ២០ ព្រះសាស្ដា ស្វ៊លិះហ៊្ عليه السلام ............................................................... ៨៦

## មេរៀនទី ១

# ដែនដីអារ៉ាប៊ីមុនសម័យអ៊ីស្លាម

ដែនដីអារ៉ាប៊ីមានទំហំ ៣០០០ ០០០ គីឡូម៉ែត្រក្រឡា ។ កាលពីសម័យបុរាណ ដែនដីនេះត្រូវបែងចែកជា ៣ តំបន់គឺ៖ តំបន់ហ៊ីយ៉ាស្ស់ តំបន់ខ្សាច់អារ៉ាប់ និងតំបន់យេមេន ។




ទីក្រុងធំជាងគេរបស់តំបន់ហ៊ីយ៉ាស្ស់គឺម៉ាក់កាស្ស់ មានប្រវត្តិតាំងពីសម័យព្រះសាស្តាអ៊ីបរ៉ូហ៊ីមﷺបានសាងសង់ព្រះមហាគ្រឹះកាក់ប៉ាស្ស់ ជាមួយព្រះរាជបុត្រព្រះអង្គﷺ ព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺ មកម្ល៉េះ ។ សម័យនោះព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺបានតាំងលំនៅដ្ឋាននៅឯម៉ាក់កាស្ស់ ។ ប្រជាជាតិអារ៉ាប់ច្រើនក្រុម

ជាប់សាច់សាលោហិតនឹងបណ្តាកូនចៅរបស់ព្រះអង្គﷺ ។ ប្រជាជាតិ (ឬកុលសម្ពន្ធ) ដែលល្បីជាងគេគឺប្រជាជាតិ (ឬកុលសម្ពន្ធ) គូរ៉យស្ញ៍ ។

មុនអ៊ីស្លាមកើតឡើង ពួកអារ៉ាប់មានមារយាទអាក្រក់ ។ ឧទាហរណ៍ ៖

១. ពួកគេឆាប់វាយប្រតប់គ្នា ដល់ថ្នាក់ធ្វើសង្គ្រាមដោយមិនសមហេតុផល ។ ត្រកូលខ្លះច្បាំងគ្នាអស់យរៈពេល ៥០ ទៅ ១០០ ឆ្នាំ ដល់ថ្នាក់ភ្លេចមូលហេតុដែលបណ្តាលឲ្យខ្លួនច្បាំងគ្នា ។

២. ពួកគេគ្មានសណ្តាប់ធ្នាប់ គ្មានច្បាប់ ។ ប្រជាជាតិខ្លាំងជាងគេមិនញញើតលួចប្លន់និងសម្លាប់ប្រជាជាតិអន់ខ្សោយជាងគេទេ ។

៣. ពួកគេគោរពបូជារូបព្រះរាប់រយ ពួកគេធ្វើរូបព្រះដូចរូបពួកគេ ។ នៅខាងក្នុងព្រះមហាគ្រឹះកាក់បាស្ញ៍មាន ៣៦៥ រូបព្រះ រូបព្រះមួយសម្រាប់ថ្ងៃមួយ ពេញមួយឆ្នាំ ។

៤. ពួកគេធ្វើបាបស្ត្រី ។

៥. ទម្លាប់អាក្រក់លើសគេមួយរបស់ពួកអារ៉ាប់គឺ ពួកគេកប់កូនស្រីឯងទាំងរស់ ។ ពេលដឹងថាខ្លួនទើបនឹងបានកូនស្រី ពួកគេក្រេវក្រោធ យកទារកនោះទៅកប់ក្នុងដី ។

ក៏ប៉ុន្តែពួកអារ៉ាប់មានគុណសម្បត្តិខ្លះ ។ ឧទាហរណ៍ ៖

១. ពួកគេមិនក្បត់ពាក្យសន្យាជាដាច់ខាត ។ សម្រាប់ពួកគេ ក្បត់ពាក្យសន្យាជាបាបធំមួយ ។

២. ពួកគេជំនាញជិះសេះ ពូកែបាញ់ធ្នូ ។

៣. ពួកគេក្លាហាន មិនរត់គេចខ្លួនពីពួកសត្រូវក្នុងសមរភូមិជាដាច់ខាត ។

៤. ពួកគេពូកែខាងកំណាព្យ ពូកែចងចាំអាចចាំកំណាព្យនិងពាក្យពេជន៍ដ៏វែងបានយ៉ាងស្ទាត់ ។

គុណសម្បត្តិទាំងនេះមាននៅក្នុងត្រកូលរបស់អាដ្ញ៍ណាន់ (عدنان) ជាពិសេសដែលជាសាច់សាលោហិតរបស់ព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺ ។ បណ្តាកូនចៅរបស់អាដ្ញ៍ណាន់មានចិត្តទូលាយ ។ ពួកគាត់ជឿព្រះតែមួយតាមព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺបង្ហាត់បង្រៀន ។ កំណាព្យនិងពាក្យពេជន៍ពួកគាត់ប្រសើរជាងកំណាព្យនិងពាក្យពេជន៍របស់ប្រជាជាតិឯទៀត ។ ព្រះសាស្តាយើងﷺកើតមកពីត្រកូលថ្លៃថ្នូរ

នេះ ។ ព្រះអង្គﷺនៅក្នុងត្រកូល បានី ហាស្ហ៊ីម ដែលជាប៉ែកមួយនៃប្រជាជាតិ (ឬកុលសម្ពន្ធ) គូរ៉យ៉ស្ហ៍ ។

## ជ្រុងលំហាត់

នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្ទ៏ﷻមានព្រះបន្ទូលអំពីអារម្មណ៍របស់ពួកអារ៉ាប់ពេលមានកូនស្រីកើតនៅក្នុងគ្រួសារខ្លួន ។ គឺនៅក្នុងស៊ូរ៉ោះត៍ អាន់-ណាស្ល៍ អាយ៉ាស់ ៥៨ និង ៥៩ ។ ចូរស្វែងរកអាយ៉ាស់ទាំងពីរនេះ ហើយចូរសរសេរសម្រាយវានៅខាងក្រោមនេះ ។

.......................................................................................................................

.......................................................................................................................

.......................................................................................................................

..............................................................................................

### *ពេលនេះអ្នកដឹង...*

- ហ៊ីយ៉ាស់ជាតំបន់មួយនៃអារ៉ាប៊ី រាជធានីរបស់តំបន់ហ៊ីយ៉ាស់គឺម៉ាក់កាស់ ។
- ពួកគូរ៉យ៉ស៍ជាប្រជាជាតិ (ឬកុលសម្ពន្ធ) អារ៉ាប់ធំជាងគេនៅម៉ាក់កាស់ ។ ពួកគេជាសាច់សាលោហិតរបស់ព្រះសាស្តាអ៊ីសម៉ាអ៊ីលعليه السلام ។
- មុនសម័យអ៊ីស្លាម ពួកអារ៉ាប់មានមារយាទអាក្រក់ ។ ពួកគេឆាប់វាយប្រគប់គ្នា មិនមានសណ្តាប់ធ្នាប់ មិនមានច្បាប់ទម្លាប់ទេ ។ ពួកគេគោរពបូជារូបព្រះ ធ្វើបាបស្ត្រី កប់កូនស្រីខ្លួនឯងទាំងរស់ ។
- ពួកអារ៉ាប់មានគុណសម្បត្តិខ្លះគឺៈ ពួកគេមិនក្បត់ពាក្យសន្យាជាដាច់ខាត ពួកគេក្លាហាន ជំនាញជិះសេះ ពូកែបាញ់ធ្នូនិងពូកែខាងកំណាព្យកាព្យឃ្លោង ។
- វង្សត្រកូលរបស់អាដ្ណាន់មានគុណសម្បត្តិប្រសើរដាច់គេ ។ ពួកគាត់មានចិត្តទូលាយ ពូកែខាងកាព្យឃ្លោងជាងគេ ពួកគាត់ជឿព្រះតែមួយគត់ ។
- ព្រះសាស្តាﷺកើតមកពីវង្សត្រកូល បានី ហ្ស៊ីម ដែលជាប៉ែកមួយនៃប្រជាជាតិគូរ៉យ៉ស៍ ។

## មេរៀនទី ២

# គូស្វយ់ កូនរបស់ គីឡាប់

قُصَيُّ بْنُ كِلَابٍ

គូស្វយ់ជាបុព្វការីទី ៤ របស់ព្រះសាស្តាមូហាំម៉ាដ់ ﷺ យើង ។ គូស្វយ់និងបង ឈ្មោះស៊ុះរ៉ោះត៍ (زهرة) នៅក្មេងណាស់កាលគីឡាប់ ឪពុក បានស្លាប់ ។ ម្តាយ លោកទាំងពីរ ឈ្មោះហ្វាទីម៉ាស់ បានរៀបការជាមួយបុរសម្នាក់ទៀតឈ្មោះ រ៉ប៊ីអុាស់ (رابعة) ។ រ៉ប៊ីអុាស់បាននាំគ្រួសារថ្មីរបស់ខ្លួនទៅឯប្រទេសស៊ីរី ។ រ៉ប៊ីអុាស់ មើលថែរក្សាគូស្វយ់ដូចកូនបង្កើត ។ លុះពេញវ័យគូស្វយ់បានឈ្លោះជាមួយ កុលសម្ពន្ធរបស់រ៉ប៊ីអុាស់ ។ ហេតុដូច្នេះលោកបានត្រឡប់ទៅឯម៉ាក់កាស់ ស្រុក កំណើតរបស់លោកវិញ ។ ព្រោះតែលោកជាមេដឹកនាំល្អបានជាលោកក្លាយទៅជា អ្នកមានអំណាចម្នាក់ក្នុងចំណោមអ្នកស្រុកម៉ាក់កាស់ ជាពិសេសក្នុងកុលសម្ពន្ធ គូរ៉យ់ស្ញ ។ គូស្វយ់មានចិត្តទូលាយនិងក្លាហាន លោកមានប្រជាប្រិយភាព ដោយសារលោកមានសីលធម៌ប្រសើរ និងមានទំនាក់ទំនងល្អជាមួយអ្នកផង ។ លោកក៏បានក្លាយទៅជាមេដឹកនាំពួកគូរ៉យ់ស្ញ ។ ស្នាដៃដ៏ល្បីមួយរបស់លោកគឺការ បង្កើត ដ៉ារ អាន់-ណាដ្វាស់ (دار الندوة) គឺគ្រឹះស្ថានមួយនៅក្បែរព្រះមហាគ្រឹះ កាក់បាស់ ។ មេដឹកនាំកុលសម្ពន្ធទាំងអស់ជួបជុំគ្នានៅក្នុងគ្រឹះស្ថាននេះដើម្បី ប្រឹក្សាគ្នាដោះស្រាយបញ្ហាផ្សេងៗ ។ គូស្វយ់ទទួលមុខងារទាំងអស់ដែលជាភារកិច្ច របស់កុលសម្ពន្ធគូរ៉យ់ស្ញ ពោលគឺ៖

១. ហ៊ីយ៉ាបាស់ (حِجَابَة) អ្នកទទួលខុសត្រូវកូនសោព្រះមហាគ្រឹះកាក់បាស់ ។

២. ណាដ្វាស់ (النَدوَة) អ្នកដឹកនាំ ដ៉ារ អាន់-ណាដ្វាស់ (دار النَدوَة) ។

៣. រីហ្វាដាស់ (رِفَادَة) អ្នកផ្តល់អាហារដល់បណ្តាអ្នកមកធ្វើពិធីហាជ្ជ ។

៤. សាក៏យ៉ាស់ (سقاية) អ្នកឲ្យទឹកបណ្តាអ្នកមកធ្វើពិធីហាជ្ជផឹក ។

៥. លីវ៉ាអ៊ុ (لِوَاء) អ្នកជ្រើសរើសខ្មាន់ទង់របស់ប្រជាជាតិគូរ៉យ់ស្ញពេលមាន សង្គ្រាម ។

៦. គីយ៉ាដាស់ (قِيادة) អ្នកដឹកនាំទ័ពក្នុងសង្គ្រាម ។

គូស្វយ់បានទទួលមរណៈកម្មក្នុងឆ្នាំ ៥៨០ នៃគ្រិស្តសករាជ ។ លោកមានកូនប្រុសពីរនាក់ឈ្មោះ អាប់ឌូ អាល់-ដ្វារ (عَبْدُ الدَّار) និង អាប់ឌូ ម៉ាណាហ្វ៉ា (عبد مناف) ។

នៅក្នុងមរតកសាស្ត្រ គូស្វយ់បានតែងតាំងកូនប្រុសបងគេរបស់លោកឈ្មោះ អាប់ឌូ អាល់-ដ្វារ ជាមេដឹកនាំថ្មីរបស់ពួកគូរ៉យ់ស្ស៍ អំណឹះតទៅអាប់ឌូ អាល់-ដ្វារជាអ្នកទទួលខុសត្រូវមុខងារទាំង ៦ ដែលជាភារកិច្ចរបស់ពួកគូរ៉យ់ស្ស៍ ។ កូនប្រុសប្អូនគេឈ្មោះ អាប់ឌូ ម៉ាណាហ្វ៉ា ជាអ្នកមានឧត្តមគតិ មិនដែលប៉ុនប៉ងប្លន់យកតំណែងរបស់បងប្រុសខ្លួនឡើយ ។

ក្រោយពីបងប្អូនពីរនាក់នេះបានស្លាប់ កូនៗរបស់លោកទាំងពីរឈ្លោះប្រកែកគ្នារឿងបែងចែកភារកិច្ចទាំង ៦ នេះ ។ ទីបំផុត គេបានសម្រេចថាភារកិច្ចទាំងនេះត្រូវបែងចែករវាងកូនៗរបស់អាប់ឌូ ម៉ាណាហ្វ៉ានិងកូនៗរបស់អាប់ឌូ អាល់-ដ្វារ ។

**ជ្រុងលំហាត់**

១. តាមការយល់ឃើញរបស់អ្នក តើភារកិច្ចមួយណារបស់ពួកគូរ៉យ់ស្ស៍ដែលធ្ងន់ជាងគេ ? ហេតុអ្វី

២. បើគេសូមឲ្យអ្នកទទួលយកភារកិច្ចមួយ តើអ្នកទទួលយកភារកិច្ចមួយណា ? ហេតុអ្វី ?

***ពេលនេះអ្នកដឹង...***

- គូស្វយ់ជាបុព្វការីទី ៤ របស់ព្រះសាស្តាយើង ﷺ ។
- លោកបានរស់នៅឯប្រទេសស៊ីរីកាលពីក្មេង តែក្រោយមកលោកបានវិលត្រឡប់ទៅម៉ាក់កាស្ស៍វិញដែលជាស្រុកកំណើតលោក ។
- គូស្វយ់មានចិត្តទូលាយនិងក្លាហាន លោកបានទៅជាមេដឹកនាំពួកគូរ៉យ់ស្ស៍ ។

- ស្នាដៃដ៏ឆ្នើមរបស់លោកគឺគ្រឹះស្ថាន ដ្ញារ អាន់-ណាដ្វ៉ាស្ញ់ (دار الندوة) ពួកមេដឹកនាំក្រុមប្រជាជាតិនានាប្រជុំគ្នានៅទីនេះដើម្បីដោះស្រាយបញ្ហាផ្សេងៗ ។
- លោកទទួលខុសត្រូវភារកិច្ចទាំង ៦ របស់ពួកគូរ៉យស្ញ៍គឺ៖ ហ៊្ញីយ៉ាបាស្ញ់ (حِجَابَة), ណាដ្វ៉ាស្ញ់ (النَدوَة), រីហ្វាដ្ញាស្ញ់ (رِفَادَة), សាក្វ៊ីយ៉ាស្ញ់ (سقاية), លីវ៉ាអ៊្ញ (لِوَاء), គ្វីយ៉ាដ្ញាស្ញ់ (قيادة) ។
- លោកមានកូនប្រុសពីរនាក់គឺ៖ អ៊្ញុប់ឌូ អាល់-ដ្ញារ (عَبْد الدَّار) និង អ៊្ញុប់ឌូ ម៉ាណាហ្វ់ (عبد مناف)

**មេរៀនទី ៣**

# ហ្ហាស៊ីម កូនរបស់ អ៊ាប់ឌូ ម៉ាណាហ្វ៍
## هَاشِم بْن عَبْد مَنَاف

ហ្ហាស៊ីមជាជីតាទួតរបស់ព្រះសាស្ដាមូហាំម៉ាដ់យើងﷺ ។ ហ្ហាស៊ីមមានប្អូនប្រុសភ្លោះម្នាក់ឈ្មោះ អ៊ាប់ឌូ ស្ហាំស៍ (عَبْد شَمْس بْنِ عَبْد مَنَاف) និងប្អូនប្រុសពីរនាក់ទៀតឈ្មោះ មុត្តាត្ទលិប (مُطَّلِب ٱبْن عَبْد مَنَاف) និង ណៅហ្វាល់ (نَوْفَل بْنِ عَبْدِ مَنَاف) ។

ហ្ហាស៊ីមជាមេដឹកនាំប្រកបដោយប្រាជ្ញាញាណ ។ ប្រការសំខាន់មួយដែលលោកបានធ្វើគឺ លោកបានធ្វើកិច្ចព្រមព្រៀងវិស័យពាណិជ្ជកម្មរវាងពួកគូរ៉យស្ហ៍និងពួកមេដឹកនាំប្រទេសស៊ីរី ។ ប្អូនប្រុសលោកក៏បានធ្វើកិច្ចព្រមព្រៀងស្រដៀងនេះដែរជាមួយពួកមេដឹកនាំប្រទេសអេត្យូពី តំបន់យេមេននិងប្រទេសអ៊ីរ៉ង់ ។

ហេតុដូច្នេះ ទំនិញអាចទៅមកបានដោយសេរីរវាងស្រុកទាំងនេះ ពួកគូរ៉យស្ហ៍ក៏បានក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិនិងមានអំណាច ។ នគរម៉ាក់កាស់បានក្លាយទៅជាមជ្ឈដ្ឋានពាណិជ្ជកម្ម ។

ក្នុងរដូវក្តៅ ក្រុមក្បួនទូរចរឈ្មួញទៅប្រទេសស៊ីរី ក្នុងរដូវរងាពួកគេទៅយេមេន ។ តែផ្លូវដែលក្រុមក្បួនទូរចរឈ្មួញទៅមកនោះមិនរួចផុតពីពួកចោរទេ ។ ហ្ហាស៊ីមបានធ្វើកិច្ចសន្យាជាមួយពួកចោរថា បើពួកគេមិនប្លន់ក្រុមក្បួនទូរចររបស់លោកទេ លោកសន្យាថានឹងលក់ទំនិញឲ្យពួកគេនោះថោកៗ ។ ពួកចោរយល់ព្រមព្រោះបានសេចក្ដីថាអំណឹះតទៅពួកចោរនោះលែងជាជនក្រៅច្បាប់ អាចចូលទៅក្នុងនគរម៉ាក់កាស់បានដោយមិនត្រូវគេវាយ ។ អល់ឡោះហ៊្ចﷻថែងអំពីរឿងនេះនៅក្នុងព្រះគម្ពីរគួរអានថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

لِإِيلَٰفِ قُرَيۡشٍ ١ إِۦلَٰفِهِمۡ رِحۡلَةَ ٱلشِّتَآءِ وَٱلصَّيۡفِ ٢ فَلۡيَعۡبُدُواْ رَبَّ هَٰذَا ٱلۡبَيۡتِ ٣ ٱلَّذِيٓ أَطۡعَمَهُم مِّن جُوعٖ وَءَامَنَهُم مِّنۡ خَوۡفِۭ ٤

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*១. ដើម្បីការពារពួកគូរ៉ៃស្ស៍ ២. ការពារពួកគេក្នុងពេលធ្វើដំណើរតាមក្បួនទូរចរជំនួញក្នុងរដូវរងានិងរដូវក្តៅ ៣. ចូរឲ្យពួកគេគោរពបូជាព្រះម្ចាស់ព្រះមហាគ្រឹះស្ថាននេះ ៤. ដែលផ្តល់អាហារដល់ពួកគេពេលពួកគេឃ្លាន ដែលផ្តល់សន្តិសុខដល់ពួកគេពេលពួកគេខ្លាច ។*(ស៊ូរ៉ោះត៍ គូរ៉ៃស្ស៍, ១០៦:១-៤)

សម័យនោះ ពួកអារ៉ាប់មានទម្លាប់មួយដែលគេហៅថា អ៊ិះហ៍ទីហ្វាដ់ ។ ពេលសមាជិកគ្រួសារណាមិនមានសមត្ថភាពរកទទួលទានបានទេ សមាជិកនោះចាកចេញពីម៉ាក់កាស្ទុំទៅនៅឯវាលខ្សាច់ក្នុងខ្ទមមួយ ទាល់តែអត់បាយអត់ទឹកស្លាប់ ។ ពួកគេយល់ឃើញថាធ្វើបែបនេះប្រសើរជាងសុំទានគេ ។

ហ្វាស្ហ៊ីមបានប្រាប់ឲ្យប្រជារាស្ត្របោះបង់ចោលទម្លាប់នេះ ។ លោកបានរៀបចំឡើងនូវផែនការណ៍មួយ ដែលតម្រូវឲ្យគ្រួសារក្រីក្រមួយចូលរួមជាមួយគ្រួសារមានមួយ ។ គ្រួសារទាំងពីរនេះជួយគ្នាទៅវិញទៅមកក្នុងការជួញដូរ ។ ដូច្នេះស្ថានភាពគ្រួសារទាំងពីរប្រសើរឡើង ។

អ៊ូម៉ៃយ៉ាស្ទុំ កូនប្រុសរបស់ អាប់ឌុ ស្ហាំស៍ ច្រណែនឪពុកធំឯងដែលគេគោរពលោក ។ គាត់ខិតខំធ្វើឲ្យមនុស្សស្រឡាញ់គាត់ដោយឲ្យអំណោយគេ ។ តែគេនៅតែស្រឡាញ់ហ្វាស្ហ៊ីមព្រោះលោកមានសប្បុរសធម៌និងធ្វើល្អ ។ ទីបំផុតអ៊ូម៉ៃយ៉ាស្ទុំបានប្រាប់ឪពុកធំខ្លួនថា គាត់នឹងឈរឈ្មោះធ្វើមេដឹកនាំពួកគូរ៉ៃប្រឈមនឹងលោក ។ គាត់សុំឲ្យអ្នកមានប្រាជ្ញាញាណជ្រើសរើសយកម្នាក់ជាមេដឹកនាំ ។ ហ្វាស្ហ៊ីមយល់ព្រមដោយដាក់លក្ខខណ្ឌពីរគឺៈ អ្នកចាញ់ត្រូវលះបង់អូដ្ឋ ១០០ ក្បាលសម្រាប់ចិញ្ចឹមអ្នកមកធ្វើពិធីហាជ្ជ់ ហើយអ្នកចាញ់នោះត្រូវចាកចេញពីម៉ាក់កាស្ទុំ ១០ ឆ្នាំ ។ អ៊ូម៉ៃយ៉ាស្ទុំព្រមទទួលលក្ខខណ្ឌទាំងពីរនេះ ។

ពេលបុរសអ្នកមានប្រាជ្ញាញាណឃើញនិងឮបុរសទាំងពីរ លោកក៏បានឲ្យដឹងភ្លាមថាហ្វាស្ហ៊ីមសមជាអ្នកដឹកនាំជាងគេ អ៊ូម៉ៃយ៉ាស្ទុំក៏ចាំបាច់ត្រូវតែចាកចេញពីម៉ាក់កាស្ទុំ ។ គាត់បានរស់នៅឯប្រទេសស៊ីរី ១០ ឆ្នាំ ។ ចាប់តាំងពីពេលនោះមកពួកបានី អ៊ូម៉ៃយ៉ាស្ទុំក្លាយទៅជាសត្រូវរបស់ពួកបានី ហ្វាស្ហ៊ីម ។

## ជ្រុងស្រាវជ្រាវ

ចូរធ្វើការស្រាវជ្រាវអំពី បានី អ៊ូម៉ៃយ៉ាស្ហ៍ ។ ពួកគេមានចរិតមារយាទដូចម្តេច ? ពួកគេប្រព្រឹត្តអ្វីខ្លះចំពោះព្រះសាស្តាﷺនិងបណ្តាសមាជិកឯទៀតនៃ អាស្ហ៍លុល-បៃត៍عليهم السلام ?

ហ្ញាស្ហ៊ីមទទួលមរណៈភាពនៅប្រទេសស៊ីរី ។ លោកមានកូនប្រុស ៥ នាក់គឺៈ អ៊្ទាប់ឌុល-មុត្តត៍លិប, អាសាដ្ទ៍, ណាដ្ហា (ឬ ណាដ្ហ៍ឡាស្ហ៍), ស្វយ់ហ្វី, អាប៊ូ ស្វយ់ហ្វី ។ កូនប្រុសទាំងបីក្រោយនេះ (ណាដ្ហា (ឬ ណាដ្ហ៍ឡាស្ហ៍), ស្វយ់ហ្វី, អាប៊ូ ស្វយ់ហ្វី) ពុំមានកូនទេ ឯអាសាដ្ទ៍មានតែកូនស្រីមួយឈ្មោះ ហ្វាទ្ទីម៉ាស្ហ៍ (មាតារបស់អីមុាំអ៊្ទលី صلوات الله عليه والسلام) ។

## ជ្រុងលំហាត់

ចូរបំពេញបង្គ្រប់បញ្ជីរាយនាមពង្សាវលីខាងក្រោមនេះ ។



***ពេលនេះអ្នកដឹង...***

- ហ្វាស្ទឹមជាជីតាទួតរបស់ព្រះសាស្តាﷺ ។
- លោកមានប្អូនប្រុសភ្លោះម្នាក់ឈ្មោះ អាប់ឌុ ស្ហាំស៍ ។
- ហ្វាស្ទឹមជាមេដឹកនាំប្រកបដោយប្រាជ្ញាញាណ ។ លោកបានធ្វើឲ្យពួកគូរ៉យស្ហ៍ក្លាយទៅជាអ្នកមាន ដោយបានធ្វើកិច្ចព្រមព្រៀងវិស័យពាណិជ្ជកម្មជាមួយអភិបាលស្រុកស៊ីរី ។ លោកបានធ្វើកិច្ចព្រមព្រៀងជាមួយពួកចោរតាមផ្លូវធំៗដែរ គឺ៖ បើពួកចោរនោះឈប់ប្លន់បណ្តាក្បួនទូរចរឈ្មួញ លោកនឹងលក់ទំនិញឲ្យពួកចោរនោះថោកៗ ។
- លោកបានលុបបំបាត់ទំនៀមទម្លាប់អ៊ិះហ៍ទីហ្វាដ់ ដោយបង្រួបបង្រួមគ្រួសារមានទ្រព្យជាមួយគ្រួសារក្រីក្រ ។
- ក្មួយរបស់ហ្វាស្ទឹមឈ្មោះអ៊ូម៉ៃយ៉ាស្ហ៍ (កូនប្រុសរបស់អាប់ឌុ ស្ហាំស៍) ច្រណែនឪពុកមាឯងដែលមនុស្សគោរពលោក ។ គាត់បានបបួលឪពុកមាគាត់ប្រកួតដើម្បីយកមុខតំណែងមេដឹកនាំពួកគូរ៉យស្ហ៍ ។
- អ៊ូម៉ៃយ៉ាស្ហ៍ចាញ់ការប្រកួត បានសំឡេះអូដ្ឋ ១០០ ក្បាលដើម្បីចិញ្ចឹមបណ្តាអ្នកមកធ្វើពិធីហាជ្ជ៍ ហើយត្រូវចាកចេញពីម៉ាក់កាស្ហ៍ ១០ ឆ្នាំ ។ ចាប់ពីពេលនោះមក ពួកបានី អ៊ូម៉ៃយ៉ាស្ហ៍បានក្លាយទៅជាសត្រូវរបស់ពួកបានី ហ្វាស្ទឹម ។

# លំហាត់មេរៀនសាឡើងវិញ ១

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺ៖

១. ចូរប្រាប់ឈ្មោះតំបន់ទាំង ៣ នៃអារ៉ាប៊ី ?

២. តើពួកអារ៉ាប់ជាសាច់សាលោហិតរបស់ព្រះសាស្តាអង្គណា ?

៣. ចូររៀបរាប់អំពីមារយាទអាក្រក់ ៣ របស់ពួកអារ៉ាប់ (មុនសម័យអ៊ីស្លាម) ។

៤. តើបណ្តាកូនចៅរបស់អាដ៉ំណាន់ជឿអ្វី (សាសនា) ?

៥. តើព្រះសាស្តាយើងﷺនៅក្នុងប្រជាជាតិ (ឬកុលសម្ពន្ធ) អ្វី មានត្រកូលអ្វី ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺ៖

១. តើគូស្វយ់និងព្រះសាស្តាយើងﷺមានទំនាក់ទំនងអ្វីនិងគ្នា ?

២. តើគូស្វយ់បានក្លាយទៅជាអ្នកមានអំណាចក្នុងចំណោមពួកគូរ៉យ់ស្ហ៍ដូចម្តេច ?

៣. ចូរប្រាប់មុខងារពីរដែលជាភារកិច្ចរបស់ពួកគូរ៉យ់ស្ហ៍ តើមុខងារនេះតម្រូវឲ្យធ្វើអ្វី ?

៤. តើកូនប្រុសរបស់គូស្វយ់ឈ្មោះអ្វី ?

## ខណ្ឌ គ

ចូរឆ្លើយសំណួរតទៅគឺ៖

១. តើហ្វាស្ហ៊ីមបានធ្វើឲ្យពួកគូរ៉យ់ស្ហ៍ទៅជាអ្នកមានទ្រព្យសម្បត្តិ និងជាអ្នកមានអំណាចដូចម្តេច ?

២. តើពួកគូរ៉យ់ស្ហ៍ធ្វើការជួញដូរនៅឯណាក្នុងរដូវក្តៅនិងក្នុងរដូវរងា ?

៣. ហេតុអ្វីអ៊ូម៉ៃយ៉ាស់ច្រណែនហ្វាស្ហ៊ីម ?

៤. ហេតុអ្វីគេធ្វើ "អ៊ិះហ៍ទីហ្វាដ់" ?

៥. តើព្រះសាស្តាយើងﷺនិងហ្វាស្ហ៊ីមមានទំនាក់ទំនងអ្វីនឹងគ្នា ?

**មេរៀនទី ៤**

# អាប់ឌុល-មុត្តត៏លិប កូនរបស់ ហាស៊ីម - ភាគ ១

អាប់ឌុល-មុត្តត៏លិប (عَبْد الْمُطَّلِب ابْن هَاشِم) ជាជីតារបស់ព្រះសាស្តាយើងﷺ ។ ហាស៊ីមជាបិតាលោក ។

អាប់ឌុល-មុត្តត៏លិបកើតនៅម៉ាឌីណាស់ ។ មាតាលោកហៅឈ្មោះលោកថា ស្ហៃបាស់ (شَيْبَة) ។ លោកនៅក្មេងនៅឡើយកាលហាស៊ីម បិតាលោក ទទួលអនិច្ចកម្ម ។ កាលហាស៊ីមជិតស្លាប់ លោកបានប្រាប់ប្អូនលោកឈ្មោះមុត្តត៏លិបថា៖ "ចូរទៅម៉ាឌីណាស់ នាំស្ហៃបាស់កូនខ្ញុំទៅម៉ាក់កាស់" ។

មុត្តត៏លិបក៏បានទៅម៉ាឌីណាស់ ហើយនាំស្ហៃបាស់ក្មួយលោកទៅម៉ាក់កាស់ជាមួយលោកផង ។ ពេលគេឃើញកុមារស្ហៃបាស់ដើរជាមួយឪពុកមា គេគិតថា ស្ហៃបាស់ជាអ្នកបម្រើរបស់មុត្តត៏លិប ហើយហៅស្ហៃបាស់ថា អាប់ឌុល-មុត្តត៏លិប មានន័យបម្រើរបស់មុត្តត៏លិប ។ ទោះបីមុត្តត៏លិបព្យាយាមពន្យល់ប្រាប់គេថាក្មេងប្រុសនេះមិនមែនបម្រើលោកទេក៏ដោយ តែគេនៅតែហៅឈ្មោះក្រៅនេះ ចាប់ពីពេលនោះមកស្ហៃបាស់មានឈ្មោះថា អាប់ឌុល-មុត្តត៏លិប រហូតមក ។

មុត្តត៏លិបនៅតែទទួលភារកិច្ចរបស់ហាស៊ីមបងប្រុសលោក លុះត្រាតែអាប់ឌុល-មុត្តត៏លិបពេញវ័យអាចទទួលខុសត្រូវជួសលោកបាន ។

អាប់ឌុល-មុត្តត៏លិបទទួលភារកិច្ចពីរ ក្នុងចំណោមភារកិច្ចរបស់ពួកគូរ៉យស៊្ហ៍ គឺភារកិច្ចសាក៏យ៉ាស់និងរីហ្វាដាស់ កាលឪពុកមាលោកទទួលអនិច្ចកម្ម ។ លោកមានគុណសម្បត្តិច្រើន លោកបានកែប្រែច្រើនប្រការក្នុងជីវិតនិងក្នុងរបៀបរស់នៅរបស់ពួកគូរ៉យស៊្ហ៍ ដូចជា៖

១. លោកជាបុគ្គលដំបូងបង្អស់ដែលអនុវត្តិសម្បថ ណាស្ហារ៍ (النَّذْر) ហើយបានសម្រេច ។ គេហៅថា ណាស្ហារ៍ (النَّذْر) គឺពេលអ្នកណាសន្យាជាមួយអល់ឡោះហ៊្ជ ថានឹងធ្វើទង្វើល្អនីមួយ បើសេចក្តីប្រាថ្នារបស់ខ្លួនបានសម្រេចដូចបំណង ។

២. លោកលុបបំបាត់ទំនៀមទម្លាប់អាពាហ៍ពិពាហ៍រវាងមនុស្ស ដែលមាន

សាច់សាលោហិតជិតគ្នាពេក គឺរវាងបងប្អូនប្រុសនិងបងប្អូនស្រីបង្កើត រវាងម្តាយនិងកូន ។ល ។

៣. លោកបានបង្កើតច្បាប់ដែលតម្រូវឲ្យកាត់ដៃចោរ ។

៤. លោកបានហាមមនុស្សមិនឲ្យផឹកស្រាទេ ។

៥. លោកបានរារាំងទង្វើគួរឲ្យរន្ធត់កប់កូនស្រីទាំងរស់ ។

៦. លោកបានដាក់ពិន័យឲ្យសងអូដ្ឋ ១០ ក្បាលសម្រាប់ឃាតកម្មមនុស្សដោយភាន់ច្រឡំ ។

៧. លោកជាបុគ្គលដំបូងបង្អស់ដែលបង់ ១/៥ (ឃុមស៍) នៃទ្រព្យខ្លួនលើមាគ៌ាអល់ឡោះហ៍ عز وجل ។

អាប់ឌុល-មុត្តត៍លិបមានអាយុ ៨២ ឆ្នាំ ព្រោះតែលោកជាមេដឹកនាំដ៏ល្អបានជាលោកមានឋានៈជា សៃយីឌុល-បាត់ហ៊ាអ៍ (سَيِّدُ الْبَطْحَاءِ) មានន័យថៅហ្វាយម៉ាក់កាស្ទ ។

## ផ្ទុងលំហាត់

ចូរសូត្រព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អ៊ីនសាន ឬ អាដ់ដាស់រ៍ អាយ៉ាស់ ៧ ដល់អាយ៉ាស់ ១១ (៧៦:៧-១១) រួចហើយចូរសរសេរពីរបីបន្ទាត់អំពី ណាស្ហារ៍ (សម្បថ) ដែលអ៊ីម៉ាំអាលី صلوات الله عليه والسلام និងគ្រួសារព្រះអង្គ صلوات الله عليه والسلام បានធ្វើ ។

.............................................................................................................

.............................................................................................................

.............................................................................................................

.............................................................................................................

..............................

*ពេលនេះអ្នកដឹង...*

- អាប់ឌុល-មុត្តាត់លិបជាជីតារបស់ព្រះសាស្ដាយើងﷺ ។
- ឪពុកលោកឈ្មោះហាស៊ីម ។
- ឈ្មោះរបស់លោកគឺ ស្ហៃបាស់ តែព្រោះតែគេគិតថាលោកបម្រើរបស់មុត្តាត់លិប បានជាគេហៅលោកថា អាប់ឌុល-មុត្តាត់លិប ។
- លោកជាបុគ្គលដំបូងបង្អស់ដែលអនុវត្តិសម្បថ អាល់-ណាស្ហារ៍ និងជាបុគ្គលដំបូងបង្អស់ដែលបង់ឃុមស៍ ។
- មួយជីវិត លោកបានកែប្រែច្រើនប្រការក្នុងជីវិតនិងក្នុងរបៀបរស់នៅរបស់ពួកគូរ៉យស៍គឺ៖ លោកបានលុបការរៀបការរវាងញាតិសាច់ជិត បានធ្វើទោសចោរបានហាមមនុស្សមិនឲ្យផឹកស្រាទេ បានរាំងមិនឲ្យគេកប់កូនស្រីឯងទាំងរស់បានពិន័យលើឃាតកម្មដែលគេបានប្រព្រឹត្តដោយអចេតនា ។
- ព្រោះតែអាប់ឌុល-មុត្តាត់លិបជាមេដឹកនាំល្អ បានជាគេហៅលោកថា ស្ហៃយីឌុល-បាត់ហ្ហាអ៍ មានន័យថាចៅហ្វាយម៉ាក់កាស់ ។

## មេរៀនទី ៥

# អ៊ុប់ឌុល-មុត្តលិប កូនរបស់ ហាស៊ីម - ភាគ ២

## អណ្តូងទឹកស៊ាំស៊ាំ

អណ្តូងទឹកស៊ាំស៊ាំ មានតាំងពីសម័យព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺមកម្ល៉េះ ។ អណ្តូងទឹកនេះជាភ័ស្តុតាងនៃព្រះគុណអល់ឡោះហ្ទ៍ មកលើព្រះមហេសីរបស់ព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺនិងព្រះរាជបុត្រព្រះនាង ព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺ ។ សព្វថ្ងៃនេះក៏នៅតែមាន ។

អត់ពីព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺទៅ ប្រជាជាតិយ៉ូរហ៊ាំ (ﺟﺮﻫﻢ) បានតាំងលំនៅជុំវិញអណ្តូងទឹកស៊ាំស៊ាំនេះ បានប្រើទឹកនេះតាមតម្រូវការ ។ លុះពួកគេក្លាយទៅជាអ្នកមាននិងមានអំណាច ពួកគេលែងយកចិត្តទុកដាក់នឹងអណ្តូងទឹកនេះ ប្រើទឹកអណ្តូងឥតសំចៃទាល់តែរីង ។

ពេលអ៊ុប់ឌុល-មុត្តលិបចាប់កំណើត គេត្រឹមតែដឹងថាអណ្តូងនេះមានតាំងពីយូរមកហើយ តែពុំមានអ្នកណាដឹងថាវានៅកន្លែងណាទេ ។ ថ្ងៃមួយអ៊ុប់ឌុល-មុត្តលិបយល់សប្តិឃើញគេមកប្រាប់ឲ្យទៅស្តារអណ្តូងទឹកស៊ាំស៊ាំ ហើយបានប្រាប់កន្លែងអណ្តូងនោះ ។ លោកក៏បានទៅជីកជីវាវរកវាជាមួយកូនប្រុសលោកឈ្មោះហារីស្ វ អស់រយៈពេល ៤ ថ្ងៃទើបរកឃើញមាត់អណ្តូង ។ ពួកគូរ៉យ៉ស្ អះអាងថាអណ្តូងជាកម្មសិទ្ធិរបស់ប្រជាជាតិគូរ៉យ៉ស្ទាំងអស់គ្នា ដើម្បីនឹងឲ្យទាំងអស់គ្នាមានកិត្តិយសជីកអណ្តូងនេះ ។ អ៊ុប់ឌុល-មុត្តលិបចង់ជីកអណ្តូងតែម្នាក់ឯងដើម្បីនឹងអាចយកទឹកមកចែកឲ្យទាំងសអស់គ្នា ជាពិសេសចែកឲ្យបណ្តាអ្នកដែលមកធ្វើពិធីហាជ្ជ់ ដោយមានរបៀបរៀបរយ ។ ទាំងអស់គ្នាមិនអាចសម្រេចចិត្តបានទេថាអ្នកណាជាអ្នកជីកអណ្តូង ។ ដូច្នេះពួកគេសម្រេចចិត្តទៅពឹងបុរសអ្នកមានប្រាជ្ញាញាណនៅប្រទេសស៊ីរី ហើយនឹងធ្វើតាមបុរសនោះថា ។ ត្រកូលនីមួយៗបានចាត់ឲ្យមានតំណាងម្នាក់ ។ អ៊ុប់ឌុល-មុត្តលិបជាមួយកូនប្រុសលោកនិងបក្សពួកលោកនៅក្នុងក្បួនទូរចរមួយ អ្នកឯទៀតនៅក្នុងក្បួនទូរចរមួយ

ផ្សេង ។

តាមផ្លូវដ៏សែនឆ្ងាយ ក្បួនទូរចរបស់អ្នាប់ឌុល-មុត្តត៍លិបអស់ទឹកផឹក អ្នាប់ឌុល-មុត្តត៍លិបក៏បានសូមទឹកពីអ្នកឯទៀត តែពួកគេមិនព្រមចែកឲ្យទេ ។ ស្ថានភាពដុនដាបខ្លាំង អ្នាប់ឌុល-មុត្តត៍លិបគិតថាពួកគាត់នឹងស្លាប់ជាមិនខាន លោកបានឲ្យម្នាក់ៗជីកផ្នូរខ្លួនឯង ធ្វើដូច្នេះ ពេលអ្នកណាស្លាប់អ្នកឯទៀតនឹងកប់សពអ្នកនោះ មានតែសពរបស់បុគ្គលក្រោយគេទេដែលពុំមានគេកប់ ។ ទាំងអស់គ្នាក៏បានជីកផ្នូរខ្លួនឯង ។

ក្រោយមកបន្តិច អ្នាប់ឌុល-មុត្តត៍លិបបានសម្រេចចិត្តថាគប្បីបន្តការស្វែងរកទឹក វាប្រសើរជាងស្លាប់ក្នុងសភាពនេះ ។ អាស្រ័យព្រះគុណអល់ឡោះហ្ ﷻ មិនយូរប៉ុន្មានក៏រកទឹកផឹកបាន ។ ទាំងអស់គ្នាក៏បានផឹកទឹកលុះបាត់ស្រេក ហើយបានដងទឹកទុកក្នុងថង់ដាក់ទឹកផង ។ ក្រុមមួយទៀតបានសូមទឹកពីពួកគាត់វិញ ។ បក្សពួករបស់អ្នាប់ឌុល-មុត្តត៍លិបចង់បដិសេធ តែអ្នាប់ឌុល-មុត្តត៍លិបបានប្រាប់ពួកគាត់ថាបើធ្វើបែបនេះក្រុមទាំងពីរមិនខុសគ្នាទេ ។ ពេលឃើញអ្នាប់ឌុល-មុត្តត៍មានចិត្តទូលំទូលាយ ក្រុមមួយទៀតបានថាហេតុការណ៍អស្ចារ្យដែលបានកើតឡើង ដោយរកទឹកបាននោះជាភ័ស្តុតាងពីអល់ឡោះហ្ ﷻ បញ្ជាក់ថាអណ្ដូងទឹកស៊ាំស៊ាំជាកម្មសិទ្ធិរបស់អ្នាប់ឌុល-មុត្តត៍លិប ។ ទាំងអស់គ្នាក៏បានឈប់ត្រឹមនេះ មិនបន្តដំណើរទៅមុខទៀតទេ ហើយក៏បាននាំគ្នាត្រឡប់ទៅម៉ាក់កាស់វិញ ។

ត្រឡប់មកដល់ផ្ទះវិញ អ្នាប់ឌុល-មុត្តត៍លិបបានជីកអណ្ដូងជ្រៅជាងមុន រកឃើញកំណប់មួយ មានរូបក្ដាន់មាសពីរ មានដាវនិងអាវក្រោះសង្គ្រាម ។ ម្ដងទៀតពួកគូរ៉យស្ហ៍សូមឲ្យចែកកំណប់នោះ ពួកគេនឹងកប់ដីអណ្ដូងនេះវិញបើពុំបានមួយចំណែកទេនោះ ។ គេក៏បានសម្រេចឲ្យចាប់ឆ្នោត លទ្ធផលគឺ ក្ដាន់មាសពីរបានទៅព្រះមហាគ្រឹះកាក់បាស្ហ៍ សល់ពីនោះបានទៅអ្នាប់ឌុល-មុត្តត៍លិបទាំងអស់ ពួកគូរ៉យស្ហ៍ពុំបានអ្វីសោះ ។

កាលនោះឯងដែលអ្នាប់ឌុល-មុត្តត៍លិបបានបរិច្ចាគ ១/៥ (មួយភាគប្រាំ) នៃចំណែករបស់លោកទៅលើការចាយវាយនៅលើមាគ៌ាអល់ឡោះហ្ ﷻ ។

## ជ្រុងលំហាត់

តើអណ្ដូងទឹកស៊ាំស៊ាំមានទំនាក់ទំនងអ្វី ជាមួយការដើរវាងស្វ័ហ្វានិងម៉ារវ៉ាស្ទ៌ក្នុងពិធីហាជ្ជ៍ ? ចូរសរសេរចម្លើយនៅខាងក្រោមនេះតាមដែលអ្នកដឹង ។

..............................................................................................................................

..............................................................................................................................

.............................................................................................................

## ជ្រុងវិភាគ

បន្ទាប់ពីបានអានមេរៀននេះ តើអ្នកយល់ដឹងអ្វីខ្លះអំពីប្រជាជាតិគួរ៉យ៉ស្ទ៍ ? តើពួកគេជាមនុស្សប្រភេទណា ? ចូរគិតដល់ការប្រព្រឹត្តរបស់ពួកគេចំពោះ អាប់ឌុល-មុត្តត៏លិប ។

..............................................................................................................................

..............................................................................................................................

.............................................................................................................

***ពេលនេះអ្នកដឹង...***

- អណ្ដូងទឹកស៊ាំស៊ាំមានតាំងពីសម័យព្រះសាស្ដាអ៊ីបរ៉ហ៊ីម عليه السلام មកម្ល៉េះ ។ កាលពីដំបូង គេបានប្រើហួសពេកទើបអណ្ដូងនេះរីងទឹកអស់ ។ សម័យអាប់ឌុល-មុត្តត៏លិប គេគ្រាន់តែដឹងថាធ្លាប់មានអណ្ដូងទឹក ។
- នៅក្នុងសុបិន គេបានប្រាប់ឲ្យអាប់ឌុល-មុត្តត៏លិបជីកអណ្ដូង តែពួកគួរ៉យ៉ស្ទ៍មិនព្រមឲ្យលោកជីកតែម្នាក់ឯងទេ ។ ដូច្នេះពួកគេបានសម្រេចចិត្តធ្វើតាមយោបល់របស់បុរសអ្នកមានប្រាជ្ញាញាណដែលរស់នៅឯប្រទេសស៊ីរី ។
- តាមផ្លូវទៅប្រទេសស៊ីរី អាប់ឌុល-មុត្តត៏លិបនិងបក្សពួកអស់ទឹកផឹក ។ គេមិនព្រមឲ្យទឹកពួកគាត់ផឹកទេ ។

- តែ អាស្រ័យព្រះគុណអល់ឡោះហ្ជ៍عز وجل អាប់ឌុល-មុត្តត៍លិបរកទឹកផឹកបាន លោកចែកទឹកនោះឲ្យអ្នកផងផឹកដែរដោយពេញចិត្ត ។ ពួកគូរ៉យ៉ស្ហ៍បកស្រាយព្រឹត្តិការនេះជាសញ្ញាមួយរបស់អល់ឡោះហ្ជ៍عز وجلដែលបញ្ជាក់ថា អណ្ដូងទឹកស៊ាំស៊ាំជាកម្មសិទ្ធិរបស់អាប់ឌុល-មុត្តត៍លិប ។ ទាំងអស់គ្នាក៏បានវិលត្រឡប់ទៅម៉ាក់កាស្ហ៍វិញ ។
- ត្រឡប់មកដល់ផ្ទះវិញ អាប់ឌុល-មុត្តត៍លិបជីកអណ្ដូងជ្រៅជាងមុន រកឃើញកំណប់មួយ ។ លោកបានដាក់មួយភាគប្រាំនៃចំណែកកំណប់របស់លោកជាវិភាគទានលើមាត៌ាអល់ឡោះហ្ជ៍عز وجل ។

## មេរៀនទី ៦

# អាប់ឌុល-មុត្តលិប កូនរបស់ ហាស្ហ៊ីម - ភាគ ៣

## ណាស្ហ៊ររបស់អាប់ឌុល-មុត្តលិប

កាលអាប់ឌុល-មុត្តលិបជីកអណ្ដូងទឹកស៊ាំស៊ាំ លោកដឹងខ្លួនថាលោកមានគោលជំហរខ្សោយនៅកណ្ដាលពួកគូរ៉យស្ហ៍ ព្រោះលោកមានកូនប្រុសតែមួយ ។ ពេលនោះលោកបានធ្វើណាស្ហ៊រ សន្យាចំពោះអល់ឡោះហ្ ﷻ ថាបើព្រះអង្គ ﷻ ព្រះរាជទានកូនប្រុស ១០ នាក់ឲ្យលោក លោកនឹងបូជាកូនប្រុសម្នាក់ឲ្យអល់ឡោះហ៍ ﷻ ។ អល់ឡោះហ៍ ﷻ ក៏បានប្រោសប្រណីអាប់ឌុល-មុត្តលិបដោយឲ្យលោកមានកូនច្រើន ។ លោកមានកូនប្រុស ១២ នាក់ ក្នុងចំណោមកូនប្រុសទាំង ១២ នាក់នោះមាន ហារីស្ហ, អាប៊ូ ត៉លិប, ហាំស្ហាស្ហ, អាប់បាស់, អាប៊ូ លាហាប់, ស៊ូបៃរ ។ លោកមានកូនស្រី ៦ នាក់ដែរ ។

ពេលបានកូនគ្រប់ ១០ នាក់ អាប់ឌុល-មុត្តលិបដឹងថាដល់ពេលធ្វើណាស្ហ៊រ ។ ទោះបីពិបាកលះបង់កូនសំឡាញ់ម្នាក់ក៏ដោយ លោកមិនចង់ក្បត់សន្យាចំពោះអល់ឡោះហ៍ ﷻ ទេ ។ ក្រោយពីបានប្រាប់កូនប្រុសៗរបស់លោកឲ្យដឹងហេតុការណ៍ លោកបានសម្រេចចិត្តផ្សងដើម្បីនឹងដឹងថាត្រូវលះបង់កូនមួយណា ។ ឈ្មោះអាប់ឌុលឡោះហ៍ បិតារបស់ព្រះសាស្ដាយើង ﷺ បានលេចឡើង ។

អាប់ឌុលឡោះហ៍ជាកូនពៅគេនិងជាកូនសម្លាញ់បង្អស់របស់ឪពុក តែអាប់ឌុល-មុត្តលិបមិនល្មៀងចេញពីកាតព្វកិច្ចរបស់ខ្លួនទេ ហើយបាននាំកូនទៅកាន់កន្លែងបូជា ។ តែគ្រួសារនិងប្រជារាស្ត្រគូរ៉យស្ហ៍ពិបាកចិត្តណាស់ដែលត្រូវបាត់បង់កុមារអាប់ឌុលឡោះហ៍ ទាំងអស់គ្នាបានអង្វរអាប់ឌុល-មុត្តលិបសូមឲ្យលោកដោះស្រាយដោយវិធីផ្សេង ។

គេបាននាំដំណឹងនេះទៅប្រាប់បុរសអ្នកមានប្រាជ្ញាញាណ លោកក៏បានស្នើឲ្យដាក់អាប់ឌុលឡោះហ៍និងអូដ្ឋ ១០ ក្បាលផ្សង ។ បើផ្សងត្រូវអាប់ឌុលឡោះហ៍ ឲ្យថែមអូដ្ឋ ១០ ក្បាលទៀត ហើយផ្សងម្ដងទៀត លុះត្រាតែផ្សងត្រូវអូដ្ឋ ។ សម័យ

នោះ ថ្លៃពិន័យសងជម្ងឺចិត្តពេលមានបទឃាតកម្មដោយអចេតនាគឺអូដ្ឋ ១០ ក្បាល ពួកគ្រូរ៉យស៍យល់ឃើញថាការស្នើនេះត្រឹមត្រូវ ។ អាប់ឌុល-មុត្តត៍លិបយល់ព្រមធ្វើតាមយ៉ាងលំបាក ។ គេក៏បានផ្សងរវាងអាប់ឌុលឡោះហ្ម៍និងអូដ្ឋ ១០ ក្បាល តែផ្សងត្រូវអាប់ឌុលឡោះហ្ម៍ ។ គេបានថែមចំនួនអូដ្ឋដល់ទៅ ២០ ម្តងហើយម្តងទៀតទាល់តែដល់ ១០០ ក្បាល ។ ទីបំផុត លុះគេដាក់អាប់ឌុលឡោះហ្ម៍និងអូដ្ឋ ១០០ ក្បាលផ្សង គេផ្សងត្រូវអូដ្ឋ ។ ប្រជារាស្ត្រសប្បាយចិត្តណាស់ តែអាប់ឌុល-មុត្តត៍លិបស្ទាក់ស្ទើរក្នុងចិត្ត ខ្លាចពុំបានគោរពពាក្យសន្យាចំពោះអល់ឡោះហ្ម៍ ។ លោកបានឲ្យផ្សង ៣ ដងទៀត គេផ្សងជាប់អូដ្ឋរាល់ៗដង ។ ទីបំផុត លោកជឿជាក់ថាទង្វើលោកត្រឹមត្រូវមែន ។ លោកបានឲ្យគេសំឡេះអូដ្ឋទាំង ១០០ ក្បាលនោះនៅពីមុខព្រះមហាគ្រឹះកាក់បាស់ កុំឲ្យគេហាមមនុស្សឬសត្វណាមួយបរិភោគសាច់អូដ្ឋនោះ ។

អល់ឡោះហ្ម៍បានការពារអាប់ឌុលឡោះហ្ម៍ដូចនេះឯង ដែលនឹងត្រូវទៅជាបិតារបស់ព្រះសាស្តាមូហាំម៉ាដ់យើង ។ មួយឆ្នាំមុន អាំមុល-ហ្វីល (ឆ្នាំដំរី) អាប់ឌុលឡោះហ្ម៍បានរៀបការជាមួយអាមីណាស់ បុត្រីរបស់វ៉ាហ្ហាប់ ។ អាមីណាស់នឹងទៅជាមាតារបស់ព្រះសាស្តា ។

ក្រោយពីរៀបការបានមួយឆ្នាំ ពេលវិលត្រឡប់មកពីធ្វើជំនួញនាប្រទេសស៊ីរីវិញ អាប់ឌុលឡោះហ្ម៍ធ្លាក់ខ្លួនឈឺនៅម៉ាឌីណាស់ ។ លុះអាប់ឌុល-មុត្តត៍លិបបានទទួលដំណឹង លោកបានឲ្យហារីស្ទ៍ទៅមើលអាប់ឌុលឡោះហ្ម៍ ។ មុនហារីស្ទ៍បានទៅដល់ទីដៅ អាប់ឌុលឡោះហ្ម៍បានទទួលអនិច្ចកម្ម ។ សពលោកត្រូវបញ្ចុះនៅឯម៉ាឌីណាស់ ។ លោកបានស្លាប់ ២ ខែមុនបុត្រឧត្តុង្គឧត្តមបានប្រសូត ។

ព្រះសាស្តាមានព្រះវចនៈថា៖ "ខ្ញុំជាកូនរបស់ព្រះតង្វាយពីរគឺ៖ ព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺនិងអាប់ឌុលឡោះហ្ម៍ ។"

## ផ្ទៀងលំហាត់

តើមានន័យថាអ្វី ដែលព្រះសាស្តាមានព្រះវចនៈអំពីព្រះតង្វាយព្រះសាស្តាអ៊ីសម៉ាអ៊ីលﷺនោះ ? ចូរសរសេរចម្លើយអ្នកពីរបីឃ្លាអំពីរឿងនេះ ។

## ជ្រុងស្រាវជ្រាវ

នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្វ៍ عز وجل សរសើរអ៊ីម៉ាំអ្អាលី صلوات الله عليه والسلام និងគ្រួសារព្រះអង្គ صلوات الله عليه والسلام ដែលបានគោរពពាក្យសន្យាណាស្ទារ៍នៅក្នុងស្វូរ៉ោះត្ហ៍ អាដ្ធ់ដ្ធាស្ហ់រ៍ (ឬ អាល់-អ៊ីនសាន) អាយ៉ាស្ហ់ ៧ ដល់អាយ៉ាស្ហ់ ៨ ។ ចូរស្វែងរកអាយ៉ាស្ហ់ទាំងពីរនេះ ហើយសរសេរសម្រាយរបស់វា ។

## *ពេលនេះអ្នកដឹង...*

- អ្អាប់ឌ្ទុល-មុត្តត្ត៍លិបបានធ្វើណាស្ទារ៍ថា បើលោកមានកូនប្រុស ១០ នាក់ លោកនឹងលះបង់ម្នាក់ក្នុងព្រះនាមអល់ឡោះហ្វ៍ عز وجل ។
- លោកបានកូនប្រុស ១២ នាក់ កូនស្រី ៦ នាក់ ។
- ដើម្បីគោរពណាស្ទាររបស់លោក លោកបានផ្សងថាត្រូវលះបង់កូនប្រុសមួយណា ។ ផ្សងជាប់អ្អាប់ឌ្ទុលឡោះហ្វ៍ដែលជាកូនពៅគេនិងជាកូនសម្លាញ់បង្អស់របស់លោក ។
- ពួកគូរ៉យ៉ស្ហ៍មិនសុខចិត្តទេ ដែលអ្អាប់ឌ្ទុល-មុត្តត្ត៍លិបបូជាអ្អាប់ឌ្ទុលឡោះហ្វ៍ ។ ដូច្នេះគេបានសម្រេចចិត្តដាក់អូដ្ឋ ១០ ក្បាលផ្សងជួសអ្អាប់ឌ្ទុលឡោះហ្វ៍ ។ ផ្សងជាប់អ្អាប់ឌ្ទុលឡោះហ្វ៍ គេក៏បានថែមអូដ្ឋ ១០ ក្បាលទៀត ហើយផ្សងម្តងទៀត ។

- ទីបំផុត ក្រោយពីបានផ្សងច្រើនដង គេបានផ្សងជាប់អូដ្ឋ ១០០ ក្បាលដើម្បីនឹងឲ្យអាប់ឌុលឡោះហ្វ៍បានរួចជីវិត ។ គេក៏បានសំឡេះអូដ្ឋទាំង ១០០ ក្បាល ។
- អាប់ឌុលឡោះហ្វ៍បានរៀបការជាមួយអាមីណាស់ ព្រះសាស្ដាﷺបានចាប់កំណើត ។ តែអកុសល អាប់ឌុលឡោះហ្វ៍បានស្លាប់ពីរខែមុនព្រះរាជបុត្រឧត្តុង្គឧត្តមរបស់លោកប្រសូត ។

## មេរៀនទី ៧

# អាប់ឌុល-មុត្តាលិប កូនរបស់ ហាស៊ីម - ភាគ ៤

### អាំមុល-ហ្វីល (عَامُ الْفِيلِ ឆ្នាំដំរី)

យេមេនជាស្រុកជិតខាងរបស់អារ៉ាប៊ី ។ មុនព្រះសាស្តាមូហាំម៉ាដ់ﷺប្រសូតបន្តិច ស្រុកយេមេនមានអភិបាលម្នាក់ឈ្មោះអាប់រ៉ហាស់ ។ ពេលដឹងថាពួកអារ៉ាប់គោរពព្រះមហាគ្រឹះកាក់បាស់ណាស់ អាប់រ៉ហាស់បានសម្រេចចិត្តសាងសង់វិហារគ្រិស្តមួយដ៏ធំនៅឯនគរស្វាន់អាអ៍ (صنعاء) នៃប្រទេសយេមេន ។ ពេលសាងវិហារគ្រិស្តរួច អាប់រ៉ហាស់ឲ្យពួកអារ៉ាប់ចោលកាក់បាស់មកកាន់វិហារខ្លួនវិញ ។ ប្រជាជាតិអារ៉ាប់មិនត្រឹមតែមិនអើពើការស្នើសូមនេះទេ យប់មួយ ស្ត្រីម្នាក់ជនជាតិបានីអាហ្ស៍កាំបានបន្ទោបង់ក្នុងវិហារនេះ ។ ឧប្បត្តិហេតុមួយទៀតគឺ កាលពួកអ្នកដំណើរអារ៉ាប់បានជ្រកក្នុងវិហារនេះ ហើយបានបង្កាត់ភ្លើងដើម្បីបំបាត់រងា បណ្ដាលឲ្យឆេះវិហារដោយអចេតនា ។ អាប់រ៉ហាស់ក្រោធខ្លាំង បានសម្រេចចិត្តកម្ទេចព្រះមហាគ្រឹះកាក់បាស់ចោលឲ្យស្រេចតែម្ដង ។

ឆ្នាំ ៥៧០ នៃគ្រិស្តសករាជ អាប់រ៉ហាស់លើកទ័ពមួយដ៏សម្បើមមកកាន់ម៉ាក់កាស់ ។ អាប់រ៉ហាស់និងទ័ពមកឈប់នៅជាយនគរម៉ាក់កាស់ ឲ្យគេទៅចាប់អូដ្ឋអ្នកស្រុកម៉ាក់កាស់ ។ អូដ្ឋរបស់អាប់ឌុល-មុត្តាលិបប្រមាណ ២០០ ក្បាលត្រូវគេចាប់ទុក ។

ភ្នាក់ងារម្នាក់បានទៅជួបពួកអ្នកស្រុកម៉ាក់កាស់ក្នុងនាមអាប់រ៉ហាស់ ថា អាប់រ៉ហាស់មិនមានបំណងធ្វើបាបអ្នកណាមួយទេ តែលោកមកនេះដើម្បីកម្ទេចព្រះមហាគ្រឹះកាក់បាស់ចោលដោយដំរី ។ អាប់ឌុល-មុត្តាលិប មេដឹកនាំរបស់ពួកគូរ៉យស៍ បានឆ្លើយវិញថាពួកគេក៏មិនចង់ប្រយុទ្ធតទល់នឹងអាប់រ៉ហាស់ដែរ ។ ចំណែកឯព្រះមហាគ្រឹះកាក់បាស់នោះជាព្រះគ្រឹះស្ថានរបស់អល់ឡោះហ៍ﷻ ព្រះអង្គﷻមានព្រះបំណងធ្វើអ្វីស្រេចតែព្រះអង្គﷻ ។

បន្ទាប់ពីនោះ ជាមួយកូនប្រុសពីរបីនាក់ អាប់ឌុល-មុត្តាលិបបានទៅជួប

អាប់រ៉ហាស្វ ។ អាប់រ៉ហាស្វបានគំនាប់អាប់ឌុល-មុត្តត៌លិបដោយសេចក្តីគោរព ។ អាប់រ៉ហាស្វគិតថា អាប់ឌុល-មុត្តត៌លិបនឹងសូមកុំឲ្យខ្លួនវាយកម្ទេចព្រះមហាគ្រឹះកាក់បាស្វ ផ្ទុយទៅវិញ អាប់ឌុល-មុត្តត៌លិបសូមឲ្យខ្លួនប្រគល់អូដ្ឋឲ្យលោកវិញ ។ អាប់រ៉ហាស្វឆ្ងល់ណាស់ដែលអាប់ឌុល-មុត្តត៌លិបបារម្ភតែអូដ្ឋលោក រីឯព្រះមហាគ្រឹះកាក់បាស្វជិតនឹងត្រូវកម្ទេចចោល ។

ចម្លើយតបចម្ងល់របស់អាប់រ៉ហាស្វ អាប់ឌុល-មុត្តត៌លិបបានថ្លែងពាក្យពេជន៍មួយឃ្លាដែលក្លាយទៅជាល្បីគឺៈ "ខ្ញុំជាម្ចាស់អូដ្ឋ ។ ព្រះមហាគ្រឹះក៏មានម្ចាស់ដែរដែលមើលថែរក្សាវា ។" អាប់រ៉ហាស្វគ្រវីក្បាលដាក់សម្តីនេះ ហើយតបវិញយ៉ាងក្រអឺតថាៈ "ពុំមានអ្នកខ្លាំងពូកែណាអាចរារាំងខ្ញុំបានទេ ។"

ត្រឡប់មកដល់លំនៅវិញ អាប់ឌុល-មុត្តត៌លិបបានបញ្ជាឲ្យប្រជារាស្ត្រលោកចាកចេញពីម៉ាក់កាស្វទៅលើភ្នំក្រែងលោមានគ្រោះថ្នាក់ ។ បន្ទាប់មកលោកបានបួងសួងអល់ឡោះហ្ ﷻ សូមឲ្យព្រះអង្គ ﷻ ការពារពួកគេនិងការពារព្រះមហាគ្រឹះកាក់បាស្វពីវិនាសអន្តរាយ ។

ព្រឹកឡើង អាប់រ៉ហាស្វត្រៀមខ្លួនលើកទ័ពទៅកាន់ម៉ាក់កាស្វ ។ ស្រាប់តែសត្វស្លាបទាំងហ្វូងៗលេចឡើងពីខាងសមុទ្រ ជញ្ជូនដុំថ្មតូចៗដោយក្រញាំជើងនិងចំពុះ ។ សត្វស្លាបនីមួយៗជញ្ជូនដុំថ្មបីដុំមកទម្លាក់លើកងទ័ពរបស់អាប់រ៉ហាស្វដោយវិធីនីមួយដែលធ្វើឲ្យដំរីនិងមនុស្សច្រើននាក់ស្លាប់យ៉ាងទាន់ហន់ ។ ថ្មមួយដុំត្រូវក្បាលអាប់រ៉ហាស្វ អាប់រ៉ហាស្វភ័យតក្កមាក៏បានបញ្ជាឲ្យកងទ័ពដែលនៅសេសសល់ដកថយវិញភ្លាម ។ រេហ៍ពលច្រើនរបស់អាប់រ៉ហាស្វបានស្លាប់តាមផ្លូវត្រឡប់ទៅស្រុកវិញ ។ ឯខ្លួនអាប់រ៉ហាស្វផ្ទាល់បានទៅដល់ស្វ្រន់អាយ៉ុំវិញ ដោយដាច់សាច់ទាំងដុំៗធ្លាក់មកដី ហើយបានស្លាប់យ៉ាងវេទនា ។

ព្រឹត្តិការណ៍ដ៏វេទនានិងអស្ចារ្យនេះមានចែងនៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៌ អាល់-ហ្វីល គឺៈ

أَلَمْ تَرَ كَيْفَ فَعَلَ رَبُّكَ بِأَصْحَٰبِ ٱلْفِيلِ ﴿١﴾ أَلَمْ يَجْعَلْ كَيْدَهُمْ فِى تَضْلِيلٍ ﴿٢﴾ وَأَرْسَلَ عَلَيْهِمْ طَيْرًا أَبَابِيلَ ﴿٣﴾
تَرْمِيهِم بِحِجَارَةٍ مِّن سِجِّيلٍ ﴿٤﴾ فَجَعَلَهُمْ كَعَصْفٍ مَّأْكُولٍ ﴿٥﴾

*១. អ្នកមិនបានឃើញទេ ថាព្រះម្ចាស់អ្នកបានប្រព្រឹត្តដូចម្តេចខ្លះលើបនម្ចាស់ដំរី? ២. ព្រះអង្គមិនបានធ្វើឲ្យឧបាយកលពួកគេភាន់ខូចអស់ទេ? ៣. ព្រះអង្គបាន*

*បញ្ជូនហ្វូងសត្វស្លាបទៅតទល់ស៊ូនឹងពួកគេ ៤. ដោយចោលដុំថ្មឥដ្ឋទៅលើពួកគេ ។ ៥. ព្រះអង្គធ្វើឲ្យពួកគេទៅជាដូចចំបើងទំពាលម្អិត ។*(១០៥:១-៥)

## ផ្រុងលំហាត់

ចូរអ្នកអានសម្រាយស៊ូរ៉ោះត៍ អាល់-ហ្វីល ។ តាមអ្នកយល់ឃើញ តើអល់ឡោះហ៍ﷻ ចង់មានព្រះបន្ទូលថាអ្វីអំពីបុគ្គលដែលបៀតបៀនអល់ឡោះហ៍ﷻ និងសាសនាអ៊ីស្លាម ?

..........................................................................................................

..........................................................................................................

..........................................................................................

## *ពេលនេះអ្នកដឹង...*

- អាប់រ៉ហ្វាស់ដឹកនាំប្រទេសយេមេន ។ លោកបានឲ្យគេសាងសង់វិហារសាសនាគ្រិស្តមួយដ៏ធំ ហើយបានអំពាវនាវឲ្យពួកអារ៉ាប់ចោលកាក់បាស់មកធ្វើសក្ការៈនៅក្នុងវិហាររបស់ខ្លួនវិញ ។
- តែពួកអារ៉ាប់មិនអើពើទេ ហើយបានធ្វើឲ្យភ្លើងឆេះវិហារនោះដោយអចេតនា ។ អាប់រ៉ហ្វាស់សម្រេចវាយកម្ទេចព្រះមហាគ្រឹះកាក់បាស់ ។
- អាប់រ៉ហ្វាស់មកកាន់ម៉ាក់កាស់ជាមួយទ័ពដំរីដ៏ធំ ។ មុននឹងចូលទៅក្នុងម៉ាក់កាស់ អាប់រ៉ហ្វាស់បានចាប់អូដ្ឋទាំងអស់របស់ពួកអ្នកស្រុកម៉ាក់កាស់ ។ បន្ទាប់មក បានចាត់បញ្ជូនអ្នកនាំសារម្នាក់ទៅប្រាប់ពួកគូរ៉យ៉ស្ហ៍ថាលោកមកវាយកម្ទេចបូជនីយគ្រឹះកាក់បាស់ មិនចង់ប្រយុទ្ធជាមួយពួកគេទេ ។
- អាប់ឌុល-មុត្តត៍លិបទៅជួបអាប់រ៉ហ្វាស់ ។ លោកបានសូមឲ្យអាប់រ៉ហ្វាស់ប្រគល់អូដ្ឋដែលត្រូវលួចនោះឲ្យលោកវិញ ។ អាប់រ៉ហ្វាស់ឆ្ងល់ដែលអាប់ឌុល-មុត្តត៍លិបបារម្ភតែអូដ្ឋលោក ខណៈដែលកាក់បាស់ជិតត្រូវកម្ទេចចោល ។

អាប៉ុឌុល-មុត្តាត្តលិបបានឆ្លើយថា៖ "ខ្ញុំជាម្ចាស់អូដ្ឋ ។ ព្រះមហាគ្រឹះក៏មានម្ចាស់ដែរ ដែលមើលថែរក្សាវា ។"

- ថ្ងៃបន្ទាប់ អាប់រ៉ហ្វាស់នាំទ័ពទៅកាន់ម៉ាក់កាស់ ។ តែអល់ឡោះហ្វ៍عزوجلការពារព្រះគ្រឹះស្ថានព្រះអង្គعزوجل ដោយចាត់បញ្ជូនសត្វស្លាបនាំដុំថ្មដោយក្រញ៉ាំជើងនិងចំពុះមកប្រយុទ្ធជាមួយទ័ពរបស់អាប់រ៉ហ្វាស់លុះខ្ទេច ។
- គេហៅឆ្នាំដែលព្រឹត្តិការណ៍នេះបានកើតឡើងនោះថា "អាំុមុល-ហ្វ៊ីល" ឆ្នាំ ដំរី ។ រឿងនេះមានចែងនៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍ អាល់-ហ្វ៊ីល ។

# លំហាត់មេរៀនសាឡើងវិញ ២

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺៈ

១. អាប់ឌុល-មុត្តត៌លិបនិងព្រះសាស្ដាﷺមានទំនាក់ទំនងអ្វីនឹងគ្នា ?

២. ហេតុអ្វីគេមិនហៅអាប់ឌុល-មុត្តត៌លិបតាមឈ្មោះពិតរបស់លោក ?

៣. ចូររៀបរាប់អំពីការកែប្រែធ្វើដោយអាប់ឌុល-មុត្តត៌លិប នៅក្នុងជីវិតនិងរបៀបរស់នៅរបស់ពួកគូរ៉យ៉ស្ស៍ ។

៤. តើគេបានលើកឋានៈឲ្យអាប់ឌុល-មុត្តត៌លិបថាអ្វី ? ឋានៈនេះមានន័យថាអ្វី ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើគេប្រាប់ឲ្យអាប់ឌុល-មុត្តត៌លិបធ្វើអ្វីក្នុងសុបិន ?

២. ហេតុអ្វីពួកគូរ៉យ៉ស្ស៍រារាំង មិនឲ្យអាប់ឌុល-មុត្តត៌លិបធ្វើតាមគេប្រាប់ក្នុងសុបិននេះ ?

៣. តើពួកគេបានសម្រេចធ្វើអ្វីដើម្បីដោះស្រាយជម្លោះនេះ ។

៤. ហេតុអ្វីពួកគូរ៉យ៉ស្ស៍លែងបន្តដំណើរ សុខចិត្តឲ្យអាប់ឌុល-មុត្តត៌លិបធ្វើតាមគេប្រាប់ក្នុងសុបិន ?

៥. តើអាប់ឌុល-មុត្តត៌លិបធ្វើអ្វីជាមួយទ្រព្យដែលបានមកលោកនោះ ?

## ខណ្ឌ គ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ណាស្មារ៍របស់អាប់ឌុល-មុត្តត៌លិបគឺអ្វី ?

២. ហេតុអ្វីលោកមិនបូជាអាប់ឌុលឡោះហ្វ៍ ?

៣. តើបុរសអ្នកមានប្រាជ្ញាញាណស្នើឲ្យធ្វើអ្វី ?

៤. តើគេបានបូជាអូដ្ឋប៉ុន្មានជួសអាប់ឌុលឡោះហ្វ៍ ?

៥. តើអ៊ុប់ឌុលឡោះហ្ញ៍ស្លាប់នៅឯណា សពលោកត្រូវបញ្ចុះនៅឯណា ?

## ខណ្ឌ ឃ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីអាប់រ៉ហ្វាស់ចង់កម្ទេចព្រះមហាគ្រឹះកាក់បាស់ ?

២. ហេតុអ្វីអ៊ុប់ឌុល-មុត្តត៉ូលិបទៅជួបអាប់រ៉ហ្វាស់ ?

៣. ហេតុអ្វីសម្ដីរបស់អ៊ុប់ឌុល-មុត្តត៉ូលិបធ្វើឲ្យអាប់រ៉ហ្វាស់ឆ្ងល់ ?

៤. ពាក្យពេជន៍ដ៏ល្បីល្បាញរបស់អ៊ុប់ឌុល-មុត្តត៉ូលិបនោះគឺអ្វី ?

៥. តើអល់ឡោះហ្ញ៍ عَزَّ وَجَلَّ បានចាត់បញ្ជូនអ្វីទៅវាយអាប់រ៉ហ្វាស់និងកងទ័ព ?

**មេរៀនទី ៨**

# កំណើតព្រះសាស្តាមូហាំម៉ាដ់ﷺ

ព្រះសាស្តានៃសាសនាអ៊ីស្លាម មូហាំម៉ាដ់ អាល់-មុស្ទហ្វាﷺ ប្រសូតថ្ងៃសុក្រទី ១៧ រ៉ាប៊ីអ៊ុល អៅវ៉ាល់ ត្រូវនឹងឆ្នាំ ៥៧០ នៃគ្រិស្តសករាជ នៅឯម៉ាក់កាស់ ។ ព្រះអង្គﷺប្រសូតក្នុងឆ្នាំដំរី (عَامُ الْفِيلِ) កាលអាប់រ៉ហាស់ចង់កម្ទេចព្រះមហាគ្រឹះកាក់បាស់ ។

អាប់ឌុលឡោះហ៍ កូនរបស់អាប់ឌុល-មុត្តត៏លិប ជាបិតារបស់ព្រះសាស្តាﷺ អាមីណាស់ កូនស្រីរបស់វ៉ាហ្វាប់ ជាមាតារបស់ព្រះសាស្តាﷺ ។ អាប់ឌុលឡោះហ៍បានទទួលអនិច្ចកម្មពីរខែមុនព្រះរាជបុត្រﷺលោកប្រសូត គេបានបញ្ចុះសពលោកនៅឯម៉ាឌីណាស់ ។ ព្រះសាស្តាﷺនៅក្នុងព្រះរាជវង្សថ្លៃថ្លាបានី ហាស៊ីមនៃប្រជាជាតិគូរ៉យស្ ។ អាប់ឌុល-មុត្តត៏លិបបានចិញ្ចឹមព្រះសាស្តាﷺ ។ ៧ ថ្ងៃបន្ទាប់ពីព្រះរាជនត្តា (ចៅ) លោកបានប្រសូត អាប់ឌុល-មុត្តត៏លិបបានបូជាពពែមួយដើម្បីអរព្រះគុណអល់ឡោះហ៍ﷻ ដែលបានព្រះរាជទានចៅប្រុសមានសុខភាពល្អឲ្យលោក ។ គេបានអញ្ជើញមនុស្សច្រើននាក់មកចូលរួមក្នុងពិធីបុណ្យ ។ នៅក្នុងប្រជុំជននេះ អាប់ឌុល-មុត្តត៏លិបបានប្រកាសថាលោកដាក់ឈ្មោះឲ្យទារកនេះថា "មូហាំម៉ាដ់" មានន័យ "ថាបុគ្គលគួរឲ្យសរសើរ" ។ ពេលពួកគូរ៉យស្សួរថាហេតុអ្វីលោកដាក់ឈ្មោះខុសពីធម្មតាឲ្យទារក អាប់ឌុល-មុត្តត៏លិបបានតបថាលោកចង់ឲ្យគេកោតសរសើរចៅលោកទាំងនៅលើមេឃនិងលើផែនដី ។

**ជ្រុងអារ៉ាប់**

ចូររៀនសរសេរ "មូហាំម៉ាដ់" ជាភាសាអារ៉ាប់ ។

__________ __________ __________ __________

កាលពីមុនព្រឹត្តិការណ៍នេះ មាតាព្រះសាស្ដាﷺបានដាក់ឈ្មោះព្រះអង្គﷺ ហើយថា "អាស្មុ៉ាដ្ម" ។ អល់ឡោះហ៊្ជ ប្រើឈ្មោះទាំងពីរនេះនៅក្នុងព្រះគម្ពីរគួរអាន ។

**ជ្រុងអារ៉ាប់**

ចូររៀនសរសេរ "អាស្មុ៉ាដ្ម" ជាភាសាអារ៉ាប់ ។

__________ __________ __________ __________

ព្រះសាស្ដាﷺបានបៅទឹកដោះមាតាតែបីថ្ងៃ ។ ទំនៀមទម្លាប់សម័យនោះតម្រូវឲ្យព្រះអង្គﷺមានមេដោះ ។ ស្ត្រីពីរនាក់មានកិត្តិយសជាមេដោះគឺ៖

១.*ស៊្ញូវៃបាស្ង* (ثُوَيبة) - ស្រីបម្រើរបស់អាប៊្ជ ឡាហ្បាប់ដែលឲ្យទឹកដោះព្រះសាស្ដាﷺបៅ ៤ ខែ ។ ព្រះសាស្ដាﷺនិងព្រះមហេសីព្រះអង្គﷺ សៃយីដ្ជាស្ង់ខ៍ឌីយ៉ាស្ង់ﷺគោរពស្ត្រីមេដោះនេះអស់មួយជីវិត ។ កាលព្រះសាស្ដាﷺត្រឡប់មកពីសមរភូមិខូយ៍បារវិញ ព្រះអង្គﷺបានទទួលដំណឹងថាគាត់ស្លាប់ ព្រះអង្គﷺសោកសៅក្រៃលែង ។

២.*ហាលីម៉ាស្ង* - គាត់ជាស្ត្រីប្រជាជាតិសាអ្អុដ់ ប៊ិន បាការ ។ គាត់បានចិញ្ចឹមព្រះសាស្ដាﷺនៅឯក្រៅនគរម៉ាក់កាស្ង់ នៅឯតំបន់ខ្សាច់ ។ ព្រះសាស្ដាﷺបានធាត់ធំ មានកម្លាំងពលំនិងសិក្សាអក្សរសាស្ត្រអារ៉ាប់សុទ្ធនៅទីនោះ ។ ព្រះអង្គﷺបានរស់នៅជាមួយស្ត្រីនេះ ៥ ឆ្នាំ ។

## ជ្រុងលំហាត់

ស៊ូរ៉ោះត៊ អាស្ស្វ-ស្វ៊ហ្វ៍ អាយ៉ាស់ ៦ (ស៊.៦១ អា.៦) ចែងអំពីព្រះសាស្តាយើងصلى الله عليه وآله وسلم ដោយហៅព្រះនាមព្រះអង្គصلى الله عليه وآله وسلمថា "អាស់ម៉ាដ្វ៉" ។ ស៊ូរ៉ោះត៊ អាល់-អាស់ស្ហាប់ អាយ៉ាស់ ៤០ (ស៊.៣៣ អា.៤០) ចែងអំពីព្រះអង្គصلى الله عليه وآله وسلمដោយហៅព្រះនាមព្រះអង្គصلى الله عليه وآله وسلم ថា "មូហ្ហាំម៉ាដ្វ៉" ។ ចូរស្វែងរកអាយ៉ាស់ទាំងពីរនេះ ហើយចូរសរសេរសម្រាយវា ។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

...................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

...................................................................

## លំហាត់បន្ថែម

អ៊ុប់ឌុល-មុត្តត៊លិបដាក់ឈ្មោះចៅصلى الله عليه وآله وسلمលោកថា "មូហ្ហាំម៉ាដ្វ៉" ព្រោះលោកចង់ឲ្យគេសរសើរព្រះអង្គصلى الله عليه وآله وسلمនៅលើមេឃនិងនៅលើផែនដី ។ ស៊ូរ៉ោះត៊ អាល់-អាស់ស្ហាប់ អាយ៉ាស់ ៥៦ (ស៊.៣៣ អា.៥៦) បំពេញគោលបំណងនេះ ។ ចូរសរសេរសម្រាយអាយ៉ាស់ ។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

...................................................................

***ពេលនេះអ្នកដឹង...***

- ព្រះសាស្តាﷺប្រសូតថ្ងៃសុក្រទី ១៧ រ៉បីអ៊ុល អៅវ៉ាល់ ត្រូវនឹងឆ្នាំ ៥៧០ នៃគ្រិស្តសករាជ នៅឯម៉ាក់កាស់ ។ គេហៅឆ្នាំដែលព្រះអង្គﷺប្រសូតថា អ៊ាំមុល-ហ្វ៊ីល គឺឆ្នាំដំរី ។
- បិតាព្រះអង្គﷺឈ្មោះអាប់ឌុលឡោះហ៍ មាតាព្រះអង្គﷺឈ្មោះអាមីណាស់ កូនស្រីរបស់វ៉ាហាប់ ។
- អាប់ឌុល-មុត្តតិ្ទលិបដាក់ឈ្មោះឲ្យព្រះសាស្តាﷺថា "មូហាំម៉ាដ់" មានន័យថា "បុគ្គលគួរឲ្យសរសើរ" ។ តែមាតាព្រះអង្គﷺបានដាក់ឈ្មោះឲ្យព្រះអង្គﷺថា "អាស់ម៉ាដ់" ស្រេចហើយកាលពីមុន ។ អល់ឡោះហ៍ﷻបានហៅព្រះអង្គﷺដោយនាមទាំងពីរនេះនៅក្នុងព្រះគម្ពីរគួរអាន ។
- អាមីណាស់ មាតាព្រះសាស្តាﷺ បានឲ្យទឹកដោះព្រះអង្គﷺបៅបានតែ ៣ ថ្ងៃទេ ។ ប្រពៃណីតម្រូវឲ្យមេដោះចិញ្ចឹមព្រះអង្គﷺ ។
- ព្រះអង្គﷺមានមេដោះពីរនាក់គឺ៖

1. *ស៊ូវ៉ៃបាស់* ស្ត្រីបម្រើរបស់អាប៊ូ ឡាហាប់ បានបំបៅព្រះសាស្តាﷺ ៤ ខែ ។ ព្រះសាស្តាﷺនិងព្រះមហេសីព្រះអង្គﷺ សៃយីដាស់ខ៊ឌីយ៉ាស់ سلام الله عليها គោរពគាត់ជានិច្ច ។

2. *ហាលីម៉ាស់* គាត់បានចិញ្ចឹមព្រះសាស្តាﷺឆ្ងាយពីម៉ាក់កាស់នៅឯតំបន់ខ្សាច់ ។ ព្រះអង្គﷺធាត់ធំនៅទីនេះ ។ ព្រះអង្គﷺបានរស់នៅជាមួយគាត់ ៥ ឆ្នាំ ។

## មេរៀនទី ៩

# កុមារភាពរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ

ព្រះសាស្ដាﷺបានរស់នៅឯតំបន់ខ្សាច់ជាមួយហាលីម៉ាស់អស់រយៈពេល ៥ ឆ្នាំ គាត់បានមើលថែរក្សាព្រះអង្គﷺបានយ៉ាងល្អ ។ កាលនោះ ព្រះអង្គﷺរៀនមើលថែទាំសត្វ ព្រះអង្គﷺបានហ្វឹកហាត់ខាងបាញ់ធ្នូដែរ ។ ព្រះអង្គﷺបានធាត់ធំ និងចម្រើនកម្លាំងកាយចិត្តនៅក្នុងបរិយាកាសរីករាយ ។ លោកស្រីហាលីម៉ាស់ឃើញថាព្រះអង្គﷺពិសេស ចាប់តាំងពីគាត់ទទួលខុសត្រូវលើរូបព្រះអង្គﷺមក គាត់បានទទួលគុណបុណ្យពីអល់ឡោះហ្ទ៍عز وجلនិងមានបានប្រសើរឡើង ។

ពេលព្រះអង្គﷺបានព្រះជន្ម ៥ ឆ្នាំ លោកស្រីហាលីម៉ាស់បានប្រគល់ព្រះអង្គﷺឲ្យទៅមាតាព្រះអង្គﷺ សៃយីដាស់អាមីណាស់ មើលថែរក្សាវិញ ។ អាប់ឌុល-មុតត៍លិប ជីតារបស់ព្រះរាជកុមារﷺ ថ្នាក់ថ្នមព្រះអង្គﷺណាស់ព្រោះព្រះអង្គﷺធ្វើឲ្យលោកនឹកដល់អាប់ឌុលឡោះហ្ទ៍កូនប្រុសលោក ។

សៃយីដាស់អាមីណាស់បានសម្រេចចិត្តទៅម៉ាឌីណាស់ ស៊ីរ៉ាស់ផ្នូរអាប់ឌុលឡោះហ្ទ៍ ស្វាមីព្រះនាង និងក្នុងបំណងទៅលេងសាច់ញាតិផង ។ ព្រះនាងបាននាំព្រះសាស្ដាﷺទៅជាមួយ ហើយបានស្នាក់នៅទីនោះមួយឆ្នាំ ។ តាមផ្លូវត្រឡប់មកម៉ាក់កាស់វិញ សៃយីដាស់អាមីណាស់ធ្លាក់ខ្លួនឈឺនៅឯស្រុកមួយហៅថា អាប់វ៉ាអ៍ ។ ក្រោយពីនោះបន្តិច ព្រះនាងសោយទិវង្គត សពព្រះនាងត្រូវបញ្ចុះនៅឯស្រុកនោះ ។ ព្រះសាស្ដាﷺក្លាយទៅជាកូនកំព្រា អាប់ឌុល-មុតត៍លិបយកព្រះអង្គﷺមកចិញ្ចឹម ។ លោកស្រឡាញ់ថៅណាស់ ប្រយ័តប្រយែងមិនឲ្យព្រះរាជនត្តាទទួលអារម្មណ៍ថាគេមិនត្រូវការព្រះអង្គﷺទេ ។

ព្រះមហាគម្ពីរគួរអានថែងអំពីរឿងនេះនៅក្នុងស៊ូរ៉ោះត៍ អាដ់-ឌូហា អាយ៉ាស់ ៦ (ស៊. ៩៣ អា.៦) ថា៖

أَلَمْ يَجِدْكَ يَتِيمًا فَـَٔاوَىٰ ﴿٦﴾

*៦. តើព្រះអង្គមិនបានឃើញអ្នកជាក្មេងកំព្រាទេ ហើយបានឲ្យជម្រក ?*(៩៣:៦)

ព្រះសាស្ដាﷺទើបតែមានព្រះជន្ម ៨ ឆ្នាំកាលព្រះអង្គﷺបានបាត់បង់ជីតា ។ មុនចូលទិវង្គត អុប់ឌុល-មុត្តត្ត៏លិបបានផ្ដែផ្ដាំឲ្យកូនប្រុសលោក អាប៊ូ ត្ត៏លិប ទទួលភារកិច្ចមើលថែរក្សាព្រះរាជកុមារﷺ ។ នេះគឺកាតព្វកិច្ចដែល អាប៊ូ ត្ត៏លិប បានបំពេញបានសម្រេចអស់មួយជីវិតលោក ។

មរណៈភាពរបស់អុប់ឌុល-មុត្តត្ត៏លិប ធ្វើឲ្យព្រះសាស្ដាﷺសោកសង្រេងជាទីបំផុត ព្រះអង្គﷺមិនលែងយំទេលុះជិតសោយទិវង្គត ព្រះអង្គﷺមិនភ្លេចគុណបុណ្យជីតាព្រះអង្គﷺឡើយ ។

មានច្រើនមូលហេតុដែលអុប់ឌុល-មុត្តត្ត៏លិបជ្រើសរើស អាប៊ូ ត្ត៏លិប ជាអាណាព្យាបាលរបស់ព្រះសាស្ដាﷺ ។ អាប៊ូ ត្ត៏លិបនិងអុប់ឌុលឡោះប៉ាជាបងប្អូនម្ដាយមួយ ។ អ្នកណាក៏ដឹងឮដែរថាលោកមានចិត្តសប្បុរសណាស់ ។ លោកមើលថែរក្សាព្រះសាស្ដាﷺល្អជាងកូនៗលោក មិនដែលធ្វើឲ្យព្រះអង្គﷺមានអារម្មណ៍កណ្ដោចកណ្ដែងឡើយ ។

កាលព្រះសាស្ដាﷺមានព្រះជន្ម ១២ ឆ្នាំ អាប៊ូ ត្ត៏លិបបាននាំព្រះអង្គﷺទៅធ្វើជំនួញនៅឯស្រុកស៊ីរី តាមក្បួនទូរចរពួកគូរ៉យស្ហ៍ ។ ក្បួនទូរចរបានកាត់តាមដែនដីម៉ាដ្យ៉ាន់ ជ្រលងគូរ៉និងស្រុកស្ហាមូដ្យមុននឹងបានឃើញទេសភាពស្រស់បំព្រងនៃស្រុកស៊ីរី ។ ព្រះសាស្ដាﷺធ្លាប់តែមានវចនៈជាញឹកញយថានេះគឺការធ្វើដំណើរដែលធ្វើឲ្យរីករាយពេញចិត្តបំផុត ។

មកដល់ប៊ុស្វ៉ (بُصْرَىٰ) ក្បួនទូរចរបានឈប់សម្រាកដើម្បីប្រមូលស្បៀងបន្តដំណើរ ។ នៅទីនោះមានសង្ឃចំណាស់ម្នាក់ឈ្មោះបាហ៊ីរ៉ (بَحِيرَىٰ) រស់នៅក្នុងវត្តគ្រិស្តមួយ ។ សង្ឃរូបនេះមិនដែលនិយាយស្ដីសោះ តែពេលបានឃើញព្រះសាស្ដាﷺ គាត់លែងតមសម្ដី សួរថា៖ "ក្មេងប្រុសនេះជាអ្នកណា ?" អាប៊ូ ត្ត៏លិបបានតបថាក្មួយប្រុសរបស់លោក ។ បាហ៊ីរ៉បានថា៖ "ក្មេងប្រុសនេះមានអនាគតត្រចះត្រចង់ ។ គេជាព្រះសាស្ដាដែលមានទំនាយនៅក្នុងព្រះគម្ពីរ ។ សាសនាគេនឹងខ្ចរខ្ចាយពេញពិភពលោក ។ តែចូរប្រយ័តពួកយ៉ាហ្វ៊ូឌី! បើពួកគេបានដឹងដំណឹងក្មេងប្រុសនេះ ពួកគេនឹងសម្លាប់គេ ។"

អ្នកប្រវត្តិសាស្ត្របានឲ្យដឹងថាបន្ទាប់ពីបានទទួលការព្រមាន អាប៊ូ ត្ត៏លិប លែងចង់បន្តដំណើរ ហើយក៏បានត្រឡប់ទៅម៉ាក់កាស្ហ៍វិញជាមួយព្រះសាស្ដា

ﷺ ។ អ្នកប្រវត្តិសាស្ត្រឯទៀតបានឲ្យដឹងថាលោកបានបន្តដំណើរទៅប្រទេសស៊ីរី តែព្យាយាមការពារព្រះសាស្តាﷺ ។ ទោះជាយ៉ាងណាក៏ដោយ អាប៊ូ ត៉ុលិបបាម្ភ អំពីសន្តិសុខរបស់ក្មួយលោកជាងមុនៗ ។

អ្នកប្រវត្តិសាសស្ត្របានសរសេរថា ព្រះសាស្តាﷺបានចេះដឹងប្រវត្តិព្រះសាស្តាដោយសារភិក្ខុគ្រិស្តសាសនិក បន្ទាប់មកព្រះអង្គﷺនិយាយប្រាប់គេដូចគេចារនៅក្នុងព្រះគម្ពីរគួរអានដែរ ។ នេះគឺពាក្យមុសាអប្រិយបំផុត ។

ពិបាកជឿណាស់ថាព្រះសាស្តាﷺអាចចេះដឹងទាំងអស់ ក្នុងពេលដ៏ខ្លីដែលបានជួបនឹងបុរសគ្រិស្តសាសនិក ហើយព្រះអង្គﷺអាចចងចាំសព្វគ្រប់បានរត់មាត់អស់ ២៨ ឆ្នាំ ក្រោយមកព្រះអង្គﷺថាគេបានបើកឲ្យព្រះអង្គﷺដឹងគួរអានកាលព្រះអង្គﷺអាយុ ៤០ ឆ្នាំ ។ ការពិត បាហ៊ីរ៉ាបានប្រាប់ អាប៊ូ ត៉ុលិប តែអំពីលក្ខណៈពិសេសរបស់ក្មួយលោកប៉ុណ្ណោះ ។

ព្រះសាស្តាﷺបានរស់នៅជាមួយ អាប៊ូ ត៉ុលិប ទាំងអស់គ្នាស្រឡាញ់និងថ្នាក់ថ្នមព្រះអង្គﷺ ។ ម្តាយធំព្រះអង្គﷺ ហ្វាតិ៉ម៉ាស់ ប៊ិនទី អាសាដ់ ភរិយារបស់អាប៊ូ ត៉ុលិប មាតារបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام មើលថែរក្សាព្រះអង្គﷺដូចកូនបង្កើត ។

***ពេលនេះអ្នកដឹង...***

- កាលព្រះសាស្តាﷺអាយុ ៥ ឆ្នាំ លោកស្រីហាលីម៉ាស់បានប្រគល់ការបីបាច់ថែរក្សាព្រះអង្គﷺឲ្យសៃយីដាស់អាមីណាស់ មាតាព្រះអង្គﷺវិញ ។
- សៃយីដាស់អាមីណាស់បាននាំព្រះសាស្តាﷺទៅម៉ាឌីណាស់ ស៊ីរ៉ាស់ផ្នូរអាប់ឌុលឡោះហ៍ ស្វាមីព្រះនាង និងក្នុងបំណងទៅលេងបងប្អូនផង ។ តែតាមផ្លូវត្រឡប់មកលំនៅដ្ឋានវិញ ព្រះនាងមានជម្ងឺហើយទទួលអនិច្ចកម្មនៅកន្លែងមួយដែលគេហៅថា អាប់វ៉ាអ៍ ។ គេបានបញ្ចុះសពព្រះនាងនៅកន្លែងនេះ ។
- ក្លាយទៅជាកូនកំព្រា អាប់ឌុល-មុត្តត៉ុលិប ជីតាព្រះអង្គﷺ យកព្រះអង្គﷺទៅចិញ្ចឹម ។ អកុសល កាលព្រះអង្គﷺអាយុ ៨ ឆ្នាំ ជីតាព្រះអង្គﷺក៏ទទួលអនិច្ចកម្មដែរ ។
- ការមើលខុសត្រូវព្រះសាស្តាﷺត្រូវផ្ទេរឲ្យទៅ អាប៊ូ ត៉ុលិប ឪពុកធំរបស់ព្រះ

អង្គﷺដែលមើលថែរក្សាព្រះអង្គﷺប្រសើរជាងកូនៗខ្លួនឯង ។ ហ្វាទីម៉ាស់ ម្ដាយធំព្រះអង្គﷺ ក៏មើលថែរក្សាព្រះអង្គﷺយ៉ាងល្អដែរ ។

- កាលព្រះសាស្ដាﷺអាយុ ១២ ឆ្នាំ អាប៊ូ ត៏ លិប បាននាំព្រះអង្គﷺទៅធ្វើជំនួញតាមក្បួនទូរចរពួកគូរ៉យស៍ ។ ដល់ប៊ុសរ៉ សង្ឃគ្រិស្ដសាសនិកចំណាស់ម្នាក់ឈ្មោះបាហ៊ីរ៉ ពេលឃើញព្រះសាស្ដាﷺ សួរថាព្រះអង្គﷺជាអ្នកណា ។ អាប៊ូ ត៏លិបបានតបថាព្រះអង្គﷺជាក្មួយលោក ។
- បាហ៊ីរ៉បានថាក្មេងនេះជាព្រះសាស្ដាដែលគេចែងនៅក្នុងព្រះគម្ពីរ ។ សាសនាព្រះអង្គﷺនឹងខ្ចរខ្ចាយពេញពិភពលោក ។ តែបើពួកយ៉ាហ៊ូឌីរកព្រះអង្គﷺឃើញ ពួកគេនឹងសម្លាប់ព្រះអង្គﷺ ។
- ចាប់ពីពេលនោះមក អាប៊ូ ត៏លិបប្រយ័តព្រះសាស្ដាﷺណាស់ ។

## មេរៀនទី ១០

# អាប៊ូ ត៏លិប និង ព្រះសាស្តាមូហាំម៉ាដ់ﷺ

ពេលស្លាប់ អ៊ុប់ឌុល-មុត្ត៏លិប បានទុកព្រះសាស្តាﷺនៅក្រោមការមើលថែរក្សារបស់កូនប្រុសលោក អាប៊ូ ត៏លិប ។ អាប៊ូ ត៏លិបនិងអ៊ុប់ឌុលឡោះហ្វ៍បិតារបស់ព្រះសាស្តាﷺ ជាបងប្អូនបង្កើតម្តាយមួយ ។ អាប៊ូ ត៏លិបយកព្រះសាស្តាﷺទៅចិញ្ចឹម មើលថែរក្សាព្រះរាជកុមារអាយុ ៨ ឆ្នាំដូចកូនបង្កើត ។ ភរិយាលោក សៃយីដ្ហាស់ហ្វាទី៏ម៉ាស់ ប៊ិនទី អាសាដ់ ក៏ស្រឡាញ់ព្រះសាស្តាﷺណាស់ដែរ ព្រះសាស្តាﷺទុកសៃយីដ្ហាស់ហ្វាទី៏ម៉ាស់ ប៊ិនទី អាសាដ់ដូចម្តាយបង្កើត ។

តាំងពីបាហ៊ីរ៉ ភិក្ខុគ្រិស្តសាសនិក បានប្រាប់ឲ្យប្រុងប្រយ័ត អាប៊ូ ត៏លិបការពារព្រះភាគិនេយ្យﷺ (ក្មួយប្រុស) ដោយយកចិត្តទុកដាក់ ។ លោកធ្លាប់តែឲ្យកូនប្រុសលោកម្នាក់ដេកក្នុងគ្រែព្រះសាស្តាﷺ ដើម្បីនឹងឲ្យព្រះអង្គﷺរួចជីវិតពេលសត្រូវលបវាយប្រហារ ។

កាលព្រះសាស្តាﷺធំឡើង ក៏ព្រះអង្គﷺនៅក្រោមអភិរក្សរបស់ឪពុកធំជាទីស្រឡាញ់ដែរ ដែលជាមេដឹកនាំជាទីគោរពម្នាក់របស់ពួកគូរ៉យ់ស៍ ។ ពេលព្រះសាស្តាﷺមានវ័យពេញ អាប៊ូ ត៏លិបជួយជម្រុញព្រះអង្គﷺឲ្យចូលរួមក្នុងកិច្ចការផ្សេងៗនិងក្នុងមុខរបរជួញដូរតាមក្បួនទូរចរ ។ លោកបានឲ្យក្មួយចូលបម្រើការសៃយីដ្ហាស់ខ៏ឌីយ៉ាស់ ប៊ិនទី ឃុវ៉ៃលីដ្ ។ ចំនួបនេះឈានទៅរកអាពាហ៍ពិពាហ៍របស់ព្រះសាស្តាﷺជាមួយស្ត្រីថ្លៃថ្លារូបនេះ ។ ពេលអាពាហ៍ពិពាហ៍ អាប៊ូ ត៏លិបជាអ្នកសូត្រឃុត្តបាស់និងជាប្រធានបុណ្យ ។

ដល់ពេលព្រះសាស្តាﷺប្រកាសបេសកកម្មសាស្តារបស់ព្រះអង្គﷺ អាប៊ូ ត៏លិបជាអ្នកគាំទ្រម្នាក់ដ៏ជ្រះថ្លារបស់ព្រះអង្គﷺ ។ ដរាបណាព្រះសាស្តាﷺនៅក្រោមអភិរក្សរបស់ឪពុកធំ ដរាបនោះពួកគូរ៉យ់ស៍មិនហ៊ានបៀតបៀនព្រះអង្គﷺទេ ។ កាលពួកគូរ៉យ់ស៍បណ្តេញពួកមុស្លីមចេញពីម៉ាក់កាស់ ពួកមុស្លីមបានរស់នៅឯជ្រលងមួយដែលគេហៅ "ជ្រលង អាប៊ូ ត៏លិប" ។ សម័យនោះ អាប៊ូ ត៏លិប ជួបប្រទះការលំបាកដូចព្រះសាស្តាﷺដែរ ទោះបីលោកអាចត្រឡប់ទៅម៉ាក់កាស់វិញ

បានដោយងាយស្រួលក៏ដោយ ពួកគួរ៉យ៉ស្ហ៍គោរពនិងផ្តល់កិត្តិយសឲ្យលោកនៅទីនោះ ។

ពួកខ្សត់វិជ្ជាបានសរសេរថា អាប៊ូ ត៉ូលិប មិនមែនមុស្លីមទេ ។ តែមានមូលហេតុច្រើនដែលជំទាស់សម្តីពួកខ្វះប្រាជ្ញាទាំងនេះគឺ៖ ខដំបូង អាប៊ូ ត៉ូលិបជាអ្នកដឹកនាំពិធីអាពាហ៍ពិពាហ៍របស់ព្រះសាស្តាﷺ ចំណែកឯបុគ្គលមិនមែនមុស្លីមមិនអាចដឹកនាំពិធីរៀបការរបស់បុគ្គលមុស្លីមបានទេ ។ ខទីពីរ គេដឹងច្បាស់ថា សៃយីដ្ហាស់ ហ្វាទី៉ម៉ាស់ ប៊ិនទី អាសាដ៉ ជាស្ត្រីមុស្លីម ព្រះនាងនៅជាភរិយារបស់អាប៊ូ ត៉ូលិប លុះស្លាប់ ។ ប៉ុន្តែ ស្ត្រីមុស្លីមមិនអាចនៅជាភរិយារបស់បុរសមិនមែនមុស្លីមបានទេ ។ ខទីបី កាល អាប៊ូ ត៉ូលិប ទទួលអនិច្ចកម្ម ព្រះសាស្តាﷺយំច្រើន ហើយព្រះអង្គﷺបានស្ហ៍ឡាត៉ឲ្យអ្នកស្លាប់ ។ ប៉ុន្តែ យើងដឹងស្រាប់ហើយថាគេហាមយើងស្ហ៍ឡាត៉សូមឲ្យបុគ្គលមិនមែនមុស្លីមបានសុគតិ ។ មូលហេតុទាំងអស់នេះនិងច្រើនទៀតលុបបំបាត់មន្ទិលសង្ស័យ បញ្ជាក់ថា អាប៊ូ ត៉ូលិប ជាមុស្លីមជ្រះថ្លាទោះបីលោកមិនបានប្រកាសឲ្យដឹងឮក៏ដោយ ។

នៅក្នុងមរតកសាសន៍របស់លោក អាប៊ូ ត៉ូលិប បានផ្តែផ្តាំកូនៗលោកឲ្យនៅជាប់ជាមួយព្រះសាស្តាﷺ កុំបោះបង់ចោលព្រះអង្គﷺជាដាច់ខាត ។ លោកបានផ្តាំដែរឲ្យកូនៗលោកឲ្យតាមសាសនាអ៊ីស្លាមដើម្បីនឹងបានជោគជ័យ ។

អនិច្ចកម្មរបស់ឪពុកធំព្រះអង្គﷺ ដែលបានគាំទ្រព្រះអង្គﷺជានិច្ចរហូតមកដល់ពេលនេះ ធ្វើឲ្យព្រះសាស្តាﷺសោកសង្រេងអនេក ។ ក្នុងឆ្នាំតែមួយ ព្រះអង្គﷺបានបាត់បង់ព្រះមហេសីជាទីស្រឡាញ់ សៃយីដ្ហាស់ ខ៉ុឌីយ៉ាស់سلام الله عليها ។ ដូច្នេះហើយបានជាព្រះសាស្តាﷺបានហៅឆ្នាំនោះថា "អ៊ាមុល-ហ៊ុស្ន៊ី" មានន័យ "ឆ្នាំសោកសង្រេង" ។

## ជ្រុងលំហាត់

បើគេប្រាប់អ្នកថា អាប៊ូ ត៉ូលិប មិនមែនមុស្លីមទេ តើអ្នកថាអ្វីដើម្បីបញ្ជាក់ប្រាប់អ្នកនោះថាលោកជាមុស្លីម ? ចូរសរសេរពីរបីឃ្លាខាងក្រោមនេះអំពីពាក្យសំអាងដែលអ្នកនឹងលើកឡើង ។

.................................................................................................................................

.................................................................................................................................

..............................................................................................

## ជ្រុងសិក្សាបន្ថែម

អាប៊ូ ត៉្លិប បានមើលថែរក្សាព្រះសាស្តាﷺដូចកូនបង្កើត ។ ចូរគិតដល់ឪពុកម្តាយអ្នកដែលបានចិញ្ចឹមអ្នកនិងការពារអ្នក ។

.................................................................................................................................

.................................................................................................................................

..............................................................................................

### *ពេលនេះអ្នកដឹង...*

- អាប៊ូ ត៉្លិប ត្រូវជ្រើសរើសជាអាណាព្យាបាលរបស់ព្រះសាស្តាﷺព្រោះបិតារបស់ព្រះអង្គﷺនិង អាប៊ូ ត៉្លិប ជាបងប្អូនបង្កើតម្តាយមួយ ។
- បន្ទាប់ពី បាហ៊ីរ៉ សង្ឃគ្រិស្តសាសនិក បានប្រាប់ឲ្យប្រុងប្រយ័ត អាប៊ូ ត៉្លិប បានយកចិត្តទុកដាក់អំពីសន្តិសុខព្រះសាស្តាﷺណាស់ ។ លោកធ្លាប់តែឲ្យកូនប្រុសលោកម្នាក់ទៅដេកលើគ្រែព្រះសាស្តាﷺ ដើម្បីនឹងឲ្យព្រះអង្គﷺរួចជីវិតពេលគេលបវាយប្រហារ ។
- អាប៊ូ ត៉្លិប បានជួយជម្រុញព្រះសាស្តាﷺឲ្យចូលរួមក្នុងកិច្ចការផ្សេងៗនិងក្នុងមុខរបរជួញដូរតាមក្បួនទូរចរ ។ ដូច្នេះព្រះអង្គﷺបានចូលប្រកបកិច្ចការឲ្យសៃយីដាស់ ខ៉ូឌីយ៉ាស់ (سلام الله عليها) កូនស្រីរបស់ ឃូវ៉ៃលីដ ។ ក្រោយមកព្រះអង្គﷺបាន អភិសេកជាមួយព្រះនាង (سلام الله عليها) ។
- ដល់ពេលព្រះសាស្តាﷺប្រកាសបេសកកម្មសាស្តារបស់ព្រះអង្គﷺ អាប៊ូ

ត្ថ៏លិប ជាអ្នកគាំទ្រដ៏ក្លៀវក្លាម្នាក់របស់ព្រះអង្គﷺ ។ លោកបានឈឺចាប់ដូចព្រះសាស្ដាﷺដែរកាលពួកគូរ៉យ៉ស្វ៍បណ្ដេញពួកមុស្លីមចេញពីម៉ាក់កាស្វ៉ ។

♦ ភ័ស្ដុតាងបញ្ជាក់ថា អាប៊ូ ត្ថ៏លិប ជាមុស្លីម គឺ៖

១) លោកបានដឹកនាំពិធីអាពាហ៍ពិពាហ៍របស់ព្រះសាស្ដាﷺ មានតែមុស្លីមទេដែលមានសិទ្ធិធ្វើបែបនេះ ។

២) សៃយីដាស្វ៉ ប៊ិនទី អាសាដ្វ៉ នៅភរិយាពេញច្បាប់រហូតរបស់ អាប៊ូ ត្ថ៏លិប ព្រះនាងជាស្ត្រីមុស្លីម ។ ស្ត្រីមុស្លីមអាចរៀបការបានជាមួយតែបុរសមុស្លីមទេ ។

៣) ព្រះសាស្ដាﷺបានយំនិងបានស្វ៏ឡាត្ញ៉ឲ្យ អាប៊ូ ត្ថ៏លិប កាលលោកទទួលអនិច្ចកម្ម ។ សាសនាអ៊ីស្លាមហាមស្វ៏ឡាត្ញ៉ឲ្យបុគ្គលមិនមែនមុស្លីម ។

## មេរៀនទី ១១

# យុវភាពរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺ

ពេលព្រះសាស្ដាﷺធំឡើង មនុស្សនៅជុំវិញព្រះអង្គﷺសម្គាល់ឃើញថា យុវជននេះមិនដូចយុវជនឯទៀតទេ ។ គេស្ញើចចរិមារយាទនិងសេចក្ដីក្លាហានរបស់ព្រះអង្គﷺ ពួកគូរ៉យស្ញ៍ទាំងអស់ស្រឡាញ់ព្រះអង្គﷺ ។

កាលនៅក្មេង ព្រះសាស្ដាﷺបានធ្វើដំណើរទៅធ្វើជំនួញនៅឯប្រទេសស៊ីរីនិងប្រទេសយេមេនជាមួយឪពុកធំព្រះអង្គﷺ ។ យ៉ាងឆាប់ៗ នៅឯម៉ាក់កាស្ហ៍ ព្រះអង្គﷺល្បីឈ្មោះខាងធុរកិច្ច ខាងទៀងត្រង់និងខាងស្មោះត្រង់ ។ គេស្ញើចគុណសម្បត្តិព្រះសាស្ដាﷺណាស់ គេហៅព្រះអង្គﷺថា អាស្ស៊-ស្វ៍ឌិក្វ (សច្ចការី) និងអាល់-អាមីន (បុគ្គលស្មោះត្រង់) ។

ពេលគេជួបព្រះសាស្ដាﷺ គេថា៖ "នេះគឺយុវជនដែលកាន់មារយាទស្មើចំពោះបណ្ដាអ្នកមានឋានៈខ្ពស់និងបណ្ដាអ្នកតូចតាច ។ គេចេះគិតដល់មនុស្សដូចគ្នា ។ គេគោរពមនុស្សចាស់ អាណិតស្រឡាញ់ក្មេងៗ ។ គេមិននិយាយកុហកសោះ មិនប្រាប់អ្នកដទៃរឿងដែលគេបានប្រាប់ខ្លួនទេ ។ គេមិនមើលស្ត្រីដោយបំណងអាក្រក់ទេ គេមិនដែលខ្វះសុជីវធម៌ចំពោះអ្នកណាមួយសោះ ។ គេមិននិយាយអាក្រក់អំពីអ្នកដទៃ មិនខាតពេលវេលាក្នុងការចាប់កំហុសអ្នកដទៃទេ ។"

នេះគឺបុគ្គលលក្ខណៈរបស់ព្រះសាស្ដាយើងﷺ ពីរបីឆ្នាំក្រោយមក សូម្បីតែសត្រូវព្រះអង្គﷺក៏យកទ្រព្យមកផ្ញើនឹងព្រះអង្គﷺដែរ ដើម្បីរក្សាទុកកុំឲ្យបាត់បង់ពេលពួកគេចាកចេញពីម៉ាក់កាស្ហ៍ ។

ថ្ងៃមួយ បុរសម្នាក់មកម៉ាក់កាស្ហ៍ ត្រូវឈ្មួញម្នាក់លួចនៅឯផ្សារ ។ បុរសនេះទៅប្ដឹងពួកគូរ៉យស្ញ៍ថាគេបានកិបប្រាក់គាត់ ។ កាលនោះ អ្នកមានឋានៈខ្ពស់ខ្លះបានចាត់ឲ្យមានក្រុមមួយសម្រាប់ដោះស្រាយបញ្ហាបែបនេះ ជួយជ្រោមជ្រែងបណ្ដាអ្នករងអំពើអយុត្តិធម៌ ។

ពួកគេបានសម្រេចថា ប្រជាជាតិគូរ៉យស្ញ៍ធំៗត្រូវចុះហត្ថលេខាធ្វើកិច្ចព្រមព្រៀងការពារសិទ្ធិមនុស្សទូទៅ ។ គេហៅកិច្ចព្រមព្រៀងដ៏សំខាន់នេះថា "ហ៊ីលហ្វ៊

អាល់-ហ្វ៊ូឌូល (حِلْفُ الْفُضُول)" ឬ "សន្ធិសញ្ញាគោលការណ៍សំខាន់ៗ" ។ ព្រះសាស្ដា ﷺ បានចូលរួមក្នុងសន្ធិសញ្ញានេះដែរ ព្រះអង្គ ﷺ បានប្រតិបត្តិការយ៉ាងសកម្មក្នុងគណៈកម្មាធិការ ហ៊ីលហ្វ៊ អាល់-ហ្វ៊ូឌូល នេះ ។

ព្រះសាស្ដា ﷺ បានប្រកបកិច្ចការជាគង្វាលសត្វដែរ កាលព្រះអង្គ ﷺ នៅកំលោះ ។ កាលព្រះអង្គ ﷺ មានព្រះជន្ម ២៥ ឆ្នាំ ព្រះសាស្ដា ﷺ បានសាងកេរ្តិ៍ឈ្មោះល្អនៅម៉ាក់កាស់ ព្រះអង្គ ﷺ ទទួលបានទំនុកចិត្តនិងសេចក្ដីស្រឡាញ់ពីបណ្ដាមនុស្សជុំវិញព្រះអង្គ ﷺ ។

## ផ្លុងលំហាត់

ព្រះសាស្ដា ﷺ បានសាងកេរ្តិ៍ឈ្មោះល្អនៅម៉ាក់កាស់ ។ ចូរសរសេរនៅខាងក្រោមនេះតើព្រះអង្គ ﷺ បានធ្វើដូចម្ដេច ។

..........................................................................................................................

..........................................................................................................................

.....................................................................................................

## *ពេលនេះអ្នកដឹង...*

- កាលព្រះសាស្ដា ﷺ ធំឡើង ព្រះអង្គ ﷺ ជាយុវជនប្លែកពីធម្មតា ផ្ទុយពីយុវជនឯទៀតតំណាលព្រះអង្គ ﷺ ។ ពួកគូរ៉យស៊្សើចព្រះអង្គ ﷺ ណាស់ព្រោះព្រះអង្គ ﷺ ក្លាហាននិងមានមារយាទប្រពៃ ។
- ព្រះអង្គ ﷺ ជាគង្វាលសត្វមួយប៉ែកនៃយុវភាពព្រះអង្គ ﷺ ។ ព្រះអង្គ ﷺ បានធ្វើដំណើរជាមួយឪពុកធំព្រះអង្គ ﷺ អាប៊ូ ត៉លិប ដែរទៅប្រទេសស៊ីរីនិងប្រទេសយេមេន ។
- ពេលធ្វើដំណើរទៅបំពេញធុរកិច្ច ព្រះអង្គ ﷺ ទទួលបាននូវកេរ្តិ៍ឈ្មោះល្អព្រោះព្រះអង្គ ﷺ ត្រង់និងស្មោះ ។ គេហៅព្រះអង្គ ﷺ ថា អាស្ស៊-ស្វ៊ឌិក្វ (សច្ចការី) និង

អាល់-អាមីន (បុគ្គលស្មោះត្រង់) ។

- សូម្បីតែសត្រូវព្រះអង្គ(صلى الله عليه وآله وسلم)ក៏ទុកចិត្តព្រះអង្គ(صلى الله عليه وآله وسلم)ដែរ គេច្រើនតែទុកទ្រព្យផ្ញើនឹងព្រះអង្គ(صلى الله عليه وآله وسلم)ដើម្បីរក្សាទុកកុំឲ្យបាត់បង់ ពេលគេធ្វើដំណើរឆ្ងាយពីម៉ាក់កាស្ញ់ ។
- ព្រះសាស្ដា(صلى الله عليه وآله وسلم)ជាសមាជិកសកម្មម្នាក់របស់គណៈកម្មាធិការ "ហ៊្វីលហ្វ៍ អាល់-ហ្វ៍ឌ្ហូល" "សន្និសញ្ញាគោលការណ៍សំខាន់ៗ" គឺកិច្ចព្រមព្រៀងដើម្បីការពារសិទ្ធិមនុស្ស ។
- ពេលមានព្រះជន្ម ២៥ ឆ្នាំ ព្រះសាស្ដា(صلى الله عليه وآله وسلم)ទទួលបានទំនុកចិត្តនិងសេចក្ដីស្រឡាញ់ពីសំនាក់មនុស្សនៅជុំវិញព្រះអង្គ(صلى الله عليه وآله وسلم) ។

# លំហាត់មេរៀនសាឡើងវិញ ៣

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើពួកមុស្លីមធ្វើបុណ្យខួបកំណើតព្រះសាស្ដាﷺពេលណា ?

២. អ្នកណាជាបិតាមាតារបស់ព្រះសាស្ដាﷺ ?

៣. អ្នកណាដាក់ឈ្មោះឲ្យព្រះសាស្ដាﷺថា "មូហាំម៉ាដ់" ? មានន័យថាអ្វី ។

៤. តើមាតាព្រះអង្គﷺបានដាក់ឈ្មោះឲ្យព្រះអង្គﷺរួចហើយថាអ្វី ?

៥. អ្នកណាមើលថែរក្សាព្រះសាស្ដាﷺ កាលព្រះអង្គﷺអាយុ ៥ ឆ្នាំ ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ព្រះសាស្ដាﷺរៀនអ្វីកាលនៅឯតំបន់ខ្សាច់ ?

២. ហេតុអ្វី អាប់ឌុល-មុត្តត៍លិប បានជ្រើសរើស អាប៊ូ ត៍លិប ជាអ្នកមើលថែរក្សាចៅលោក ?

៣. តើបាហ៊ីរ៉កាន់សាសនាអ្វី ?

៤. តើអ៊ីមុាំអាលី صلوات الله عليه والسلام និងព្រះសាស្ដាﷺមានទំនាក់ទំនងអ្វីនឹងគ្នា ?

៥. ហេតុអ្វី អាប៊ូ ត៍លិប បារម្ភអំពីសន្តិសុខរបស់ក្មួយលោក ?

## ខណ្ឌ គ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វី អាប៊ូ ត៍លិប ត្រូវជ្រើសរើសដើម្បីចិញ្ចឹមព្រះសាស្ដាﷺ ?

២. តើ អាប៊ូ ត៍លិប ធ្វើអ្វីក្រោយពីបាហ៊ីរ៉ សង្ឃគ្រិស្តសាសនិក បានប្រាប់ឲ្យប្រុងប្រយ័ត ?

៣. ពេលព្រះសាស្ដាﷺពេញវ័យ តើ អាប៊ូ ត៍លិប ជួយជម្រុញព្រះអង្គﷺឲ្យធ្វើអ្វី ?

៤. កាលណា អាប៊ូ ត៍លិប បានចូលរួមក្នុងការលំបាកដែលព្រះសាស្ដាﷺបានជួប

ប្រទះ ?

៥. អ្វីកើតឡើងក្នុង "អាមុល-ហ៊ុសនី" "ឆ្នាំសោកសង្រេង" ?

## ខណ្ឌ ឃ

ចូរឆ្លើយសំណួរតទៅគឺ៖

១. តើពួកគ្រីស្ទានបានកត់សម្គាល់ឃើញ ព្រះសាស្តាﷺប្លែកពីគេត្រង់ណាខ្លះ ប្រៀបធៀបនឹងយុវជនឯទៀតដែលតំណាលព្រះអង្គﷺនោះ ?

២. តើគេដាក់ងារឲ្យព្រះសាស្តាﷺថាអ្វី ?

៣. ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយណាដែលបញ្ជាក់ឲ្យដឹងថា សូម្បីតែសត្រូវព្រះសាស្តាﷺក៏ស្ញើចព្រះអង្គﷺដែរ ?

៤. តើព្រះសាស្តាﷺបានចូលរួមក្នុងគណៈកម្មាធិការណា ដើម្បីការពារសិទ្ធិមនុស្ស ?

៥. តាមអ្នកយល់ឃើញ ហេតុអ្វីព្រះសាស្តាﷺបានចូលរួមជាមួយគណៈកម្មាធិការនេះ ?

**មេរៀនទី ១២**

# សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها - ភាគ ១

សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها ជាព្រះមហេសីទីមួយរបស់ព្រះសាស្តា صلی الله علیه وآله وسلم និងជាព្រះមាតារបស់សៃយីដាស្ញ់ ហ្វាទីម៉ាស្ញ់ سلام الله علیها ។ ព្រះនាងប្រសូតនៅម៉ាក់កាស្ញ់ ។ បិតាព្រះនាងឈ្មោះ ឃូវ៉ៃលីដ្ង ប៊ិន អាសាដ្ង់ ជាឈ្មួញស្តុកស្តម្ភ ។

ពេលបិតាព្រះនាងស្លាប់ សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها ទទួលធុរកិច្ចនិងបន្តការចាត់បញ្ជូនក្បួនទូរចរជំនួញទៅប្រទេសស៊ីរីនិងប្រទេសយេមេន ។ ធុរកិច្ចជួញដូរបានរីកចម្រើននៅក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់ព្រះនាង سلام الله علیها ព្រះនាងបានយកកម្រៃដែលទទួលបានពីធុរកិច្ចនេះទៅជួយជនក្រីក្រ ស្ត្រីមេមាយ កូនកំព្រា ជនមានជម្ងឺនិងជនពិការ ។ បើមាននារីក្រីក្រ ព្រះនាងរៀបការឲ្យនារីនោះ ថែមទាំងបង់ប្រាក់ខាន់ស្លាឲ្យផង ។

សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها សុខចិត្តចាត់បញ្ជូនភ្នាក់ងារទៅតាមក្បួនទូរចរជំនួញជាងទៅដោយផ្ទាល់ខ្លួន ។ ព្រះនាង سلام الله علیها បានកម្រៃច្រើន ក្លាយទៅជាឈ្មួញមានស្តុកស្តម្ភជាច់គេនៃនគរម៉ាក់កាស្ញ់យ៉ាងឆាប់រហ័ស ។ ជំនួញព្រះនាង سلام الله علیها ធំជាងជំនួញរបស់ឈ្មួញឯទៀតរួមគ្នា ដោយសារជោគជ័យរបស់ព្រះនាង سلام الله علیها គេហៅព្រះនាងថា "អង្គម្ចាស់ក្សត្រីនៃនគរម៉ាក់កាស្ញ់" ។

ទោះបីពួកអារ៉ាប់ភាគច្រើនគោរពបូជារូបបដិមាជាព្រះក៏ដោយ តែមួយចំនួនទៀតបានបោះបង់ចោលទង្វើនេះមកជឿព្រះតែមួយគត់ ដូចព្រះសាស្តាអ៊ីបរ៉ហ៊ីម عليه السلام និងព្រះសាស្តាអ៊ីសម៉ាអ៊ីល عليه السلام បានបង្ហាត់បង្រៀន ។ ក្នុងចំណោមអ្នកបោះបង់ចោលទង្វើនេះមានម្នាក់ឈ្មោះ វ៉ារ៉កោះត៏ ប៊ិន ណៅហ្វាល់ (وَرَقَةُ بْنُ نَوْفَلٍ) បងប្អូនជីដូនមួយរបស់សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها ។ លោកធ្លាប់តែហាមគេកប់ទាំងរស់កូនស្រីឯងដែលជាទារកនៅឡើយ វាជាទង្វើសាមញ្ញក្នុងសម័យនោះ ។ លោកចាប់អារម្មណ៍គម្ពីរអ៊ិនយ៉ីលនិងគម្ពីរតៅរ៉ត្ត ។

សៃយីដាស្ញ់ ខ៉ទីយ៉ាស្ញ់ سلام الله علیها គោរពជំនឿឪពុកមាព្រះនាង سلام الله علیها ខ្លួនព្រះនាង سلام الله علیها ក៏គោរពបូជាព្រះតែមួយគត់ដែរ ។ ព្រះនាង سلام الله علیها ល្បីឈ្មោះជាស្ត្រីមានចិត្តសប្បុរស

គេហៅព្រះនាងسلام الله عليهاថា ត្ហ៏ហ៊ីរ៉ោះត៏ មានន័យថា "នារីបរិសុទ្ធ"។ កេរ្តិ៍ឈ្មោះព្រះនាងسلام الله عليهاល្បីសុសសាយ បុរសច្រើននាក់បានស្ដីដណ្ដឹងព្រះនាងسلام الله عليهاរៀបការ តែព្រះនាងបដិសេធបុរសទាំងអស់។

នានិទាឃៈរដូវ ឆ្នាំ ៥៩៥ នៃគ្រិស្តសករាជ ខណៈដែលគេត្រៀមក្បួនទូរចរជំនួញរដូវក្ដៅជាស្រេចដើម្បីចាកចេញពីម៉ាក់កាស្ហ៏ទៅកាន់ប្រទេសស៊ីរី សៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏سلام الله عليها ខ្វះភ្នាក់ងារដែលអាចទុកចិត្តបានម្នាក់ដើម្បីនាំក្បួនទូរចរព្រះនាងسلام الله عليها។ ក្នុងពេលតែមួយនេះដែរ អាប៊ូ ត៏លិប ព្យាយាមរកការឲ្យក្មួយធ្វើ គឺព្រះសាស្ដាصلى الله عليه وآله وسلمដែលមានព្រះជន្ម ២៥ ឆ្នាំ។ ពេលបានដំណឹងថាសៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏سلام الله عليها រកមនុស្សធ្វើការ លោកក៏បានទៅជួបព្រះនាងسلام الله عليها សូមឲ្យព្រះនាងយកក្មួយលោកធ្វើការនេះ។

ដូចអ្នកស្រុកម៉ាក់កាស្ហ៏ភាគច្រើនដែរ សៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏سلام الله عليهاបានឮគេនិយាយអំពីព្រះសាស្ដាصلى الله عليه وآله وسلم។ ព្រះអង្គصلى الله عليه وآله وسلمល្បីឈ្មោះថាជាមនុស្សគួរឲ្យទុកចិត្តបាន និងជាមនុស្សត្រង់។ ទោះបីព្រះអង្គصلى الله عليه وآله وسلمខ្វះបទពិសោធន៍ក៏ដោយ ព្រះនាងسلام الله عليهاព្រមយកព្រះអង្គصلى الله عليه وآله وسلمធ្វើការដោយឥតរួញរាបន្តិចឡើយ ដោយថាព្រះនាងسلام الله عليهاនឹងឲ្យបម្រើម្នាក់ឈ្មោះម៉ៃសារ៉ោះត៏ (مَيْسَرَةُ) ដែលធ្លាប់ធ្វើដំណើរទៅមកហើយនោះ ទៅជាមួយព្រះអង្គصلى الله عليه وآله وسلم។

ឆ្នាំនោះ ក្បួនទូរចរសៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏سلام الله عليهاទទួលបានកម្រៃច្រើនបំផុត។ ព្រះសាស្ដាصلى الله عليه وآله وسلمចេះមុខរបរជួញដូរយ៉ាងឆាប់។ នៅប្រទេសស៊ីរី ពួកឈ្មួញស្ញើចព្រះអង្គصلى الله عليه وآله وسلمដែលចេះតថ្លៃយ៉ាងឈ្លាសវៃតែត្រឹមត្រូវ។

ត្រឡប់មកម៉ាក់កាស្ហ៏វិញ ព្រះសាស្ដាصلى الله عليه وآله وسلمទៅជួបសៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏ មុនទៅផ្ទះ។ ម៉ៃសារ៉ោះត៏បានរាយការណ៍ប្រាប់ចៅហ្វាយស្រីអំពីការធ្វើដំណើរជួញដូរសព្វគ្រប់។ គាត់ស្ញើចចរិយាមារយាទព្រះសាស្ដាصلى الله عليه وآله وسلم ហើយកោតសរសើរចរិតនិងលក្ខណៈបុគ្គលព្រះអង្គصلى الله عليه وآله وسلمណាស់។

ហេតុដូច្នេះឯង កាល អាប៊ូ ត៏លិប បានឲ្យប្អូនស្រីលោកឈ្មោះ ស្វ៏ហ្វីយ៉ាស្ហ៏ ទៅស្ដីដណ្ដឹងសៃយីដ្ហាស្ហ៏ ខ៏ឌីយ៉ាស្ហ៏سلام الله عليها ឲ្យព្រះសាស្ដាصلى الله عليه وآله وسلم បានជាព្រះនាងسلام الله عليها យល់ព្រមភ្លាម ហើយក៏បានកំណត់ថ្ងៃអភិសេក។ អាប៊ូ ត៏លិប ជាអ្នកចាត់ការពិធីអភិសេកក្មួយជាទីស្រឡាញ់របស់លោកផ្ទាល់ដៃតែម្ដង។ ថ្ងៃអភិសេក លោកបាន

ឲ្យព្រះសាស្ដាﷺពាក់អាវធំរបស់ អាប៉ុឌុល-មុត្តត៉លិប ឲ្យព្រះអង្គﷺពាក់ចិញ្ចៀនរបស់ហាស៊ីម ។ អាប៊ូ ត៉លិប ជាអ្នកសូត្រឃុត្តបាស់អាពាហ៍ពិពាហ៍ក្រោយពីបានមូលមតិគ្នាអំពីប្រាក់ខាន់ស្លាតម្លៃ ៥០០ កាក់មាស ។ ពួកគូរ៉យស៊ បានធ្វើបុណ្យអាពាហ៍ពិពាហ៍យ៉ាងអធិកអធម ។

ក្រោយពិធីអភិសេក អាប៊ូ ត៉លិប បានធ្វើពិធីជុបលៀង ៣ ថ្ងៃ អ្នកស្រុកម៉ាក់កាស់គ្រប់គ្នាត្រូវអញ្ជើញចូលលៀង ។ គេហៅទង្វើនេះថា "វ៉ាលីម៉ាស់ (وَلِيمَة)" ក្រោយមកអ៊ីស្លាមបានតម្រូវឲ្យទង្វើនេះជាប៉ែកមួយនៃស៊ូណាត់ក្នុងពិធីរៀបការ ។

ព្រះសាស្ដាﷺមានព្រះជន្ម ២៥ ឆ្នាំ កាលព្រះអង្គﷺអភិសេកជាមួយសៃយីដាស់ ខ៊ូឌីយ៉ាស់سلام الله عليها ឯព្រះនាងسلام الله عليهاអាយុ ៤០ ឆ្នាំ ។

**ផ្គុងលំហាត់**

តាមយោបល់អ្នក ហេតុអ្វីសៃយីដាស់ខ៊ូឌីយ៉ាស់سلام الله عليهاព្រមរៀបការជាមួយព្រះសាស្ដា ﷺ ?

..........................................................................................................................

..........................................................................................................................

...........................................................................................................

***ពេលនេះអ្នកដឹង...***

- សៃយីដាស់ខ៊ូឌីយ៉ាស់سلام الله عليهاជាភរិយាដំបូងបង្អស់របស់ព្រះសាស្ដាﷺ ។
- ព្រះនាងسلام الله عليهاជាម្ចាស់ក្បួនទូរចរជំនួញ ដែលព្រះនាងបានធ្វើឲ្យរីកចម្រើន ។ កម្រៃដែលបានពីជំនួញនេះ ព្រះនាងយកទៅជួយជនក្រីក្រនិងជនមានជម្ងឺ ។
- ព្រះនាងسلام الله عليهاមិនធ្វើដំណើរផ្ទាល់ទេ ក្នុងការជួញដូរនៅប្រទេសស៊ីរីនិងប្រទេសយេមេន ព្រះនាងسلام الله عليهاឲ្យភ្នាក់ងារទៅជួញដូរជាជំនួស ។ ព្រះនាងسلام الله عليهاបានក្លាយទៅជាឈ្មួញស្រីដែលមានជាងគេនៃនគរម៉ាក់កាស់ ។ ក្បួនទូរចរជំនួញព្រះនាង

سلام الله عليها ធំជាងគេ ព្រោះតែបានទទួលជោគជ័យធំបានជាគេហៅព្រះនាង سلام الله عليها ថា "អង្គម្ចាស់ក្សត្រីនៃនគរម៉ាក់កាស្ញ" ។

- ផ្ទុយពីពួកអ្នកស្រុកម៉ាក់កាស្ញភាគច្រើន សៃយីដ្ញាស្ញខ្ញុំឌីយ៉ាស្ញ سلام الله عليها ជឿព្រះតែមួយគត់ ។ ព្រះនាង سلام الله عليها ប្រកបដោយសន្តានចិត្តល្អប្រពៃ គេតែងតែហៅព្រះនាង سلام الله عليها ថា ត៉ហ្វ៉ុរ៉ោះត៉ មានន័យថា នារីបរិសុទ្ធ ។
- កាលព្រះសាស្តា صلى الله عليه وآله وسلم មានព្រះជន្ម ២៥ ឆ្នាំ អាប៊ូ ត៉លិប បានស្វែងរកការឲ្យព្រះអង្គ صلى الله عليه وآله وسلم ធ្វើ ។ សៃយីដ្ញាស្ញខ្ញុំឌីយ៉ាស្ញ سلام الله عليها ខ្វះភ្នាក់ងារជាទីទុកចិត្តម្នាក់ដើម្បីនាំក្បួនទូរចរជំនួញរដូវក្តៅរបស់ព្រះនាង سلام الله عليها ។ អាប៊ូ ត៉លិប បានសូមឲ្យព្រះនាង سلام الله عليها យកក្មួយលោកធ្វើការ ។
- ព្រះនាង سلام الله عليها បានដឹងពួកេរ្តិ៍ឈ្មោះល្អរបស់ព្រះសាស្តា صلى الله عليه وآله وسلم ទោះបីព្រះអង្គ صلى الله عليه وآله وسلم ខ្វះការពិសោធន៍ក៏ដោយ ព្រះនាង سلام الله عليها មិនរារែកទទួលព្រះអង្គ صلى الله عليه وآله وسلم ធ្វើការទេ ។ ឆ្នាំនោះគេបានកម្រៃច្រើនលើសលន់ ។ ពេលម៉ៃសារ៉ោះត៉ បម្រើរបស់ព្រះនាង سلام الله عليها ត្រឡប់មកម៉ាក់កាស្ញវិញ គាត់បានកោតសរសើរចរិតនិងលក្ខណៈបុគ្គលរបស់ព្រះសាស្តា صلى الله عليه وآله وسلم ។
- ដូច្នេះឯង បានជាសៃយីដ្ញាស្ញខ្ញុំឌីយ៉ាស្ញ سلام الله عليها យល់ព្រមទទួលការស្តីដណ្តឹងរបស់ព្រះសាស្តា صلى الله عليه وآله وسلم ។ អាប៊ូ ត៉លិប ជាអ្នកចាត់ចែងពិធីអភិសេក ។ ថ្ងៃអភិសេក ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះជន្ម ២៥ ឆ្នាំ សៃយីដ្ញាស្ញខ្ញុំឌីយ៉ាស្ញ سلام الله عليها អាយុ ៤០ ឆ្នាំ ។

## មេរៀនទី ១៣

# សៃយីដាស់ ខ៏ឌីយ៉ាស់سلام الله عليها - ភាគ ២

អភិសេកជាមួយព្រះសាស្ដាﷺរួច សៃយីដាស់ ខ៏ឌីយ៉ាស់سلام الله عليها មិនសូវចាប់អារម្មណ៍ជំនួញដូចមុនៗទេ ព្រះនាងسلام الله عليهاសាងជីវិតថ្មីសុខសាន្តជាភរិយា ។ មុខរបរជំនួញរបស់ព្រះនាងسلام الله عليهاធំណាស់ មិនអាចបញ្ចប់ភ្លាមៗបានទេ ហេតុដូច្នេះព្រះនាងسلام الله عليهاបន្ថយការធ្វើជំនួញបន្តិចម្ដងៗ ។ ពីរបីឆ្នាំក្រោយមក ព្រះនាងسلام الله عليهاឈប់ធ្វើជំនួញ តែព្រះនាងسلام الله عليهاនៅតែមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ ។

សម្រាប់សៃយីដាស់ ខ៏ឌីយ៉ាស់سلام الله عليها បម្រើនិងធ្វើឲ្យស្វាមីសប្បាយចិត្តជាករណីយកិច្ចរបស់ព្រះនាងسلام الله عليها - ព្រះនាងسلام الله عليهاបំពេញកាតព្វកិច្ចនេះបានសម្រេចល្អប្រសើរ ។ គូស្វាមីភរិយាបានរួមរស់សុខសាន្តនិងមានបុត្រ ។

បុត្រដំបូងរបស់គូស្វាមីភរិយាឈ្មោះ ក៏ស៊ីម ។ ក៏ស៊ីម ប្រសូតរួចគេហៅព្រះសាស្ដាﷺថា អាប៊ុល-ក៏ស៊ីម មានន័យ ឪពុករបស់ក៏ស៊ីម តាមទម្លាប់អារ៉ាប់ ។ បុត្រទីពីរជាបុត្រប្រុសទៀត មាននាមថា អាប់ឌុលឡោះហ៍ គេហៅ ត៏ហ៊ៀរ និង ត៏យ៉យិប (طيب) ដែរ ។

បុត្រទាំងពីររស់ពុំបានយូរទេ បានស្លាប់តាំងពីនៅក្មេងខ្ចី ។ មរណៈភាពនេះធ្វើឲ្យព្រះសាស្ដាﷺសោកសៅអនេក ។ ពេលអ៊ីម៉ាំអាលីصلوات الله عليه والسلام ប្អូនជីតាមួយរបស់ព្រះអង្គﷺ ប្រសូត ព្រះសាស្ដាﷺបានយកព្រះអង្គﷺមកចិញ្ចឹមដូចកូនបង្កើត ។

ព្រះសាស្ដាﷺបានលះបង់ពេលវេលាច្រើននៅក្នុងគុហាហ៊ីរ៉អ៊ុ លើភ្នំមួយក្បែរម៉ាក់កាស់ ។ ព្រះអង្គﷺតាំងសមាធិផ្ដោតទៅអល់ឡោះហ៍عزّ وجلّនៅក្នុងគុហានេះ ព្រះអង្គعزّ وجلّកោតស្ញប់ស្ញែងសារពើដែលអល់ឡោះហ៍عزّ وجلّបានបង្កើតមក ។ ព្រះអង្គﷺគិតអំពីទង្វើនិងទម្លាប់អាក្រក់របស់ពួកអ្នកស្រុកម៉ាក់កាស់ដែរ ដែលធ្វើឲ្យព្រះអង្គﷺមានទោមនស្សអនេក ។ ជួនកាលព្រះអង្គﷺនៅក្នុងគុហាហ៊ីរ៉អ៊ុច្រើនថ្ងៃ ។ ដូច្នេះ សៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاយកបាយនិងទឹកមកឲ្យព្រះអង្គﷺ រៀបចំកន្លែងមិនឲ្យព្រះអង្គﷺលំបាកទេ ។

លុះអល់ឡោះហ៍عزّ وجلّបានឲ្យព្រះសាស្ដាﷺ ចាប់ផ្ដើមបំពេញបេសកកម្មសាស្ដា

ផ្សាយសាសនាអ៊ីស្លាម សៃយីដ្ហាស់ខ៊ូឌីយ៉ាស់ﷺជានារីដំបូងបង្អស់ដែលជឿព្រះរាជសារនិងទៅជានារីមុស្លីម ។

ព្រះនាងﷺបានបរិច្ចាគទ្រព្យទាំងអស់ ដើម្បីបម្រើផលប្រយោជន៍អ៊ីស្លាម ។ គេប្រើទ្រព្យព្រះនាងﷺសម្រាប់ទិញសិរីភាពពួកមុស្លីមដំបូង មុស្លីមភាគច្រើនជាមនុស្សបម្រើគេ ។ ក្រោយមក ទ្រព្យព្រះនាងﷺត្រូវចំណាយទៅលើការភៀសខ្លួនពួកមុស្លីមទៅឯដែនដីអាប៊ីស៊ីនី (ប្រទេសអេត្យូពី) ដើម្បីរួចផុតពីអំពើឃោរឃៅរបស់ពួកគួរ៉យស្ញ៍ ។

ក្នុងពេលដែលព្រះសាស្តាﷺបន្តការផ្សាយសាសនាអ៊ីស្លាម ពួកគួរ៉យស្ញ៍ច្រើនក្លាយទៅជាសត្រូវព្រះអង្គﷺ ។ ពួកគេជេរប្រមាថព្រះអង្គﷺ ។ ខ្លះហៅព្រះអង្គﷺថា "អាប់តារ៍" មានន័យថាសត្វកាត់កន្ទុយ ។ ពួកគេចង់និយាយសើកឲ្យថាព្រះសាស្តាﷺមិនមានកូនដែលអាចស្នងព្រះអង្គﷺ បន្តនាមត្រកូលព្រះអង្គﷺ ។

ការបន្តុះបង្អាប់នេះធ្វើឲ្យព្រះសាស្តាﷺសោកសៅ លុះអល់ឡោះហ៍ﷻបើកឲ្យដឹងនៅក្នុងស៊ូរ៉ោះត៍ អាល់-កៅស៊្សារ ថា៖

بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ

إِنَّآ أَعْطَيْنَٰكَ ٱلْكَوْثَرَ ① فَصَلِّ لِرَبِّكَ وَٱنْحَرْ ② إِنَّ شَانِئَكَ هُوَ ٱلْأَبْتَرُ ③

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*១. ពិតណាស់ យើងបានប្រទានអាល់-កៅស៊្សារឲ្យអ្នក ។ ២. ដូច្នេះចូរអ្នកធ្វើនមស្ការបូជាព្រះម្ចាស់អ្នកនិងធ្វើពលិកម្ម ។ ៣. ពិតណាស់ សត្រូវរបស់អ្នកជាមនុស្សដាច់ពូជ ។*(១០៨:១-៣)

នៅក្នុងអាយ៉ាស់នេះ អល់ឡោះហ៍ﷻបានសន្យាព្រះសាស្តាﷺថាព្រះអង្គﷺនឹងមិនអត់បណ្តាកូនចៅទេ ក្រោយមកបន្តិចកូនពៅគេរបស់ព្រះអង្គﷺបានចាប់កំណើត ។ នេះគឺកូនស្រី ព្រះអង្គﷺដាក់ឈ្មោះឲ្យថា ហ្វាទីម៉ាស់ ស្ហាស់រ៉អ៍ ។ សៃយីដ្ហាស់ ហ្វាទីម៉ាស់ﷺ ជាព្រះមាតារបស់ព្រះសន្តអ៊ីមុាំរបស់យើងﷺ ។

សព្វថ្ងៃនេះ បណ្តាកូនចៅរបស់ព្រះសាស្តាﷺរស់នៅទូទាំងពិភពលោក គេហៅអភិជនទាំងនេះថា សៃយីដ្ហ ។ គេអាចស្គាល់អភិជនទាំងនេះបានអាស្រ័យឈ្នួតក្បាលខ្មៅឬបៃតង ។

តែគេមិនដែលឃើញអ្នកណាមួយប្រកាសខ្លួនថាជាកូនចៅរបស់ អាប៊ូ យ៉ាហ្វាល់ ឬសត្រូវឯទៀតណាមួយរបស់ព្រះសាស្ដាﷺទេ នេះដោយសារសន្យារបស់អល់ឡោះហ្ទ៍عزّ وجلّខាងលើនេះ កាលព្រះអង្គعزّ وجلّមានព្រះបន្ទូលថា៖ "សត្រូវរបស់អ្នកជាមនុស្សដាច់ពូជ ។"

សៃយីដាស់ខ៌ុឌីយ៉ាស់سلام الله عليهاបានរៀបការជាមួយព្រះសាស្ដាﷺ ២៥ ឆ្នាំ ។ ព្រះនាងسلام الله عليهاសោយទិវង្គតថ្ងៃទី ១០ ខែរ៉ម៉ាដន ១០ ឆ្នាំបន្ទាប់ពីអល់ឡោះហ្ទ៍عزّ وجلّឲ្យព្រះសាស្ដាﷺបំពេញបេសកកម្មសាស្ដា ៣ ឆ្នាំមុនសករាជហ៊ិជរ៉ោះត៍ ។ សពព្រះនាងسلام الله عليهاត្រូវបញ្ចុះនៅឯម៉ាក់កាស់ ។ ក្នុងឆ្នាំតែមួយ ព្រះសាស្ដាﷺបានបាត់បង់ អាប៊ូត៍លិប ឪពុកធំព្រះអង្គﷺ ។ សោកសៅដោយសារមរណៈកម្មទាំងពីរនេះ ព្រះអង្គﷺហៅឆ្នាំនេះថា "អាមុល-ហ៊ុស្សនី" ឆ្នាំសោកសង្រេង ។

កាលសៃយីដាស់ខ៌ុឌីយ៉ាស់سلام الله عليهاនៅរស់ ព្រះសាស្ដាﷺមិនរៀបការភរិយាផ្សេងទេ ។ ព្រះអង្គﷺបានថាព្រះនាងسلام الله عليهاជាភរិយាប្រសើរលើសអស់ភរិយា ។

ព្រះសាស្ដាﷺបានថា សៃយីដាស់ខ៌ុឌីយ៉ាស់سلام الله عليهاជាស្ត្រីសុក្រឹតឥតខ្ចោះម្នាក់ក្នុងចំណោមស្ត្រីសុក្រឹតឥតខ្ចោះទាំងបួននៅលើផែនដី ។ ស្ត្រីសុក្រឹតឥតខ្ចោះបីនាក់ទៀតគឺ សៃយីដាស់អាស៊ីយ៉ាស់سلام الله عليها មហេសីរបស់ ហ្វៀរអៅន៍لعنه الله, សៃយីដាស់ម៉ារយ៉ាំسلام الله عليها ព្រះមាតារបស់ព្រះសាស្ដាអ៊ីសាعليه السلام, សៃយីដាស់ហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ុسلام الله عليها ។

**_ពេលនេះអ្នកដឹង..._**

- រៀបការរួច សៃយីដាស់ខ៌ុឌីយ៉ាស់سلام الله عليهاមិនសូវចាប់អារម្មណ៍ជំនួញដូចមុនៗទេ លែងធ្វើជំនួញបន្តិចម្ដងៗ ។ សម្រាប់ព្រះនាងسلام الله عليها បម្រើស្វាមីជាកាតព្វកិច្ច ។
- គូស្វាមីភរិយាបានកូនប្រុសពីរនាក់ឈ្មោះ កាំស៊ីម និង អាប់ឌុលឡោះហ្ទ៍ ។ អកុសល កូនប្រុសទាំងពីរបានស្លាប់កាលនៅក្មេងខ្ចី ។ ហេតុដូច្នេះ កាលអ៊ីម៉ាំអាលីصلوات الله عليه والسلامកើត ព្រះសាស្ដាﷺយកព្រះអង្គصلوات الله عليه والسلامមកចិញ្ចឹមដូចកូនបង្កើត ។
- កាលអល់ឡោះហ្ទ៍عزّ وجلّឲ្យព្រះសាស្ដាﷺប្រកាសសាសនាអ៊ីស្លាម សៃយីដាស់ខ៌ុឌីយ៉ាស់سلام الله عليهاជានារីដំបូងបង្អស់ដែលទៅជានារីមុស្លីម ។ ព្រះនាងسلام الله عليهاបរិច្ចាគ

ទ្រព្យទាំងអស់ដើម្បីផលប្រយោជន៍អ៊ីស្លាម ។

- កាលព្រះសាស្តាصلى الله عليه وآله وسلمផ្សាយសាសនាអ៊ីស្លាម ពួកគូរ៉យ់ស្ហ៍ជេរប្រមាថព្រះអង្គصلى الله عليه وآله وسلم ហៅព្រះអង្គصلى الله عليه وآله وسلمថា "អាប់តារ៍" មានន័យសត្វដាច់កន្ទុយ ដោយចង់និយាយសំដៅឲ្យថាព្រះអង្គصلى الله عليه وآله وسلمមិនមានកូនដើម្បីស្នងព្រះអង្គصلى الله عليه وآله وسلم ។ ដើម្បីលួងចិត្តព្រះអង្គصلى الله عليه وآله وسلم អល់ឡោះហ្ទ៍عز وجلបានដាក់មកនូវស៊ូរ៉ោះត៍ អាល់-កៅស៊ារ ។
- អល់ឡោះហ្ទ៍عز وجلបានសន្យាថាព្រះអង្គصلى الله عليه وآله وسلمនឹងពុំឥតមានកូននោះទេ សៃយីដាស់ខ៊ីឌីយ៉ាស់سلام الله عليهاក៏បានប្រសូតបុត្រីឈ្មោះ ហ្វាទីម៉ាស់ ស្ហាស់រ៉អ៍ ។ ព្រះរាជបុត្រីនេះជាព្រះមាតារបស់អ៊ីម៉ាំយើងعليهم السلام គេហៅបណ្តាព្រះរាជបុត្ររាជនត្តារបស់ព្រះនាងسلام الله عليهاដែលនៅទូទាំងពិភពលោកថា សៃយីដ ។
- តែពុំមានអ្នកណាប្រកាសខ្លួនថាជាបណ្តាកូនចៅរបស់ អាប៊ូ យ៉ាហាល់ ឬសត្រូវឯទៀតណាមួយរបស់ព្រះសាស្តាصلى الله عليه وآله وسلمទេ ព្រោះអល់ឡោះហ្ទ៍عز وجلមានព្រះបន្ទូលថា៖ "សត្រូវរបស់អ្នកជាមនុស្សដាច់ពូជ ។"
- ក្រោយពីរៀបការបាន ២៥ ឆ្នាំ សៃយីដាស់ខ៊ីឌីយ៉ាស់سلام الله عليهاសោយទិវង្គត ។ អាប៊ូត៍លិប សោយទិវង្គតក្នុងឆ្នាំតែមួយដែរ ។ ព្រះសាស្តាصلى الله عليه وآله وسلمហៅឆ្នាំនេះថា "អាមុល-ហ៊ុស្ន៍នី" ឆ្នាំសោកសង្រេង ។

# លំហាត់មេរៀនសាឡើងវិញ ៤

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីគេហៅសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاថា "អង្គម្ចាស់ក្សត្រីនៃនគរម៉ាក់កាស់" ?

២. សៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاគោរពជំនឿឪពុកមាព្រះនាងسلام الله عليها តើជំនឿនោះគឺអ្វី ?

៣. ព្រះសាស្តាﷺធ្វើការអ្វីឲ្យសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليها ?

៤. អ្នកណាសូត្រឃុត្តបាស់អាពាហ៍ពិពាហ៍ព្រះសាស្តាﷺ និងសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليها ?

៥. តើព្រះសាស្តាﷺនិងសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاអាយុប៉ុន្មាន កាលរៀបអាពាហ៍ពិពាហ៍ ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاលែងចាប់អារម្មណ៍ជំនួញបន្តិចម្តងៗ ?

២. កូនប្រុសទាំងពីររបស់ព្រះសាស្តាﷺ និងសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاឈ្មោះអ្វី ? កូនទាំងពីរនេះកើតអ្វី ?

៣. ពួកសត្រូវរបស់ព្រះសាស្តាﷺហៅឈ្មោះព្រះអង្គﷺថាអ្វី ?

៤. ស៊ូរ៉ោះត៍អ្វីត្រូវបើកឲ្យដឹងជាចម្លើយﷺតបការហៅឈ្មោះនោះ ? ចូរពន្យល់ថា តើអល់ឡោះហ៍عزوجلគោរពសន្យាព្រះអង្គﷺដូចម្តេច ដែលព្រះអង្គعزوجلបានសន្យាព្រះសាស្តាﷺនៅក្នុងស៊ូរ៉ោះត៍នោះ ?

៥. តើសៃយីដាស់ខ៏ឌីយ៉ាស់سلام الله عليهاសោយទិវង្គតកាលណា អ្នកណាសោយទិវង្គតឆ្នាំតែមួយនោះដែរ ?

## មេរៀនទី ១៤

# ព្រះសាស្តា អាដាំ عليه السلام - ភាគ ១

ព្រះសាស្តាអាដាំ عليه السلام ជាមនុស្សទីមួយបង្អស់ដែលត្រូវបង្កើតមក ។ បន្ទាប់ពីបានបង្កើតដី មេឃ ថ្ងៃនិងខែ អល់ឡោះហ្ទ៍ عز وجل បានបង្កើតទេវតានិងយ៉ិន ។ ទីបំផុតព្រះអង្គ عز وجل បានបង្កើតព្រះសាស្តាអាដាំ عليه السلام និងសៃយីដាហ្ស៊ូហាវ៉ាអ៊ុ سلام الله عليها ។

កាលអល់ឡោះហ្ទ៍ عز وجل បានប្រាប់អស់ទេវតាថា ព្រះអង្គ عز وجل នឹងបង្កើតសត្វលោកថ្មីមួយដែលនឹងនៅលើផែនដី អស់ទេវតាឆ្ងល់ ទូលថា៖ "អល់ឡោះហ្ទ៍ عز وجل អើយ ហេតុអ្វីបង្កើតសត្វលោកឯទៀត អស់ទូលព្រះបង្គំជាខ្ញុំគោរពសក្ការៈព្រះអង្គ عز وجل ស្រាប់ហើយ អស់ទូលព្រះបង្គំជាខ្ញុំថ្វាយសេចក្តីគោរពព្រះនាមព្រះអង្គ عز وجل មិនលែង ? អស់សត្វលោកទាំងនោះនឹងវាយគ្នាដណ្តើមអំណោយផលផែនដី ពួកគេនឹងសម្លាប់គ្នា ។" អស់ទេវតាថាដូច្នេះព្រោះធ្លាប់បានឃើញពួកយ៉ិនធ្វើបែបនេះនៅឯផែនដី ។ តែយ៉ិនខ្លះជឿស៊ប់ចិត្ត អាស្សាស៊ីល (عزازيل) និង អ៊ីប្លីស (إبليس) គោរពបូជាអល់ឡោះហ្ទ៍ عز وجل ជាមួយពួកទេវតា ។

អល់ឡោះហ្ទ៍ عز وجل បានឲ្យចម្លើយដែលធ្វើឲ្យអស់ទេវតាពេញចិត្ត ។ ព្រះអង្គ عز وجل មានព្រះបន្ទូលថា៖ "អញ عز وجل ដឹងអ្វីដែលពួកអ្នកមិនដឹង ។ សត្វលោកដែលអញ عز وجل នឹងបង្កើតនោះជាតំណាងអញ عز وجل នៅឯផែនដី ។ កូនចៅរបស់គេនឹងនៅពេញផែនដីនឹងបរិភោគសារពើរដែលដុះនៅលើនោះ ។ បន្ទាប់ពីបានបង្កើតគេហើយ អញ عز وجل នឹងឲ្យគេមានជីវិត ពួកអ្នកនឹងក្រាបប្រណិប័តន៍គេ ។"

អល់ឡោះហ្ទ៍ عز وجل បង្កើតខ្លួនអាដាំ عليه السلام ពីដីពិសេស បន្ទាប់មកឲ្យព្រះអង្គ عليه السلام មានជីវិតកើតជាមនុស្សសុក្រឹត ។ អល់ឡោះហ្ទ៍ عز وجل បានឲ្យអស់ទេវតាក្រាបប្រណិប័តន៍ព្រះសាស្តាអាដាំ عليه السلام ។ អស់ទេវតាធ្វើតាមព្រះរាជបង្គាប់ភ្លាម សម្តែងសេចក្តីគោរពចំពោះព្រះសាស្តាអាដាំ عليه السلام ។ តែអ៊ីប្លីស (ស្ទៃត្អូន لعنه الله) មិនព្រមក្រាបប្រណិប័តន៍ទេ ។

អល់ឡោះហ្ទ៍ عز وجل សួរស្ទៃត្អូន لعنه الله ថា ហេតុអ្វីវា لعنه الله ល្មើសព្រះរាជបញ្ជាព្រះអង្គ عز وجل ។ ស្ទៃត្អូន لعنه الله បានទូលថាវា لعنه الله ត្រូវបង្កើតមកពីភ្លើង វា لعنه الله ប្រសើរជាងព្រះសាស្តាអាដាំ عليه السلام

ដែលត្រូវបង្កើតមកពីដី ។ ដូច្នេះវាلعنه اللهបានល្មើសព្រះរាជបញ្ជាអល់ឡោះហ្ទ៍ﷻដោយចេតនាព្រោះតែវាلعنه اللهប្រកាន់ខ្លួនពេក ។

អល់ឡោះហ្ទ៍ﷻមិនសប្បាយព្រះហឫទ័យ អំពីការប្រព្រឹត្តល្មើសរបស់ស្ហៃតនلعنه اللهទេ ព្រះអង្គﷻមានព្រះរាជបន្ទូលថា៖ "ចេញពីឋានសួគ៌ទៅ ។ ឯងلعنه اللهត្រូវបណ្ដាសារហូតដល់ថ្ងៃជំនុំជម្រះ ។ ស្ហៃតនلعنه اللهបានសូមឲ្យរស់រហូតដល់ថ្ងៃនោះ អល់ឡោះហ្ទ៍ﷻបានបំពេញបំណងវាلعنه الله ។

ស្ហៃតនلعنه اللهគួរតែអរព្រះគុណអល់ឡោះហ្ទ៍ﷻ តែវាلعنه اللهបែរជាសន្យាថាវាلعنه اللهនឹងព្យាយាមធ្វើឲ្យព្រះសាស្ដាអាដាំعليه السلام និងបណ្ដាកូនចៅព្រះអង្គعليه السلامវង្វេងចេញពីផ្លូវល្អ ។ អល់ឡោះហ្ទ៍ﷻបានប្រាប់វាلعنه اللهវិញថាវាلعنه اللهមិនអាចធ្វើឲ្យមុស្លីមពិតប្រាកដវង្វេងផ្លូវបានទេ ។

ព្រះសាស្ដាអាដាំعليه السلامនិងសៃយីដាស់ហាវ៉ាអ៍عليها السلام បានរស់នៅសុខសាន្តក្នុងឋានសួគ៌អាស្រ័យព្រះគុណអល់ឡោះហ្ទ៍ﷻ ។ ព្រះអង្គទាំងពីរعليهم السلامមានគ្រប់សព្វ ចង់បានអ្វីបានហ្នឹង រួមរស់ដោយសុភមង្គល ។

## ផ្ទុងលំហាត់

នៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អល់ឡោះហ្ទ៍ﷻថែងអំពីអ៊ីប្លីសلعنه اللهដែលមិនព្រមក្រាបប្រណិប័តន៍ព្រះសាស្ដាអាដាំعليه السلام ។ ចូរអ្នកសរសេរសម្រាយអាយ៉ាស់ស៊ូរ៉ោះត៍នេះដែលស្ដីអំពីរឿងនេះ ។

.....................................................................................................................

.....................................................................................................................

..............................................................................................

## *ពេលនេះអ្នកដឹង...*

- បន្ទាប់ពីបានបង្កើតមេឃនិងដី អល់ឡោះហ្ទ៍ﷻបានបង្កើតព្រះសាស្ដាអាដាំعليه السلام

និងសៃយីដ្ហាស់ហ្វាវ៉ាអ៊ុ سلام الله عليها ។

- ពេលអស់ទេវតាដឹងថាអល់ឡោះហ្ទ៍ عز وجل នឹងបង្កើតសត្វលោកថ្មីមួយ ពួកគេឆ្ងល់សួរអល់ឡោះហ្ទ៍ عز وجل ថាហេតុអ្វីព្រះអង្គ عز وجل បង្កើតសត្វលោកច្រើនទៀត ពួកគេគោរពបូជាព្រះអង្គ عز وجل ស្រាប់ហើយ ឯសត្វលោកថ្មីទាំងនោះនឹងពូកែតែវាយគ្នាប៉ុណ្ណោះ ។
- អល់ឡោះហ្ទ៍ عز وجل មានព្រះបន្ទូលថាព្រះអង្គ عز وجل ដឹងអ្វីដែលអស់ទេវតាមិនដឹង ថាព្រះអង្គ عز وجل នឹងឲ្យសត្វលោកថ្មីរបស់ព្រះអង្គ عز وجل នោះទៅជាតំណាងព្រះអង្គ عز وجل នៅឯផែនដី ។
- អល់ឡោះហ្ទ៍ عز وجل បានបង្កើតព្រះសាស្តាអាដាំ عليه السلام ពីដីពិសេស ព្រះអង្គ عز وجل ប្រទានជីវិតឲ្យព្រះសាស្តាអាដាំ عليه السلام ។ បន្ទាប់មកព្រះអង្គ عز وجل ដាក់ព្រះបញ្ជាឲ្យអស់ទេវតាក្រាបប្រណិប័តន៍ព្រះសាស្តាអាដាំ عليه السلام ។ អស់ទេវតាធ្វើតាមព្រះបញ្ជាអល់ឡោះហ្ទ៍ عز وجل ភ្លាម លើកលែងតែអ៊ីប្លីស لعنه الله មួយទេដែលមិនព្រមក្រាបប្រណិប័តន៍ ។ វា لعنه الله បានប្រាប់អល់ឡោះហ្ទ៍ عز وجل ថាវា لعنه الله ត្រូវបង្កើតមកពីភ្លើង ថាវា لعنه الله គ្រាន់បើជាងព្រះសាស្តាអាដាំ عليه السلام ដែលត្រូវបង្កើតមកពីដី ។
- អល់ឡោះហ្ទ៍ عز وجل ទ្រង់ព្រះពិរោធអ៊ីប្លីស لعنه الله (ស្ហៃតូន لعنه الله) បណ្តេញវា لعنه الله ចេញពីឋានសួគ៌ដាក់បណ្តាសាវា لعنه الله រហូតដល់ថ្ងៃជំនុំជម្រះ ។ សៃតូន لعنه الله សូមឲ្យរស់រហូតដល់ថ្ងៃនោះ អល់ឡោះហ្ទ៍ عز وجل យល់ព្រម ។ ស្ហៃតូន لعنه الله សន្យាថានឹងធ្វើឲ្យព្រះសាស្តាអាដាំ عليه السلام និងបណ្តាកូនចៅព្រះអង្គ عليه السلام ឃ្លាតចេញពីផ្លូវល្អ ។ តែអល់ឡោះហ្ទ៍ عز وجل បានប្រាប់វា لعنه الله ថាវា لعنه الله មិនអាចធ្វើឲ្យមុស្លីមពិតប្រាកដឃ្លាតចេញពីផ្លូវល្អបានទេ ។
- ព្រះសាស្តាអាដាំ عليه السلام និងសៃយីដ្ហាស់ហ្វាវ៉ាអ៊ុ سلام الله عليها រស់នៅក្នុងឋានសួគ៌ ដោយសេចក្តីសុខអាស្រ័យព្រះគុណអល់ឡោះហ្ទ៍ عز وجل ។

**មេរៀនទី ១៥**

# ព្រះសាស្តា អាដាំعليه السلام - ភាគ ២

កាលអល់ឡោះហ្ស៍عز وجلឲ្យព្រះសាស្តាអាដាំعليه السلام និងសៃយីដាស់ហាវ៉ាអ៊ុំعليها السلامរស់នៅក្នុងឋានសួគ៌ ព្រះអង្គعز وجلអនុញ្ញាតឲ្យព្រះអង្គទាំងពីរعليهما السلامធ្វើអ្វីបានតាមចិត្ត លើកលែងតែប្រការមួយគឺ ព្រះអង្គعز وجلបានប្រាប់កុំឲ្យព្រះអង្គទាំងពីរعليهما السلامទៅក្បែរដើមឈើសួគ៌មួយនិងកុំឲ្យសោយផ្លែវា ។

ស្ហៃតនلعنه اللهមិនអាចទ្រាំមើលព្រះសាស្តាអាដាំعليه السلام និងសៃយីដាស់ហាវ៉ាអ៊ុំعليها السلامមានសុភមង្គលបានទេ ។ វាلعنه اللهប្រទេចផ្តាសាព្រះសាស្តាអាដាំعليه السلامនិងសៃយីដាស់ហាវ៉ាអ៊ុំعليها السلام ចង់សងសឹក ។ ព្រោះតែច្រណែន វាلعنه اللهចង់ទាក់ទាញព្រះសាស្តាអាដាំعليه السلامឲ្យធ្វើទង្វើអាក្រក់ ។

ទោះបីគេមិនអនុញ្ញាតឲ្យស្ហៃតនلعنه اللهនៅក្នុងឋានសួគ៌ក៏ដោយ វាلعنه اللهតែងតែទៅលេងឋានសួគ៌មិនខាន ។ ថ្ងៃមួយ ស្ហៃតនلعنه اللهចូលទៅក្នុងឋានសួគ៌ និយាយជាមួយព្រះសាស្តាអាដាំعليه السلام ។ វាلعنه اللهថាវាلعنه اللهជាមិត្តរបស់ព្រះអង្គعليه السلام លុះវាلعنه اللهបានសម្រេចក្នុងការធ្វើឲ្យព្រះសាស្តាអាដាំعليه السلامជឿជាក់ ថាវាلعنه اللهមិនមានបំណងអាក្រក់ចំពោះព្រះអង្គعليه السلامទេ វាلعنه اللهបានថា៖ "អ្នកعليه السلامដឹងទេថាគេឲ្យអ្នកនៅឆ្ងាយពីអ្វីដែលល្អប្រសើរក្នុងឋានសួគ៌ ? បើអ្នកعليه السلامបរិភោគផ្លែរបស់ដើមឈើនេះ អ្នកعليه السلامនឹងបាននៅក្នុងឋានសួគ៌រហូត អ្នកعليه السلامអាចក្លាយទៅជាទេវតាទៀតផង ។"

ពេលព្រះសាស្តាអាដាំعليه السلامនិងសៃយីដាស់ហាវ៉ាអ៊ុំعليها السلامបានឮសម្តីនេះ ព្រះអង្គទាំងពីរعليهما السلامនឹកឃើញបណ្តាំរបស់អល់ឡោះហ្ស៍عز وجلឲ្យនៅឆ្ងាយពីដើមឈើនេះ ព្រះអង្គទាំងពីរعليهما السلامខ្លាច ។ តែស្ហៃតនلعنه اللهឆ្លាតណាស់ វាلعنه اللهបានស្បថក្នុងព្រះនាមអល់ឡោះហ្ស៍عز وجلថាវាلعنه اللهជាមិត្តរបស់ព្រះអង្គទាំងពីរعليهما السلام ថាវាلعنه اللهមិនប្រាប់ព្រះអង្គទាំងពីរعليهما السلامនូវអ្វីដែលមានគ្រោះថ្នាក់ដល់ព្រះអង្គទាំងពីរعليهما السلامទេ ។

ព្រះសាស្តាអាដាំعليه السلامនិងសៃយីដាស់ហាវ៉ាអ៊ុំعليها السلام មិនដែលឮគេនិយាយកុហកសោះកាលពីមុនមក និងព្រោះតែស្ហៃតនلعنه اللهស្បថក្នុងព្រះនាមអល់ឡោះហ្ស៍عز وجلបានជាព្រះអង្គទាំងពីរعليهما السلامជឿវាلعنه الله ។ ដំបូង វាلعنه اللهបានប្រាប់ឲ្យព្រះអង្គទាំងពីរعليهما السلامហិត

ក្លិនផ្អែមរបស់ដើមឈើនោះ ពិនិត្យមើលពណ៌អស្ចារ្យរបស់វា ។ ទីបំផុត វាلعنه اللهបាន ជម្រុញព្រះអង្គទាំងពីរعليهم السلامឲ្យល្មើសបង្គាប់អល់ឡោះហ៊្វعز وجل បរិភោគផ្លែដើមឈើ នោះ ។

នេះគឺកំហុសរបស់ព្រះសាស្តាអាដ្វាំعليه السلامនិងសៃយីដ្វាស៊ុហាវ៉ាសلام الله عليها កំហុស ដែលព្រះអង្គទាំងពីរعليهم السلامស្តាយក្រោយខ្លាំងណាស់ ។

អល់ឡោះហ៊្វعز وجلបានប្រាប់ព្រះអង្គទាំងពីរعليهم السلامថា៖ "តើអញعز وجلមិនបានប្រាប់ពួក អ្នកعليهم السلامហើយទេថាកុំឲ្យទៅជិតដើមឈើនោះ ថាស្ហៃតនលعنه اللهជាសត្រូវរបស់ពួកអ្នក عليهم السلام?" ព្រះអង្គទាំងពីរعليهم السلامទូលអល់ឡោះហ៊្វعز وجلថាព្រះអង្គទាំងពីរعليهم السلامសោកស្តាយ ណាស់ ហើយអង្វរសូមឲ្យអល់ឡោះហ៊្វعز وجلលើកទោសឲ្យព្រះអង្គទាំងពីរعليهم السلام ។ តែ អល់ឡោះហ៊្វعز وجلមានព្រះបន្ទូលថា៖ "ចូរអ្នកទាំងពីរعليهم السلامចេញពីឋានសួគ៌ទៅ ។ ពេល នេះ អ្នកទាំងពីរعليهم السلامនឹងនៅលើផែនដី ។ ចាប់ពីពេលនេះតទៅ ជីវិតសុខសាន្តរបស់ អ្នកទាំងពីរعليهم السلامត្រូវចប់ ពួកអ្នកعليهم السلامនឹងត្រូវធ្វើការដើម្បីចិញ្ចឹមជីវិតពួកអ្នកعليهم السلامនិង គ្រួសារពួកអ្នកعليهم السلام ។"

ព្រះសាស្តាអាដ្វាំعليه السلامនិងសៃយីដ្វាស៊ុហាវ៉ាسلام الله عليها មកកាន់ឋានក្រោមនេះ ដូច្នេះឯង ។ ព្រះអង្គទាំងពីរعليهم السلامបានមកស្នាក់នៅឯកន្លែងមួយហៅថា អាុដាន់ (عَدَن) ។ ដំបូង ព្រះអង្គទាំងពីរعليهم السلامស្អប់កន្លែងនេះ ចង់ត្រឡប់ទៅឋានសួគ៌វិញ ។ ព្រះ អង្គទាំងពីរعليهم السلامយំអង្វរសូមខមាទោសអល់ឡោះហ៊្វعز وجل សុំព្រះអង្គعز وجلត្រឡប់ទៅវិញ ។ ក្រោយមក អល់ឡោះហ៊្វعز وجلបានលើកលែងកំហុសឲ្យព្រះអង្គទាំងពីរعليهم السلام តែព្រះអង្គ عز وجلបានប្រាប់ថាពេលនេះ ព្រះអង្គទាំងពីរعليهم السلامត្រូវតែខិតខំចាប់កន្លែងខ្លួនឯងនៅក្នុង ឋានសួគ៌ដោយទង្វើ ។ អល់ឡោះហ៊្វعز وجلបានប្រាប់ថាមានផ្លូវពីរក្នុងជីវិត ។ ផ្លូវមួយ តម្រូវឲ្យអនុវត្តិតាមព្រះបញ្ញារបស់អល់ឡោះហ៊្វعز وجل វានឹងនាំទៅរកសុភមង្គលនិង ឋានសួគ៌ ឯផ្លូវមួយទៀតគឺផ្លូវពួកសាងបាបកម្មដែលនាំទៅរកទុក្ខលំបាកនិងឋាន នរក ។ ព្រះអង្គعز وجلបានប្រាប់ព្រះអង្គទាំងពីរعليهم السلامថាស្ហៃតនលعنه اللهនឹងព្យាយាមទាក់ទាញ ព្រះអង្គទាំងពីរعليهم السلامនិងបណ្តាកូនចៅព្រះអង្គទាំងពីរعليهم السلامឲ្យយកផ្លូវទីពីរ ថាស្ហៃតនលعنه الله ជាសត្រូវចេញមុខរបស់ព្រះអង្គទាំងពីរعليهم السلام ។

ព្រះសាស្តាអាដ្វាំعليه السلامនិងសៃយីដ្វាស៊ុហាវ៉ាسلام الله عليها សមនឹងជីវិតថ្មីបន្តិចម្តងៗ អល់ឡោះហ៊្វعز وجلបានព្រះរាជទានកូនៗឲ្យព្រះអង្គទាំងពីរعليهم السلام ធ្វើឲ្យព្រះអង្គទាំងពីរ

عليهم السلامមានសេចក្តីសុខ ។ សៃយីដាស់ហាវ៉ាអ៊ុسلام الله عليهاបានសម្រាលកូនភ្លោះពីរគូ ក្វ៉ាប៊ិល (قابيل) និងប្អូនស្រីកើតមុន ហាប៊ិល (هابيل) និងប្អូនស្រីកើតពីរបីឆ្នាំក្រោយមក ។

ព្រះសាស្តាអាដាំعَلَيْهِ السَّلَامនិងសៃយីដាស់ហាវ៉ាអ៊ុسلام الله عليهاស្រឡាញ់កូនណាស់ ព្រះអង្គទាំងពីរعليهم السلامសប្បាយចិត្តដែលឃើញកូនធំដោយមានសុខភាពល្អ ។ ពេលកូនៗពេញវ័យគ្រប់ការ អល់ឡោះហ្ម៉ុعز وجلបានចាត់បញ្ជូនស្ត្រីពីរនាក់មកពីលើមេឃដើម្បីឲ្យរៀបការជាមួយក្វ៉ាប៊ិលនិងហាប៊ិល ។

បណ្តាកូនស្រីជួយធ្វើការសៃយីដាស់ហាវ៉ាអ៊ុسلام الله عليها ក្វ៉ាប៊ិលជាកសិករដាំដំណាំចំណែកឯហាប៊ិលចិញ្ចឹមសត្វ ។ បងប្អូនទាំងពីរស្រឡាញ់គ្នា គ្រួសារព្រះសាស្តាអាដាំعَلَيْهِ السَّلَامនិងសៃយីដាស់ហាវ៉ាអ៊ុسلام الله عليهاរស់នៅសុខសាន្ត ។

## *ពេលនេះអ្នកដឹង...*

- កាលអល់ឡោះហ្ម៉ុعز وجلឲ្យព្រះសាស្តាអាដាំعَلَيْهِ السَّلَام និងព្រះនាងហាវ៉ាអ៊ុسلام الله عليهاរស់នៅក្នុងឋានសួគ៌ ព្រះអង្គទាំងពីរعليهم السلامអាចធ្វើអ្វីបានតាមចិត្តលើកលែងតែបរិភោគផ្លែរបស់ដើមឈើមួយជាពិសេស ។
- ស្ហៃតនលعنه اللهប្រទេចផ្តាសាព្រះសាស្តាអាដាំعَلَيْهِ السَّلَامនិងព្រះនាងហាវ៉ាអ៊ុسلام الله عليها ចង់សងសឹក ។ ថ្ងៃមួយវាلعنه اللهបានចូលទៅក្នុងឋានសួគ៌ ថាវាلعنه اللهជាមិត្តរបស់ព្រះសាស្តាអាដាំعَلَيْهِ السَّلَام ។ វាلعنه اللهបានសាកជម្រុញព្រះសាស្តាអាដាំعَلَيْهِ السَّلَامឲ្យបរិភោគផ្លែឈើហាម ។ តែព្រះសាស្តាអាដាំعَلَيْهِ السَّلَامនិងព្រះនាងហាវ៉ាអ៊ុسلام الله عليها បាននឹកឃើញបម្រាមអល់ឡោះហ្ម៉ុعز وجل តែស្ហៃតនលعنه اللهឆ្លាតជាង វាلعنه اللهបានស្បថក្នុងព្រះនាមអល់ឡោះហ្ម៉ុعز وجل ។ ទីបំផុតព្រះអង្គទាំងពីរعليهم السلامល្មើសព្រះបញ្ជាអល់ឡោះហ្ម៉ុعز وجلដោយបរិភោគផ្លែឈើហាម ។
- អល់ឡោះហ្ម៉ុعز وجلទ្រង់ព្រះពិរោធបទល្មើសរបស់ព្រះសាស្តាصلى الله عليه وآله وسلمអាដាំعَلَيْهِ السَّلَام និងព្រះនាងហាវ៉ាអ៊ុسلام الله عليها ។ ទោះបីព្រះអង្គទាំងពីរعليهم السلامអង្វរសូមខមាទោសក៏ដោយ អល់ឡោះហ្ម៉ុعز وجلដេញព្រះអង្គទាំងពីរعليهم السلامចេញពីឋានសួគ៌ឲ្យមកនៅឯផែនដី ព្រះអង្គទាំងពីរعليهم السلامចាំបាច់ត្រូវធ្វើការងារដើម្បីចិញ្ចឹមជីវិតខ្លួនឯងនិងគ្រួសារ ។
- ពីដំបូងព្រះអង្គទាំងពីរعليهم السلامស្នប់រស់នៅឯ*អ៊ុដ្ហាន់* ព្រះអង្គទាំងពីរعليهم السلامបានអង្វរអល់ឡោះហ្ម៉ុعز وجلសូមឲ្យព្រះអង្គعز وجلលើកលែងទោសឲ្យព្រះអង្គទាំងពីរعليهم السلام ។ ព្រះ

អង្គ ﷻ អភ័យទោសឲ្យព្រះអង្គទាំងពីរ عليهما السلام តែព្រះអង្គ ﷻ មានព្រះបន្ទូលថាព្រះអង្គទាំងពីរ عليهما السلام ត្រូវតែចាប់កន្លែងរបស់ខ្លួនក្នុងឋានសួគ៌ ។ អល់ឡោះហ្ ﷻ បានប្រាប់ថាមានផ្លូវពីរនៅក្នុងជីវិតនេះគឺ ផ្លូវគោរពព្រះបញ្ជាអល់ឡោះហ្ ﷻ ដែលនាំទៅរកឋានសួគ៌ មួយទៀតគឺផ្លូវល្មើសព្រះបញ្ជាអល់ឡោះហ្ ﷻ ដែលនាំទៅរកឋាននរក ។

- ព្រះសាស្តាអាដាំ ﷺ និងព្រះនាងហាវ៉ាអ៊ុ سلام الله عليها បានតាំងលំនៅ ធ្លាប់នឹងរបៀបរស់នៅថ្មីបន្តិចម្តងៗ អល់ឡោះហ្ ﷻ បានប្រោសប្រណីព្រះអង្គទាំងពីរ عليهما السلام ដោយឲ្យព្រះអង្គទាំងពីរ عليهما السلام មានកូន កូនបងគេគឺក៏ប៊ីលនិងប្អូនស្រីភ្លោះ កូនប្អូនគឺហាប៊ីលនិងប្អូនស្រីភ្លោះ ។ ពេលក៏ប៊ីលនិងហាប៊ីលគ្រប់អាយុរៀបការ អល់ឡោះហ្ ﷻ បានចាត់បញ្ជូនស្ត្រីពីរនាក់មកពីលើមេឃដើម្បីជាភរិយារបស់អ្នកទាំងពីរ ។

## មេរៀនទី ១៦

# ព្រះសាស្តា អាដាំ عليه السلام - ភាគ ៣

ពេលកូនៗព្រះអង្គ عليه السلام ធំ ព្រះសាស្តាអាដាំ عليه السلام គិតថានឹងជ្រើសរើសកូនម្នាក់ជាអ្នកស្នងព្រះអង្គ عليه السلام ។ អល់ឡោះហ៊្ជ عز وجل ឲ្យព្រះអង្គ عليه السلام ជ្រើសរើសហាប៊ិលព្រោះហាប៊ិលប្រសើរជាងបង ។ ក៏ប៊ិលក្រោធណាស់ ប្រាប់ឪពុកថាខ្លួនទេជាអ្នកស្នងឪពុក ព្រោះខ្លួនចាស់ជាងហាប៊ិល ។

ទីបំផុត ព្រះសាស្តាអាដាំ عليه السلام ឲ្យម្នាក់ៗយកតង្វាយទៅថ្វាយអល់ឡោះហ៊្ជ عز وجل អ្នកដែលសមជាអ្នកស្នងគឺអ្នកដែលគេព្រមយកតង្វាយ ។ ហាប៊ិលគិតនឹងបូជាសត្វល្អជាងគេមួយក្បាល គឺចៀមធំស្អាតជាងគេ ។ ក៏ប៊ិលគិតថាអល់ឡោះហ៊្ជ عز وجل នឹងមិនសោយកសិផលដែលខ្លួនប្រមូលបាននោះទេ ដូច្នេះមិនមានប្រយោជន៍ទេដែលយកកសិផលល្អៗទៅបូជានោះ ។ ដូច្នេះ ក៏ប៊ិលបានយកពោតខូចទៅថ្វាយអល់ឡោះហ៊្ជ عز وجل ។ ភ្លើងចេញមកពីលើមេឃឆេះចៀមអស់សល់តែផេះ ចំណែកឯពោតខូចនៅដដែល ។ បានសេចក្តីថាគេទទួលយកតង្វាយរបស់ហាប៊ិល តង្វាយរបស់ក៏ប៊ិលត្រូវច្រានចោល ។ ដូច្នេះហាប៊ិលស្នងព្រះសាស្តាអាដាំ عليه السلام ។

ចាប់ពីពេលនេះតទៅក៏ប៊ិលច្រណែនឈ្នានីស ស្អប់ខ្ពើមប្អូន ។ ក៏ប៊ិលបៀតបៀននិងចង់សម្លាប់ហាប៊ិល ។ អល់ឡោះហ៊្ជ عز وجل ថ្លែងអំពីព្រឹត្តិការណ៍នេះនៅក្នុងព្រះគម្ពីរគួរអានថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

۞وَٱتۡلُ عَلَيۡهِمۡ نَبَأَ ٱبۡنَيۡ ءَادَمَ بِٱلۡحَقِّ إِذۡ قَرَّبَا قُرۡبَانٗا فَتُقُبِّلَ مِنۡ أَحَدِهِمَا وَلَمۡ يُتَقَبَّلۡ مِنَ ٱلۡأٓخَرِ قَالَ لَأَقۡتُلَنَّكَۖ قَالَ إِنَّمَا يَتَقَبَّلُ ٱللَّهُ مِنَ ٱلۡمُتَّقِينَ ٢٧

*ដោយនូវព្រះនាមអល់ឡោះហ៊្ជ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*២៧. អ្នកចូរថ្លែងប្រាប់ពួកគេនូវប្រវត្តិកូនអាដាំពីរនាក់ ក្នុងនាមនៃការពិត កាលអ្នកទាំងពីរបានបូជាតង្វាយ ។ គេបានទទួលយកតែតង្វាយរបស់ម្នាក់ទេ រីឯតង្វាយរបស់ម្នាក់ទៀតពុំត្រូវទទួលយកទេ ។ គេ (គឺក៏ប៊ិល) បាននិយាយ[ទៅកាន់ម្នាក់*

*ទៀត]ថា៖ "អញនឹងសម្លាប់ឯង ។" គេ (ហ៊្វាប៊ិល) បាននិយាយថា៖ "អល់ឡោះហ៊្វា ទទួលយក[តង្វាយ]តែពីអ្នកណាដែលជឿសិប់ចិត្តទេ ។*(ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស៊ុ, ៥:២៧)

ហ៊្វាប៊ិលស្រឡាញ់បង ព្យាយាមលួងបងកុំឲ្យឆេវឆាវថា៖ "លោកបងអើយ លោកបងល្មៀងចេញពីផ្លូវល្អហើយ គោលបំណងលោកបងមិនល្អប្រពៃទេ ។ ចូរសូមខមាទោសអល់ឡោះហ៊្វ ﷻ កុំចង់ជួញទណ្ឌកម្មនរក ។" ពាក្យពេជន៍ទាំងនេះពុំមានឥទ្ធិពលទៅលើក៉ប៊ិលទេ ។ ក៉ប៊ិលមានះឡើងចាង គិតតែខ្លួនឯង ។ ទីបំផុតអារម្មណ៍ក៉ប៊ិលពេញដោយសេចក្ដីឈ្នានីស ថ្ងៃមួយក៉ប៊ិលបានសម្លាប់ហ៊្វាប៊ិល ។

**ជ្រុងសីលធម៌**

អ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថា៖ "........................................"
ហេតុអ្វីការច្រណែនឈ្នានីសអាក្រក់ម្ល៉េះ ? ចូរឆ្លើយដោយផ្អែកទៅលើរឿងហ៊្វាប៊ិល និងក៉ប៊ិល ។

មិនឃើញហ៊្វាប៊ិលត្រឡប់មកផ្ទះវិញ ព្រះសាស្តា ﷺ អាដាំ عليه السلام ភ័យបារម្ភ សួរក៉ប៊ិលថាបានឃើញប្អូនឬទេ ។ ក៉ប៊ិលបានឆ្លើយបែបព្រហើនថា៖ "ខ្ញុំជាអ្នកថែរក្សាវាឬ ?" ចម្លើយនេះធ្វើឲ្យព្រះសាស្តាអាដាំ عليه السلام សន្និតថាកូនព្រះអង្គ عليه السلام ស្លាប់ហើយ ព្រះអង្គ عليه السلام សោកសៅណាស់ដែលបាត់បង់កូន ។

ចន្លោះពេលនោះ ក៉ប៊ិលមិនដឹងធ្វើអ្វីជាមួយសាកសពប្អូន ។ គាត់លីសាកសពដាក់ក្នុងបាវ ។ គាត់ខ្លាសខ្លួនឯងដែលបានប្រព្រឹត្តអំពើនេះ គាត់រិះគិតរកមធ្យោបាយពេញមួយយប់ ។

ពេលនោះ អល់ឡោះហ៊្វ ﷻ បានសម្រេចដឹកនាំបុរសភ្លើនេះ ។ ព្រោះតែបុគ្គលរូបនេះមិនស័ក្តិសមនឹងទទួលបាននូវការណែនាំពីអល់ឡោះហ៊្វ ﷻ ផ្ទាល់ អល់ឡោះហ៊្វ ﷻ បានឲ្យសត្វក្អែកមកបង្ហាត់បង្រៀនគាត់ ។

អល់ឡោះហ៊្វ ﷻ បានចាត់បញ្ជូនក្អែកពីរមកឲ្យក៉ប៊ិលឃើញ ។ ក៉ប៊ិលឃើញ

ក្អែកមួយសម្លាប់ក្អែកមួយទៀត ។ បន្ទាប់មកវាយកចំពុះចឹកដីកើតជារណ្តៅហើយកប់សពក្អែកស្លាប់ក្នុងរណ្តៅនោះ ។ រួចហើយវាយកជើងតន្រ្តំដីឲ្យស្មើ ។ ក៏ាប៊ិលក៏បានភ្ញាក់គំនិត ដឹងថាត្រូវធ្វើដូចម្តេច ហើយកប់សាកសពហ្វាប៊ិល ប្អូនប្រុសគាត់ទាំងខ្លោចចិត្ត ។

ព្រះសាស្តាអាដាំعليه السلامនិងព្រះនាងហាវ៉ាអ៊ុسلام الله عليهاនឹកហ្វាប៊ិលណាស់ ព្រោះហ្វាប៊ិលជាមនុស្សល្អ ។ ព្រះអង្គទាំងពីរعليهما السلامបានសូមអល់ឡោះហ្ស៊ عز وجلឲ្យបានកូនប្រុសម្នាក់ទៀតដូចហ្វាប៊ិល ។ អល់ឡោះហ្ស៊عز وجلបានឲ្យការបួងសួងរបស់ព្រះអង្គទាំងពីរعليهما السلامបានសម្រេច ព្រះអង្គទាំងពីរعليهما السلامក៏បានកូនប្រុសម្នាក់ គឺព្រះសាស្តាស៊ីស្សعليه السلام (شِيْث) ។

ក៏ាប៊ិលបានទៅរស់នៅឯខាងកើតនៃទឹកដី*អាដាន់* គាត់គោរពបូជាភ្លើងនៅឯទីនោះ ។ សម័យព្រះសាស្តានុះហ៍عليه السلام ទឹកជំនន់បានពន្លង់បណ្តាកូនចៅរបស់ក៏ាប៊ិលទាំងអស់ មានតែបណ្តាកូនចៅរបស់ព្រះសាស្តាស៊ីស្សعليه السلامទេដែលរស់នៅក្នុងពិភពលោក ។

***ពេលនេះអ្នកដឹង...***

- អល់ឡោះហ្ស៊عز وجلឲ្យព្រះសាស្តាអាដាំعليه السلامតែងតាំងហ្វាប៊ិលជាអ្នកស្នង ។ ក៏ាប៊ិលក្រោធមិនយល់ស្របទេ ថាគាត់ជាអ្នកស្នងឪពុកព្រោះក្នុងចំណោមបងប្អូនទាំងពីរនាក់មានតែគាត់ទេដែលចាស់ជាងគេ ។
- ដើម្បីជ្រើសរើស ព្រះសាស្តាអាដាំعليه السلامឲ្យកូនទាំងពីរយកតង្វាយទៅថ្វាយអល់ឡោះហ្ស៊عز وجل អ្នកស្នងព្រះអង្គعليه السلامគឺអ្នកដែលអល់ឡោះហ្ស៊عز وجلព្រមទទួលយកតង្វាយ ។ ក៏ាប៊ិលបានយកពោតខូចទៅថ្វាយអល់ឡោះហ្ស៊عز وجل (ដោយគិតថាអល់ឡោះហ្ស៊عز وجلនឹងមិនសោយពោតនោះទេ) ហ្វាប៊ិលបានយកចៀមស្អាតធំមួយទៅថ្វាយអល់ឡោះហ្ស៊عز وجل ។ អល់ឡោះហ្ស៊عز وجلបានទទួលយកតង្វាយរបស់ហ្វាប៊ិល ។
- ក៏ាប៊ិលច្រណែនហ្វាប៊ិល ចាប់ផ្តើមធ្វើអាក្រក់ គិតសម្លាប់ប្អូន ។ ហ្វាប៊ិលព្យាយាមលួងបងកុំឲ្យឆេវឆាវ ប្រាប់បងឲ្យសូមខមាទោសអល់ឡោះហ្ស៊عز وجل ។

- ក៏ប៊ិលបណ្ដោយខ្លួនឲ្យការច្រណែនឈ្នានីសឈ្នះអារម្មណ៍ ថ្ងៃមួយគាត់បានសម្លាប់ហ្វាប៊ិល ។
- ក៏ប៊ិលមិនដឹងធ្វើអ្វីជាមួយសាកសពហ្វាប៊ិលទេ ។ អល់ឡោះហ៏ﷻបានចាត់បញ្ជូនក្អែកពីរឲ្យមកណែនាំគាត់ ។ ក្អែកមួយបានសម្លាប់ក្អែកមួយទៀត ហើយបានជីកដីកប់ក្អែកស្លាប់ ។ ក៏ប៊ិលក៏បានដឹងថាត្រូវធ្វើអ្វី ។
- ព្រះសាស្ដាអាដាំﷺនិងព្រះនាងហាវ៉ាអ៊ុំ سلام الله عليها នឹកហ្វាប៊ិលណាស់ ព្រោះហ្វាប៊ិលជាមនុស្សល្អ ។ ព្រះអង្គទាំងពីរ عليهم السلام ក៏បានសូមអល់ឡោះហ៏ عز وجل ឲ្យបានកូនប្រុសម្នាក់ទៀតដូចហ្វាប៊ិល អល់ឡោះហ៏ عز وجل បានបំពេញបំណងព្រះអង្គទាំងពីរ عليهم السلام ។ ព្រះនាងហាវ៉ាអ៊ុំ سلام الله عليها ក៏បានប្រសូតកូនប្រុសទីបី គឺព្រះសាស្ដាស៊ីស្ធ عليه السلام ។

# លំហាត់មេរៀនសាឡើងវិញ ៥

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺៈ

១. ពេលអល់ឡោះហ្ទ៍عَزَّ وَجَلَّប្រាប់អស់ទេវតាថា ព្រះអង្គعَزَّ وَجَلَّនឹងបង្កើតសត្វលោកថ្មីមួយ តើអស់ទេវតាឆ្លើយថាអ្វី ហេតុអ្វី ?

២. តើអល់ឡោះហ្ទ៍عَزَّ وَجَلَّឆ្លើយតបអស់ទេវតាថាអ្វី ?

៣. តើអ៊ីប្លីសلعنه اللهល្មើសបង្គាប់អល់ឡោះហ្ទ៍عَزَّ وَجَلَّដូចម្តេច ហេតុអ្វី ?

៤. តើអ៊ីប្លីសلعنه اللهសន្យាធ្វើអ្វីចំពោះព្រះសាស្តាអាដាំعَلَيْهِ السَّلَامُ និងបណ្តាកូនចៅព្រះអង្គعَلَيْهِ السَّلَامُ ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើស្ហៃតន្ទលعنه اللهប្រាប់ព្រះសាស្តាអាដាំعَلَيْهِ السَّلَامُនិងព្រះនាងហាវ៉ាអ៊ុ័سلام الله عليهاថាអ្វី អំពីដើមឈើហាម ?

២. ហេតុអ្វីព្រះសាស្តាអាដាំعَلَيْهِ السَّلَامُនិងព្រះនាងហាវ៉ាអ៊ុ័سلام الله عليهاស្តាប់ស្ហៃតន្ទលعنه الله ?

៣. អល់ឡោះហ្ទ៍عَزَّ وَجَلَّបានលើកទោសឲ្យព្រះសាស្តាអាដាំعَلَيْهِ السَّلَامُ និងព្រះនាងហាវ៉ាអ៊ុ័سلام الله عليهاដែលបានធ្វើខុស តែព្រះអង្គعَزَّ وَجَلَّបានប្រាប់ព្រះអង្គទាំងពីរعليهما السلامថាព្រះអង្គទាំងពីរعليهما السلامត្រូវចាប់កន្លែងនៅរបស់ព្រះអង្គعليهما السلامក្នុងឋានក្រោម ។ តើត្រូវធ្វើដូចម្តេច ?

៤. តើកូនប្រុសរបស់ព្រះសាស្តាអាដាំعَلَيْهِ السَّلَامُរៀបការជាមួយអ្នកណា ?

## ខណ្ឌ គ

ចូរឆ្លើយសំណួរតទៅគឺៈ

១. ហេតុអ្វីក៏ហ្ទ៍ប៊ិលថាខ្លួនជាអ្នកស្នងឪពុក ?

២. តើក៏ហ្ទ៍ប៊ិលនិងហាប៊ិលត្រូវឆ្លងកាត់ការពិសោធន៍អ្វី អ្នកណាឈ្នះ ?

៣. អ្នកណាបានសម្លាប់អ្នកណា ?

៩. អល់ឡោះហ្ទ៍عزّ وجلّបានណែនាំក្តុំប៊ិលដូចម្ដេច ?

## មេរៀនទី ១៧

# ព្រះសាស្តា អ៊ីដ្រីសعَلَيْهِ السَّلَامُ

ព្រះគម្ពីរគួរអានថែងថា៖

بِسْمِ ٱللَّهِ ٱلرَّحْمَٰنِ ٱلرَّحِيمِ

وَٱذْكُرْ فِى ٱلْكِتَٰبِ إِدْرِيسَ ۚ إِنَّهُۥ كَانَ صِدِّيقًا نَّبِيًّا ﴿٥٦﴾ وَرَفَعْنَٰهُ مَكَانًا عَلِيًّا ﴿٥٧﴾

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៥៦. ចូរអ្នកថ្លែងអំពីអ៊ីដ្រីសក្នុងព្រះគម្ពីរ ។ គេជាសច្ចការី ជាសាស្តា ។ ៥៧. យើងបានលើកគេឡើងទៅឯឋានខ្ពស់ ។*(ស៊ូរ៉ោះត៍ ម៉ារយ៉ាំ, ១៩:៥៦-៥៧)

ព្រះសាស្តាអ៊ីដ្រីសعَلَيْهِ السَّلَامُជាចៅទួតរបស់ព្រះសាស្តាស៊ីស្ធ់عَلَيْهِ السَّلَامُ ព្រះអង្គعَلَيْهِ السَّلَامُប្រសូត ១០០ ឆ្នាំក្រោយព្រះសាស្តាអាដាំعَلَيْهِ السَّلَامُសោយទិវង្គត ។ ព្រះអង្គعَلَيْهِ السَّلَامُជាព្រះសាស្តាទី ៣ របស់អល់ឡោះហ៍عَزَّ وَجَلَّ ។

ព្រះសាស្តាអ៊ីដ្រីសعَلَيْهِ السَّلَامُបានប្រាប់ឲ្យប្រជារាស្ត្រ គោរពសក្ការៈអល់ឡោះហ៍عَزَّ وَجَلَّ កុំសាងបាបកម្ម ។ ព្រះអង្គعَلَيْهِ السَّلَامُជាមនុស្សប្រកបដោយប្រាជ្ញា ព្រះអង្គعَلَيْهِ السَّلَامُបានបង្ហាត់មនុស្សឲ្យស្គាល់នវាគតភណ្ឌ (ស្គាល់វត្ថុថ្មី) ។ ព្រះអង្គعَلَيْهِ السَّلَامُជាបុគ្គលដំបូងបង្អស់ដែលនាំចូលនូវអក្សរសាស្ត្រ បានបង្ហាត់ឲ្យមនុស្សចេះថ្លឹងវត្ថុដោយជញ្ជីញ ។ ព្រះអង្គعَلَيْهِ السَّلَامُបានបង្ហាត់បង្រៀនមនុស្សឲ្យចេះដឹងដំណើរផ្កាយ ។ ព្រះអង្គعَلَيْهِ السَّلَامُជាបុគ្គលដំបូងបង្អស់ដែលបង្កើតអាវុធសម្រាប់បរបាញ់និងសម្រាប់ការពារខ្លួន ព្រះអង្គعَلَيْهِ السَّلَامُបានបង្ហាត់បង្រៀនឲ្យមនុស្សចេះដេរដែរ ។

**ជ្រុងស្រាវជ្រាវ៥**

អ៊ីម៉ាំصلوات الله عليه والسلامអង្គណាដែលល្បីថាជាអ្នកចេះដឹង ?..................................

គេហៅនាមចំតើតរបស់ព្រះអង្គصلوات الله عليه والسلامថាអ្វី ?.....................................

សម័យព្រះសាស្តាអ៊ីដ្ររីស عليه السلام មានស្តេចកំណាចមួយគ្រប់គ្រងលើជីវិតនិងទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ។ ថ្ងៃមួយស្តេចនេះដើរកំសាន្ត បានឃើញសួនច្បារមួយក៏ស្រឡាញ់សួននោះណាស់ ។ ស្តេចបានហៅម្ចាស់សួនមកជួប ឲ្យប្រគល់សួនឲ្យខ្លួន ។ បុរសម្ចាស់សួនដែលខ្លាចតែព្រះមួយគត់នោះបានតបថាសួននេះជាបង្អែករបស់គ្រួសារគាត់ គាត់មិនប្រគល់ឲ្យទេ ។ ស្តេចសូមទិញដីសួននោះ តែម្ចាស់សួនបដិសេធ ។ ស្តេចក្រោធ ត្រឡប់ទៅដំណាក់វិញ ។

មហេសីរបស់ស្តេចជាស្ត្រីអាក្រក់ ។ ពេលបានដឹងហេតុការណ៍ដែលបានកើតឡើង ស្ត្រីកំណាចបានប្រជុំមិត្តឥតសាសនាពីរបីនាក់ជាសាក្សីនៅឯវាំង ។ ស្រីចិត្តខ្មៅបានឲ្យពួកគេស្បថថាម្ចាស់សួនលែងជឿព្រះ ថាគាត់ក្បត់ស្តេច ។ ពេលពួកនិយាយបង្កាច់ទាំងនេះធ្វើសាក្សី គេបានកោះហៅម្ចាស់សួនមកឯរាជវាំង ត្រូវចោទថាបានប្រព្រឹត្តបទឧកក្រិដ្ឋទាំងនេះ ។ ទោះបីគាត់បានស្បថថាមិនបានធ្វើកំហុសទាំងនេះក៏ដោយ ស្តេចមិនស្តាប់គាត់ទេ ហើយបានសម្លាប់គាត់ ។ ស្តេចបានរឹបយកដីទ្រព្យរបស់បុរសស្លាប់ ។

ឃាតកម្មប្រព្រឹត្តដោយស្តេចល្មោភនេះ ធ្វើឲ្យអល់ឡោះហ៍ عَزَّ وَجَلَّ ទ្រង់ព្រះពិរោធ ព្រះអង្គ عَزَّ وَجَلَّ បានឲ្យព្រះសាស្តាអ៊ីដ្ររីស عليه السلام ទៅជួបស្តេចនេះ ឲ្យប្រាប់ស្តេចនេះថាខ្លួនមិនត្រឹមតែបានសម្លាប់មនុស្សមានជំនឿជ្រះថ្លាម្នាក់ប៉ុណ្ណោះទេ ថែមទាំងបានប្លន់យកដីរបស់បុរសនោះ ធ្វើឲ្យគ្រួសារបុរសនោះធ្លាក់ខ្លួនក្រ ។ ព្រះសាស្តាអ៊ីដ្ររីស عليه السلام បានទទួលព្រះបញ្ជាដែរ ថាឲ្យប្រាប់ស្តេចនោះថាអល់ឡោះហ៍ عَزَّ وَجَلَّ នឹងធ្វើទណ្ឌកម្មស្តេចនោះដោយរឹបយករាជាណាចក្រ ដោយកម្ទេចនគររបស់ស្តេចនោះចោល ឯសាកសពមហេសីរបស់ស្តេចនោះនឹងត្រូវឆ្កែស៊ី ។

ពេលព្រះសាស្តាអ៊ីដ្ររីស عليه السلام បាននាំព្រះរាជសារនេះទៅរាជវាំង ស្តេចក្រោធខ្លាំង ថា៖ "ឯងគប្បីចាកចេញពីទីនេះមុនអញនឹងសម្លាប់ឯងដោយផ្ទាល់ដៃ ។" ព្រះសាស្តាអ៊ីដ្ររីស عليه السلام បានចាកចេញ តែស្តេចស្រីបានចាត់បញ្ជូនមនុស្សទៅតាមសម្លាប់ព្រះអង្គ عليه السلام ។

ព្រះសាស្តាអ៊ីដ្ររីស عليه السلام បានដឹងថាមហេសីព្រះអង្គ عليه السلام ជួបគ្រោះថ្នាក់ ព្រះ

អង្គعليه السلامចេញពីស្រុកទៅលាក់ខ្លួន ។ ព្រះអង្គعليه السلامបានពួននៅក្នុងរូងភ្នំមួយ ទេវតាបានយកបាយមកឲ្យព្រះអង្គعليه السلام ។ ព្រះអង្គعليه السلامបួងសួងអល់ឡោះហ្ទ៍عز وجلថា៖ "អល់ឡោះហ្ទ៍عز وجلអើយ សូមព្រះអង្គعز وجلកុំឲ្យស្រុកនេះមានសិរីសួស្តី ។"

អល់ឡោះហ្ទ៍عز وجلបានឲ្យសំបូងសង្រ្វងរបស់ព្រះសាស្តាអ៊ីដ្រីសعليه السلام បានសម្រេច ទណ្ឌកម្មអល់ឡោះហ្ទ៍عز وجلក៏បានបាក់ស្រោចមកលើស្តេចកំណាច ។ ស្តេចអប្រិយបានបាត់បង់រាជបល្ល័ង្ក បានស្លាប់យ៉ាងអាម៉ាស់ ។ នគរស្តេចកំណាចនេះត្រូវកម្ទេចចោល ឯសាកសពមហេសីស្តេចអាក្រក់ត្រូវឆ្កែព្រៃស៊ី ។ រាជាណាចក្របានធ្លាក់ទៅក្នុងកណ្តាប់ដៃស្តេចមួយទៀតដែលសាហាវដូចស្តេចមុន ។

ក្រោយពីព្រះសាស្តាអ៊ីដ្រីសعليه السلامបានចាកចេញ ម៉្តផ្នាំបានកន្លងផុត ។ ក្នុងអំឡុងពេល ២០ ឆ្នាំនេះពុំមានភ្លៀងធ្លាក់សោះ មនុស្សធ្លាក់ខ្លួនឈឺដោយជម្ងឺកំណាច ។ ពួកគេដឹងថាជម្ងឺនេះមកពីបណ្តាសារបស់ព្រះសាស្តាអ៊ីដ្រីសعليه السلام ដូច្នេះពួកគេនាំគ្នាបួងសួងអល់ឡោះហ្ទ៍عز وجلសូមខមាទោសព្រះអង្គعز وجل ។ អល់ឡោះហ្ទ៍عز وجلព្រមទទួលការអង្វររបស់ពួកគេ ព្រះអង្គعز وجلបានចាត់បញ្ជូនព្រះសាស្តាអ៊ីដ្រីសعليه السلامមកកាន់នគរវិញ ។ ប្រជារាស្ត្រចោមរោមព្រះអង្គعليه السلام សន្យាព្រះអង្គعليه السلامថានឹងធ្វើសក្ការៈនិងស្តាប់បង្គាប់អល់ឡោះហ្ទ៍عز وجل ។ បន្ទាប់មកព្រះអង្គعليه السلامបានបួងសួងអល់ឡោះហ្ទ៍عز وجلសូមឲ្យភ្លៀង ការរីងរាំងក៏បានចប់ត្រឹមនេះ ។ ព្រះសាស្តាអ៊ីដ្រីសعليه السلامដឹកនាំប្រជារាស្ត្រច្រើនឆ្នាំ ។ ព្រះអង្គعليه السلامជាព្រះសាស្តាដែលប្រជារាស្ត្រស្រឡាញ់និងគោរព ។ ទីបំផុតអល់ឡោះហ្ទ៍عز وجلបានលើកព្រះអង្គعليه السلامឡើងទៅលើមេឃ ព្រះអង្គعليه السلامមានព្រះជន្មនៅឡើយសព្វថ្ងៃនេះ ។

***ពេលនេះអ្នកដឹង...***

- ព្រះសាស្តាអ៊ីដ្រីសعليه السلامបានបង្ហាត់មនុស្ស ឲ្យចេះគោរពបូជាអល់ឡោះហ្ទ៍عز وجل ។ ព្រះអង្គعليه السلامមានប្រាជ្ញាណាស់ ។ ព្រះអង្គعليه السلامជាបុគ្គលដំបូងបង្អស់ដែលនាំចូលអក្សរសាស្ត្រ ជាបុគ្គលដំបូងបង្អស់ដែលបានបង្កើតអាវុធសម្រាប់បរបាញ់សត្វនិងសម្រាប់ការពារខ្លួន ព្រះអង្គعليه السلامបានបង្ហាត់ឲ្យមនុស្សចេះដេរដៃ ។

- សម័យព្រះសាស្តាអ៊ីដ្ររីស﵇ ស្តេចកំណាចកាន់អំណាច ។ ថ្ងៃមួយស្តេចនេះបានចោទបង្កាច់បុរសម្នាក់ដែលខ្លាចក្រែងព្រះថាក្បត់សាសនា ។ ស្តេចនេះបានឲ្យគេសម្លាប់បុរសស្លូតត្រង់ប្លន់យកដីទ្រព្យគាត់ បណ្តោយឲ្យគ្រួសារគាត់រងទុក្ខលំបាក ។
- អល់ឡោះហ្ន៎﷿ទ្រង់ព្រះពិរោធ បានចាត់បញ្ជូនព្រះសាស្តាអ៊ីដ្ររីស﵇ទៅជួបស្តេចកំណាច ប្រាប់ស្តេចឲ្យដឹងអំពីបាបធំរបស់ខ្លួន អំពីទណ្ឌកម្មព្រះដ៏តឹងរ៉ឹង ។ ពេលព្រះអង្គ﵇ទៅជួបស្តេចអាក្រក់ ស្តេចនោះក្រោធ ចង់សម្លាប់ព្រះអង្គ﵇ បើព្រះអង្គ﵇មិនចេញពីវាំងភ្លាមទេ ។ ព្រះអង្គ﵇បានចាកចេញ តែស្តេចស្រីបានចាត់បញ្ជូនមនុស្សទៅតាមសម្លាប់ព្រះអង្គ﵇ ។
- ព្រះសាស្តាអ៊ីដ្ររីស﵇បានលាក់ខ្លួននៅក្នុងរូងភ្នំ បានបួងសួងអល់ឡោះហ្ន៎﷿ថា៖ "អល់ឡោះហ្ន៎﷿អើយ សូមព្រះអង្គ﷿កុំឲ្យនគរនេះមានសិរីសួស្តី ។"
- អល់ឡោះហ្ន៎﷿បានទទួលសំបួងសង្រួងរបស់ព្រះសាស្តាអ៊ីដ្ររីស﵇ បានធ្វើទណ្ឌកម្មស្តេចអប្រិយ ។ តែស្តេចសាហាវមួយទៀតបានសោយរាជ្យនគរនេះ ។
- ម្ភៃឆ្នាំបានកន្លងផុត គេមិនឃើញព្រះសាស្តាអ៊ីដ្ររីស﵇ទេ ។ ក្នុងអំឡុងពេល ២០ ឆ្នាំនេះពុំមានភ្លៀងធ្លាក់សោះ មនុស្សកើតជម្ងឺកាច ។ ពួកគេដឹងខ្លួនថាបានធ្វើខុស ក៏បានសូមឲ្យអល់ឡោះហ្ន៎﷿លើកលែងទោស ។ ព្រះសាស្តាអ៊ីដ្ររីស﵇ត្រឡប់មកកាន់នគរវិញ ព្រះអង្គ﵇បានបួងសួងសូមឲ្យអល់ឡោះហ្ន៎﷿បញ្ចប់ការរីងរាំង ។
- ប្រជារាស្ត្រស្រឡាញ់និងគោរពព្រះសាស្តាអ៊ីដ្ររីស﵇ ។ អល់ឡោះហ្ន៎﷿បានលើកព្រះអង្គ﵇ឡើងទៅលើមេឃ ព្រះអង្គ﵇មានព្រះជន្មនៅឡើងនៅទីនោះ ។

## មេរៀនទី ១៨

# ព្រះសាស្តា នុះហ៍عليه السلام

កាលពីយូរអង្វែងមកហើយ មានប្រជារាស្ត្រមួយបានរស់ដោយគោរពបូជារូបបដិមាជាព្រះ ។ អល់ឡោះហ៊្វعز وجل បានចាត់បញ្ជូនព្រះសាស្តានុះហ៍عليه السلام ទៅដឹកនាំប្រជារាស្ត្រនោះនៅលើផ្លូវត្រូវ ។

ព្រះសាស្តានុះហ៍عليه السلام ប្រកបដោយប្រាជ្ញាញាណនិងអំណត់ ព្រះអង្គعليه السلام ព្យាយាមបង្ហាត់បង្រៀនប្រជារាស្ត្រទាំងនោះឲ្យស្គាល់អល់ឡោះហ៊្វعز وجل និងព្រះគុណព្រះអង្គعز وجل ព្រះអង្គعليه السلام ឲ្យពួកគេឈប់គោរពបូជាដុំដីឬដុំឈើជាព្រះ ។ ទោះបីព្រះអង្គعليه السلام ខិតខំណែនាំយ៉ាងណាក៏ដោយ ពួកគេមិនស្តាប់ព្រះអង្គعليه السلام ទេ ពួកគេគេចមុខពីព្រះអង្គعليه السلام ។ ពេលព្រះអង្គعليه السلام ព្រមានពួកគេអំពីទណ្ឌកម្មអល់ឡោះហ៊្វعز وجل ពួកគេចំអកដាក់ព្រះអង្គعليه السلام ។

ព្រះសាស្តានុះហ៍عليه السلام មិនឈប់ប្រៀនប្រដៅទេ ព្រះអង្គعليه السلام នៅតែណែនាំប្រជារាស្ត្រ ។ មានតែមនុស្សតិចតួចទេដែលព្រមស្តាប់ព្រះអង្គعليه السلام មនុស្សឯទៀតថា៖ "លោកعليه السلام គ្រាន់តែមនុស្សដូចយើងដែរ ។ បើព្រះរបស់លោកعليه السلام ចង់ឲ្យព្រះសាស្តាមកដឹកនាំយើង ព្រះអង្គប្រាកដជានឹងចាត់បញ្ជូនទេវតាមួយអង្គមក យើងនឹងស្តាប់ទេវតានោះ ។" មនុស្សឯទៀតថា៖ "នុះហ៍عليه السلام បើលោកعليه السلام ចង់ឲ្យយើងជឿលោកعليه السلام លោកعليه السلام ត្រូវតែចោលពួកដែលកំពុងតាមលោកعليه السلام ពួកគេភាគច្រើនក្រ ។ ឲ្យគេជឿសាសនាដែលគោរពអ្នកមាននិងអ្នកក្រស្មើគ្នាដូចម្តេចទៅ ?" ព្រះសាស្តានុះហ៍عليه السلام តបថា៖ "សាសនាខ្ញុំសម្រាប់មនុស្សទាំងអស់ សម្រាប់បណ្តាអ្នកចេះនិងសម្រាប់អ្នកភ្លើ សម្រាប់បណ្តាអ្នកមានកេរ្តិ៍ឈ្មោះនិងសម្រាប់បណ្តាអ្នកតូចតាច សម្រាប់អ្នកមាននិងសម្រាប់អ្នកក្រ ។ ខ្ញុំعليه السلام មិនអាចចោលបណ្តាអ្នកដែលបានជ្រោមជ្រែងខ្ញុំعليه السلام កាលខ្ញុំعليه السلام គ្មានគ្នានោះបានទេ ។ ពួកគេទាំងនោះជាអ្នកជឿអល់ឡោះហ៊្វعز وجل ពិតប្រាកដ ។" គេមិនចូលចិត្តសម្តីព្រះសាស្តានុះហ៍عليه السلام ទេ តបព្រះអង្គعليه السلام វិញយ៉ាងក្រអឺតថា៖ "នុះហ៍عليه السلام អឺយ ចូរឲ្យព្រះរបស់លោកعليه السلام ដាក់ទណ្ឌកម្មយើងទៅ បើលោកعليه السلام ចង់ ។" ព្រះសាស្តានុះហ៍عليه السلام មានវចនៈថា៖

"ខ្ញុំ(عليه السلام)គ្រាន់តែជាមនុស្សធម្មតាទេ ខ្ញុំ(عليه السلام)មិនមានសមត្ថភាពបញ្ជូនព្រះទណ្ឌកម្មមកលើអស់លោកទេ ហើយក៏មិនមានសមត្ថភាពការពារអស់លោកពីព្រះទណ្ឌកម្មទេបើអល់ឡោះហ្ហ៍(عز وجل)ចង់ដាក់ទណ្ឌកម្មអស់លោក ។ ចូរអស់លោកចងចាំថាអស់លោកនឹងវិលត្រឡប់ទៅរកព្រះអង្គ(عز وجل)វិញថ្ងៃណាមួយ ចូរអស់លោកសោកស្ដាយកំហុសអស់លោកមុនហួសពេល ។"

ទោះបីមនុស្សសម័យព្រះសាស្ដានុះហ្វ៍(عليه السلام)ចចេសរឹងរូសក៏ដោយ ព្រះអង្គ(عليه السلام)អត់ធ្មត់ បន្តការឃោសនាព្រះរាជសាររបស់អល់ឡោះហ្ហ៍(عز وجل) ៩៥០ ឆ្នាំ ។ ព្រះអង្គ(عليه السلام)មិនអើពើការជេរប្រមាថនិងការនិយាយបង្អាប់របស់ពួកគេទេ ដោយសង្ឃឹមថាថ្ងៃណាមួយពន្លឺជំនឿនឹងជ្រាបចូលទៅក្នុងបេះដូងពួកគេ ។ តែយូរទៅៗ ពួកគេកាន់តែអាក្រក់ទៅៗ ហ៊ានវាយប្រហារព្រះអង្គ(عليه السلام)ដោយដុំថ្មរាល់ពេលដែលព្រះអង្គ(عليه السلام)ចង់និយាយជាមួយពួកគេ ។ ទីបំផុតព្រះអង្គ(عليه السلام)ទ្រាំមិនបាន ក៏បានត្អូញត្អែរប្រាប់អល់ឡោះហ្ហ៍(عز وجل) សូមឲ្យអល់ឡោះហ្ហ៍(عز وجل)ជួយដោះស្រាយ ។ អល់ឡោះហ្ហ៍(عز وجل)ទទួលសំណូមព្រះសាស្ដានុះហ្វ៍(عليه السلام) បញ្ជាព្រះអង្គ(عليه السلام)ឲ្យសាងសង់សំពៅធំមួយប្រាប់ព្រះអង្គ(عليه السلام)ថានឹងមានទឹកជំនន់ធំ ពួកសាងបាបកម្មទាំងអស់នឹងស្លាប់ក្នុងទឹកជំនន់នេះ ។ ព្រះគម្ពីរគួរអានចែងថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

إِنَّآ أَرۡسَلۡنَا نُوحًا إِلَىٰ قَوۡمِهِۦٓ أَنۡ أَنذِرۡ قَوۡمَكَ مِن قَبۡلِ أَن يَأۡتِيَهُمۡ عَذَابٌ أَلِيمٞ ١ قَالَ يَٰقَوۡمِ إِنِّي لَكُمۡ نَذِيرٞ مُّبِينٌ ٢
أَنِ ٱعۡبُدُواْ ٱللَّهَ وَٱتَّقُوهُ وَأَطِيعُونِ ٣

*ដោយនូវព្រះនាមអល់ឡោះហ្ហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*១. ពិតណាស់ យើងបានចាត់បញ្ជូននុះហ្វ៍ទៅរកប្រជារាស្ត្ររបស់គេ[ដោយមានតម្រាស់ថា៖] "ចូរអ្នកដាស់តឿនប្រជារាស្ត្រអ្នក មុនទណ្ឌកម្មដ៏វេទនានឹងមកដល់ពួកគេ ។" ២. គេបានថ្លែងថា៖ "ប្រជារាស្ត្រខ្ញុំអើយ ពិតណាស់ខ្ញុំជាអ្នកដាស់តឿនដ៏ជាក់ច្បាស់សម្រាប់អស់លោក ។ ៣. ចូរអស់លោកគោរពបូជាអល់ឡោះហ្ហ៍និងខ្លាចក្រែងព្រះអង្គ ហើយចូរអស់លោកស្ដាប់បង្គាប់ខ្ញុំ ។*(ស៊ូរ៉ោះតុ៎ នុះហ្វ៍, ៧១:១-៣)

ព្រះសាស្ដានុះហ្វ៍(عليه السلام)អនុវត្តិតាមព្រះបញ្ជាអល់ឡោះហ្ហ៍(عز وجل) ដោយដាំដើមឈើ

ចាំឲ្យដើមឈើធំ ទៅជាមាំ ។ បន្ទាប់មកព្រះអង្គﷺ កាប់ដើមឈើនោះ ចាប់ផ្តើមសាងសង់សំពៅ ។ ព្រះអង្គﷺ បានចំណាយពេល ៨០ ឆ្នាំដើម្បីសាងសង់សំពៅរួច ក្នុងអំឡុងពេលនោះ មនុស្សនិយាយលេងសើចអំពីព្រះអង្គﷺ ថាព្រះអង្គﷺ ឈប់ធ្វើជាព្រះសាស្តា ទៅធ្វើជាងឈើវិញ ។

លុះបានរៀបចំសំពៅរួចរាល់ហើយ អល់ឡោះហ្ជ បញ្ជាឲ្យព្រះសាស្តានុះហ្ ﷺ ហៅបណ្តាអ្នកតាមព្រះអង្គﷺ ឡើងសំពៅ ឲ្យយកសត្វគ្រប់ប្រភេទមួយគូៗដាក់សំពៅ ។ ភ្លៀងចាប់ផ្តើមធ្លាក់ដូចបាក់មេឃ ទឹកបាញ់ចេញពីក្នុងដី ។ ផែនដីត្រូវទឹកលិចយ៉ាងឆាប់រហ័ស សំពៅក៏បានអណ្តែតឡើង ។

កូនប្រុសបីនាក់របស់ព្រះសាស្តានុះហ្ﷺ ឈ្មោះ ហ៊ាំ (حَامٌ), សាំ (سَامٌ), យ៉ាហ្វិស្ស (يَافِثُ) និងភរិយាពួកគេផុតភ័យនៅលើសំពៅ តែកូនប្រុសម្នាក់ឈ្មោះកាន់អាន (كَنْعَانُ) ដែលមិនជឿអល់ឡោះហ្ជ នោះមិនព្រមឡើងសំពៅតាមអ្នកទាំងអស់គ្នាទេ ។

ព្រះសាស្តានុះហ្ﷺ ឃើញកាន់អាន កូនប្រុសព្រះអង្គﷺ ប្រវេប្រវាក្នុងទឹក ក៏ខំហៅមករកអល់ឡោះហ្ជ ម្តងទៀតនិងមកឡើងសំពៅ ។ តែកាន់អានបានតបថាខ្លួននឹងទៅឡើងលើកំពូលភ្នំ នឹងបានរួចផុតពីភ័យជាមិនខាន ។ ព្រះសាស្តាﷺ បានព្រមានថានឹងពុំមានជម្រកណាផ្សេងពីសំពៅទេ ដើម្បីឲ្យរួចផុតពីព្រះពិរោធអល់ឡោះហ្ជ នោះ ។ ចន្លោះពេលនោះ រលកធំមួយក៏បានវាយពន្លិចកាន់អានក្បែយអាត្មា ។ អល់ឡោះហ្ជ បានសន្យាព្រះសាស្តានុះហ្ﷺ ថាគ្រួសារព្រះអង្គﷺ និងបណ្តាតាមព្រះអង្គﷺ នឹងមានសុវត្ថិភាព ព្រះសាស្តាﷺ អង្វរអល់ឡោះហ្ជ សូមឲ្យព្រះអង្គជ គោរពសន្យា និងសូមឲ្យព្រះអង្គﷺ ស្រង់ជីវិតកូនប្រុសព្រះអង្គﷺ ។ ព្រះគម្ពីរគួរអានថែងថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَنَادَىٰ نُوحٞ رَّبَّهُۥ فَقَالَ رَبِّ إِنَّ ٱبۡنِي مِنۡ أَهۡلِي وَإِنَّ وَعۡدَكَ ٱلۡحَقُّ وَأَنتَ أَحۡكَمُ ٱلۡحَٰكِمِينَ ٤٥ قَالَ يَٰنُوحُ إِنَّهُۥ لَيۡسَ مِنۡ أَهۡلِكَۖ إِنَّهُۥ عَمَلٌ غَيۡرُ صَٰلِحٖۖ فَلَا تَسۡـَٔلۡنِ مَا لَيۡسَ لَكَ بِهِۦ عِلۡمٌۖ إِنِّيٓ أَعِظُكَ أَن تَكُونَ مِنَ ٱلۡجَٰهِلِينَ ٤٦

*ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៤៥. នុះហ្បានបួងសួងព្រះម្ចាស់គេដោយទូលថា៖ "ព្រះម្ចាស់អើយ កូនប្រុសទូល*

*ព្រះបង្គំជាខ្ញុំជាម្នាក់នៃគ្រួសារទូលព្រះបង្គំជាខ្ញុំ ។ ពាក្យសន្យារបស់ព្រះអង្គសច្ចៈពិតមែន ហើយព្រះអង្គមានយុត្តិធម៌លើសអ្នកកាត់សេចក្តីទាំងឡាយ ។" ៤៦. ព្រះអង្គមានព្រះតម្រាស់ថា៖ "នុះហ៍អើយ គេពុំមែនជាម្នាក់នៃគ្រួសាររបស់អ្នកទេ ។ គេ[ជាអ្នកប្រព្រឹត្ត]ទីទៃពីទង្វើល្អ..."*(ស៊ូរ៉ោះត៍ ហ៊ូដ, ១១:៤៥-៤៦)

អល់ឡោះហ្ស៍ﷻបានប្រាប់ព្រះសាស្តានុះហ៍ﷺថា កាន់អានមិនមែនកូនពិតរបស់ព្រះអង្គﷺទេ ព្រោះកាន់អានមិនប្រព្រឹត្តខ្លួនឲ្យឃើញថាជាកូនដោយទង្វើទេ គេមិនស័ក្តិសមនឹងត្រូវស្រង់ទេ ។ ព្រះសាស្តានុះហ៍ﷺដឹងកំហុស ក៏បានសូមខមាទោសអល់ឡោះហ្ស៍ﷻភ្លាម ។

សំពៅអណ្តែតយូរ ខណៈដែលផែនដីលិចទឹក ពុំមានអ្នកណាមួយរស់រានជីវិតទេនៅលើផែនដី ។ ទីបំផុត ព្រះទណ្ឌកម្មអល់ឡោះហ្ស៍ﷻបានចប់ ភ្លៀងឈប់ធ្លាក់ ។ ទឹកស្រក សំពៅទៅកឿងលើដីគោកនៃភ្នំយូឌី (جودي) ។

ព្រះសាស្តានុះហ៍ﷺបានទទួលព្រះបញ្ជាឲ្យចុះពីលើសំពៅ ឲ្យបណ្តាអ្នកតាមព្រះអង្គﷺនិងសត្វទាំងអស់ដែលនៅលើសំពៅចុះមកដី ។ នៅលើដីថ្មីនេះ ពួកគេកសាងជីវិតថ្មីពីទទេ ក្រោមព្រះពរអល់ឡោះហ្ស៍ﷻ ។

**ផ្ទុងលំហាត់**

ចូរសរសេរឧត្តមគតិរឿងនេះ ។

.........................................................................................................................

.........................................................................................................................

.............................................................................................

***ពេលនេះអ្នកដឹង...***

- អល់ឡោះហ្ស៍ﷻបានចាត់បញ្ជូនព្រះសាស្តានុះហ៍ﷺ ទៅរកមនុស្សមួយក្រុមដែលគោរពបូជារូបចម្លាក់ជាព្រះ ។ អស់រយៈពេល ៩៥០ ឆ្នាំ ព្រះសាស្តានុះហ៍

عليه السلامបង្ហាត់មនុស្សឲ្យចេះគោរពបូជាអល់ឡោះហ៍ عز وجل ព្រះមួយគត់ តែមនុស្សភាគច្រើនចំអកឲ្យព្រះអង្គعليه السلام ឲ្យព្រះអង្គعليه السلامសូមឲ្យអល់ឡោះហ៍ عز وجلធ្វើទណ្ឌកម្មពួកគេ ។ ព្រះសាស្តានុះហ៍عليه السلامជាមនុស្សមានអំណត់ ព្រះអង្គعليه السلامខិតខំប្រាប់ពួកគេឲ្យភ្ញាក់ខ្លួនថាពួកគេធ្វើខុស ។

- តែមនុស្សសម័យព្រះសាស្តានុះហ៍عليه السلامចចេសរឹងរូស ពួកគេមិនខ្វល់នឹងព្រះអង្គعليه السلامទេ ។ ពេលមនុស្សវាយប្រហារព្រះអង្គعليه السلامដោយចោលព្រះអង្គعليه السلامនឹងដុំថ្ម ព្រះសាស្តានុះហ៍عليه السلامបួងសួងអល់ឡោះហ៍ عز وجل សូមឲ្យព្រះអង្គ عز وجلជួយដោះស្រាយ ។
- អល់ឡោះហ៍ عز وجلបានឮសំណូមព្រះសាស្តានុះហ៍عليه السلام ព្រះអង្គ عز وجلបញ្ជាព្រះសាស្តានុះហ៍عليه السلامឲ្យសាងសង់សំពៅធំមួយ ។ ព្រះសាស្តានុះហ៍عليه السلامបានចំណាយពេល ៨០ ឆ្នាំដើម្បីសាងសង់សំពៅ ។
- សង់សំពៅរួច អល់ឡោះហ៍ عز وجلបានបញ្ជាព្រះសាស្តានុះហ៍عليه السلامឲ្យឡើងលើសំពៅដោយនាំយកបណ្តាអ្នកតាមព្រះអង្គعليه السلام និងសត្វគ្រប់ប្រភេទមួយគូៗទៅផង ។ កូនប្រុសបីនាក់របស់ព្រះអង្គعليه السلامបានឡើងលើសំពៅដែរ តែកូនប្រុសទីបួនរបស់ព្រះអង្គعليه السلامឈ្មោះកាន់អ៊ាន់ គ្មានជំនឿ មិនព្រមទៅជាមួយគេទេ ។
- ភ្លៀងធ្លាក់ដូចបាក់មេឃ ផែនដីត្រូវទឹកលិច ។ ព្រះសាស្តានុះហ៍عليه السلامសូមឲ្យអល់ឡោះហ៍ عز وجلស្រង់កូនប្រុសព្រះអង្គعليه السلام តែអល់ឡោះហ៍ عز وجلបដិសេធ ព្រោះកាន់អ៊ាន់ អាស្រ័យលើទង្វើ មិនត្រូវទុកជាកូនពិតរបស់ព្រះអង្គعليه السلامទេ ហើយមិនសមឲ្យវារស់ទេ ។
- សំពៅអណ្តែតអស់រយៈពេលយូរ ពុំមានមនុស្សអាក្រក់នៅសេសសល់ទេ ។ ព្រះទណ្ឌកម្មអល់ឡោះហ៍ عز وجلបានសម្រេចជាស្ថាពរ ភ្លៀងឈប់ធ្លាក់ ។ ទឹកស្រកវិញយ៉ាងរហ័ស សំពៅបានទៅចតលើភ្នំយូឌី ។
- ព្រះសាស្តានុះហ៍عليه السلامនិងបណ្តាអ្នកតាមព្រះអង្គعليه السلامបានកសាងជីវិតថ្មី ក្រោមព្រះពរ អល់ឡោះហ៍ عز وجل ។

## មេរៀនទី ១៩

# ព្រះសាស្ដា ហ៊ូដ عليه السلام




ប្រជារាស្ត្រកុលសម្ព័ន្ធ (ឬប្រជាជាតិ) អ៊ាដ់ (عَادٌ) រស់នៅឯតំបន់មួយហៅ អាស្ស៊ុកហ្វ៊ុ (الأحقاف) នៅចន្លោះយេមេននិងអ៊ូម៉ាន (عُمَان)។ ប្រជារាស្ត្រនេះរស់នៅ ដោយសេចក្ដីសុខសាន្ត។ អល់ឡោះហ្វ៍ عزّ وجلّ ទ្រង់ប្រោសពួកគេដោយមេត្តាប្រណី។ ពួកគេឆ្លាត ពួកគេបានសង់ក្រុងធំៗ។ ពួកគេមានមាឧមាំនៅក្នុងកុលសម្ព័ន្ធពួកគេពុំមានជម្ងឺចម្លងទេ។ ទោះបីអល់ឡោះហ្វ៍ عزّ وجلّ បានប្រោសពួកគេដោយព្រះមេត្តាប្រណីក៏ដោយ ប្រជាជាតិអ៊ាដ់មិនជឿព្រះតែមួយគត់ទេ ពួកគេគោរពសក្ការៈរូបចម្លាក់ថ្មជាព្រះ។ រាល់ពេលអ្វីដែលល្អប្រសើរកើតមានដល់ពួកគេ ពួកគេអរគុណរូបចម្លាក់ព្រះ ពេលពួកគេជួបប្រទះបញ្ហា ពួកគេបួងសួងរូបចម្លាក់ព្រះ។

### ជ្រុងស្រាវជ្រាវសាសនា

សាសនាអ្វីដែលមានរូបបដិមាជាព្រះ? ហេតុអ្វីបានជាគោរពព្រះរូបចម្លាក់ជាទង្វើខុស?

ច្រើនឆ្នាំកន្លងមក ប្រជាជាតិអ៊ាដ់បាត់បង់ឯកភាព។ ពួកមានអំណាចជិះជាន់ពួកក្រីក្រ ទន់ខ្សោយ។ ដើម្បីបង្ហាញផ្លូវប្រជារាស្ត្រអវិជ្ជា ច្រឡោងខាមនេះ

អល់ឡោះហ្ទ័ عز وجل បានចាត់បញ្ជូនព្រះសាស្តាហ៊្វូដ عليه السلام ទៅរកពួកគេ ។

ព្រះសាស្តាហ៊្វូដ عليه السلام ជាប្រជាជាតិតែមួយរបស់ពួកអាដ់ គេគោរពព្រះអង្គ عليه السلام ព្រោះព្រះអង្គ عليه السلام មានវង្សត្រកូលថ្លៃថ្នូរនិងប្រកបដោយសីលធម៌ល្អប្រពៃ ។ ព្រះអង្គ عليه السلام ជាកូនរបស់ អាប់ឌុលឡោះហ្ទ៍ ចៅរបស់ សាំ ចៅទួតរបស់ព្រះសាស្តានុះហ្វ៍ عليه السلام ។ ព្រះសាស្តាហ៊្វូដ عليه السلام ជាមនុស្សប្រកបដោយសប្បុរសធម៌និងសម្បូរអំណត់ ។ កាលព្រះអង្គ عليه السلام បានទទួលព្រះបញ្ជាអល់ឡោះហ្ទ័ عز وجل ឲ្យផ្សាយព្រះរាជសារព្រះអង្គ عز وجل ព្រះអង្គ عليه السلام ទៅរកប្រជារាស្ត្រ ថា៖ "បងប្អូនអើយ ហេតុអ្វីបងប្អូនគោរពបូជាថ្មដែលបងប្អូនឆ្លាក់ជារូបដោយផ្ទាល់ដៃ ។ រូបព្រះមិនអាចផ្តល់អ្វីឲ្យអស់លោក មិនយកអ្វីពីអស់លោកបានសោះ ។ បងប្អូនមិនឆោតទេ តែអ្វីដែលបងប្អូនធ្វើនោះវាផ្ទុយពីប្រាជ្ញាបងប្អូន ។ បងប្អូនមានតែព្រះមួយគត់ ត្រូវតែគោរពបូជាព្រះអង្គមួយគត់ ។ ព្រះអង្គបានបង្កើតបងប្អូនមក ព្រះអង្គឲ្យបងប្អូនមានសុខភាពល្អនិងមានទ្រព្យ ព្រះអង្គបានធ្វើឲ្យបងប្អូនទៅជាប្រជាជាតិមួយដែលមានអំណាច ។ ចូរបងប្អូនកុំបះបោរប្រឆាំងអល់ឡោះហ្ទ័ عز وجل ពុំនោះទេបងប្អូននឹងជួបប្រទះជោគវាសនាដូចប្រជារាស្ត្ររបស់ព្រះសាស្តានុះហ្វ៍ عليه السلام ដែរ ។"

ព្រះសាស្តាហ៊្វូដ عليه السلام ព្យាយាមអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យមនុស្សដឹងកំហុសខ្លួន តែផ្ទុយពីស្តាប់ព្រះអង្គ عليه السلام ពួកគេចចេសរឹងរូសលើសដើម ។ ពួកគេថា៖ "ហ៊្វូដ عليه السلام អើយ លោក عليه السلام និយាយផ្តេសផ្តាស ។ ហេតុអ្វីយើងត្រូវគោរពបូជាព្រះតែមួយចោលទង្វើដូនតាយើង ?" ព្រះសាស្តាហ៊្វូដ عليه السلام បានពន្យល់ពួកគេថារូបព្រះបានតែធ្វើឲ្យពួកគេឃ្លាតកាន់តែឆ្ងាយពីអល់ឡោះហ្ទ័ عز وجل ប៉ុណ្ណោះ ថាព្រះអង្គ عليه السلام ជាព្រះសាស្តាចាត់បញ្ជូនមកដើម្បីបង្ហាញផ្លូវពួកគេ ។ ព្រះមហាគម្ពីរគួរអានថែងថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَإِلَىٰ عَادٍ أَخَاهُمۡ هُودًاۚ قَالَ يَٰقَوۡمِ ٱعۡبُدُواْ ٱللَّهَ مَا لَكُم مِّنۡ إِلَٰهٍ غَيۡرُهُۥٓۖ إِنۡ أَنتُمۡ إِلَّا مُفۡتَرُونَ ٥٠ يَٰقَوۡمِ لَآ أَسۡـَٔلُكُمۡ عَلَيۡهِ أَجۡرًاۖ إِنۡ أَجۡرِيَ إِلَّا عَلَى ٱلَّذِي فَطَرَنِيٓۚ أَفَلَا تَعۡقِلُونَ ٥١

*ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៥០. [យើងបានបញ្ជូន]ហ៊្វូដមករកប្រជាជាតិអាដ់ គេជាបងប្អូនពួកគេ ។ គេបានថ្លែង[ចំពោះពួកគេ]ថា៖ "ប្រជារាស្ត្រខ្ញុំអើយ ចូរអស់លោកធ្វើសក្ការបូជា*

*អល់ឡោះហ៍ ។ អស់លោកពុំមានព្រះទេក្រៅពីព្រះអង្គ ។ [តែពួកលោកធ្វើសក្ការបូជារូបបដិមា] អស់លោកគ្រាន់តែជាអ្នកប្រឌិត[ពាក្យកុហកភូតភរ]ប៉ុណ្ណោះ ។ ៥១. ប្រជារាស្ត្រអើយ ខ្ញុំមិនសូមប្រាក់ពីអស់លោកជាថ្លៃអ្វីទាំងនេះទេ (ដែលបានផ្សព្វផ្សាយសិក្ខាបទ និងបានហៅអស់លោកមករកអល់ឡោះហ៍) ។ រង្វាន់របស់ខ្ញុំនៅលើព្រះដែលជាអ្នកបង្កើតខ្ញុំឯនោះទេ ។ អស់លោកមិនពិចារណាទេ ?* (ស៊ូរ៉ោះតុ៏ ហ៊ូដ, ១១:៥០-៥១)

តែពាក្យពេជន៍នេះធ្វើឲ្យពួកអាុដ៉ុក្រោធ ថា៖ "ហ៊ូដﷺអើយ អ្នកមានសិទ្ធិអ្វីនិយាយបែបនេះដាក់យើង ? អ្នកបរិភោគនិងផឹកដូចយើងដែរ ។ អ្នកមិនគ្រាន់បើជាងយើងទេ ។ ហេតុអ្វីគេជ្រើសរើសអ្នកជាព្រះសាស្តា ? អ្នកជាមនុស្សកុហក ឬអ្នកត្រូវបណ្តាសាព្រះយើង ធ្វើឲ្យអ្នកឆ្កួត ។" មនុស្សចំអកឲ្យព្រះសាសាហ៊ូដﷺ ។ មានតែមនុស្សតិចតួចប៉ុណ្ណោះ ដែលស្តាប់ពាក្យពេជន៍ឥតឈប់របស់ព្រះអង្គﷺ ។ ពេលព្រះអង្គﷺព្រមានពួកអាុដ៉ុអំពីទណ្ឌកម្មអល់ឡោះហ៍ﷻ ព្រះគម្ពីរគួរអានថែងអំពីចម្លើយពួកគេថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

فَأۡتِنَا بِمَا تَعِدُنَآ إِن كُنتَ مِنَ ٱلصَّٰدِقِينَ ٧٠

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៧០. ចូរលោកនាំយកអ្វីដែលលោកបានគំរាមយើងនោះមក បើលោកជាអ្នកសច្ចៈមែន ។"* (ស៊ូរ៉ោះតុ៏ អាល់-អាក់រ៉ហ្វ, ៧:៧០)

កាលពួកអាុដ៉ុហៅរកទណ្ឌកម្មអល់ឡោះហ៍ﷻផ្ទាល់មាត់តែម្តងនោះ ភ្លៀងលែងធ្លាក់បីឆ្នាំ កើតមានការរាំងស្ងួតគួរឲ្យខ្លាច ។ ក្នុងអំឡុងពេលនោះ ព្រះសាស្តាហ៊ូដﷺប្រាប់មនុស្សឲ្យស្តាយក្រោយដែលបានប្រព្រឹត្តខុស ឲ្យពួកគេសូមខមាទោសអល់ឡោះហ៍ﷻមុនហួសពេល ។ តែពួកគេមិនចង់ឃើញការពិតទេ នៅតែបួងសួងរូបព្រះសូមឲ្យធ្លាក់ភ្លៀង ។ ទីបំផុត ព្រះសាស្តាហ៊ូដﷺលះបង់ចោលមានវចនៈថា៖ "អស់លោកធ្វើអ្វីតាមតែចិត្តចុះ ។ ខ្ញុំﷺពឹងតែលើអល់ឡោះហ៍ﷻ ព្រះអភិបាលរបស់ខ្ញុំﷺ ។"

ទីបំផុត ទណ្ឌកម្មអល់ឡោះហ៍ﷻប្រាកដឡើង ។ ពពកខ្មៅធំបានកើតមានឡើង ។ ពេលឃើញពពកខ្មៅនោះ ពួកអាដ្ធ៍គិតថានឹងភ្លាក់ភ្លៀង តែផ្ទុយពីនេះ មានខ្យល់ព្យុះគួរឲ្យខ្លាចវាយរំលំផ្ទះសម្បែងពួកគេ វាយបង្ហើរសត្វពួកគេទៅលើអាកាស ។ ផ្ទុយពីទឹកភ្លៀង មានភ្លៀងផ្គេកបន្ទោរចេញមកពីពពកខ្មៅ ។ កើតមានខ្យល់ព្យុះសាហាវនេះអស់រយៈពេលប្រាំបីថ្ងៃ ។ ពេលអស់ខ្យល់ព្យុះ ប្រជាជាតិអាដ្ធ៍ត្រូវកម្ទេចចោល ។ ព្រះគម្ពីរគួរអានថែងថា៖

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَأَمَّا عَادٌ فَأُهۡلِكُواْ بِرِيحٖ صَرۡصَرٍ عَاتِيَةٖ ۝٦ سَخَّرَهَا عَلَيۡهِمۡ سَبۡعَ لَيَالٖ وَثَمَٰنِيَةَ أَيَّامٍ حُسُومٗاۖ فَتَرَى ٱلۡقَوۡمَ فِيهَا صَرۡعَىٰ كَأَنَّهُمۡ أَعۡجَازُ نَخۡلٍ خَاوِيَةٖ ۝٧ فَهَلۡ تَرَىٰ لَهُم مِّنۢ بَاقِيَةٖ ۝٨

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៦. រីឯពួកអាដ្ធ៍ត្រូវប្រល័យដោយវាតគុលស្វោរស្វារ (គឺខ្យល់កំបុតត្បូង) ៧. ដែលព្រះអង្គបានបញ្ជូនទៅបំផ្លិចបំផ្លាញពួកគេ អស់រយៈពេលប្រាំពីរយប់និងប្រាំបីថ្ងៃឥតឈប់ ។ អ្នកអាចឃើញពួកគេដេកស្លាប់លើដីដូចដើមលម៉ើប្រហោងក្នុង ។ ៨. តើអ្នកឃើញពួកគេនៅសេសសល់ម្នាក់ទេ ?* (ស៊ូរ៉ោះត៍ អាល់-ហាក់កោះត៍, ៦៩:៦-៨) ។

ពេលចាប់ផ្ដើមមានខ្យល់កួច ព្រះសាស្ដាហ៊ូដ្ធ៍ﷺបានប្រមូលគ្រួសារព្រះអង្គﷺនិងបណ្ដាអ្នកតាមព្រះអង្គﷺទៅជ្រកនៅឯកន្លែងផុតភ័យ ។ នៅសល់តែពួកគេទាំងអស់នេះទេពីទណ្ឌកម្មអល់ឡោះហ៍ﷻ ។ ពេលអស់ខ្យល់ព្យុះ ព្រះសាស្ដាហ៊ូដ្ធ៍ﷺបាននាំបក្សពួកព្រះអង្គﷺទៅកាន់កន្លែងមួយហៅថា ហាដ្ធ៍រ៉ម៉ៅត៍ (حَضْرَمَوْتُ) រស់នៅទីនោះមួយជីវិត ។

### *ពេលនេះអ្នកដឹង...*

- ប្រជាជាតិអាដ្ធ៍រស់នៅសុខសាន្តអាស្រ័យព្រះពរអល់ឡោះហ៍ﷻ ។ ពួកគេមានមាឌមាំ ពុំមានជម្ងឺរាតត្បាតទេ ។ តែពួកគេមិនជឿព្រះតែមួយទេ ពួកគេគោរព

ព្រះរូបចម្លាក់ ។

- ច្រើនឆ្នាំកន្លងមក ប្រជាជាតិអាដ់បាត់បង់ឯកភាព ។ អល់ឡោះហ្ញ៉ عز وجل បានបញ្ជូនព្រះសាស្តាហ៊ូដ ﷺ ទៅដឹកនាំពួកគេ ។ ព្រះអង្គ ﷺ ជាប្រជាជាតិអាដ់ដែរ គេគោរពព្រះអង្គ ﷺ ព្រោះព្រះអង្គ ﷺ មានវង្សត្រកូលថ្លៃថ្នូរ និងមានសីលធម៌ល្អប្រពៃ ។ ព្រះអង្គ ﷺ ណែនាំពួកគេឲ្យគោរពបូជាអល់ឡោះហ្ញ៉ عز وجل ឈប់គោរពព្រះរូបចម្លាក់ ។
- ព្រះសាស្តាហ៊ូដ ﷺ ពុះពារការលំបាកច្រើន ដើម្បីទាក់ទាញប្រជារាស្ត្រព្រះអង្គ ﷺ តែពួកគេមិនព្រមស្តាប់ព្រះអង្គ ﷺ ទេដោយអះអាងថាដូនតាពួកគេធ្វើបែបនេះដែរ ។ ពួកគេចំអកឲ្យព្រះអង្គ ﷺ ថាព្រះអង្គ ﷺ និយាយកុហក ។ មានអ្នកតាមព្រះអង្គ ﷺ តែបន្តិចបន្តួចប៉ុណ្ណោះ ។
- ពេលព្រះសាស្តាហ៊ូដ ﷺ ប្រាប់ពួកគេ ថាអល់ឡោះហ្ញ៉ عز وجل នឹងធ្វើទណ្ឌកម្មពួកគេ ពួកគេហៅរកទណ្ឌកម្មអល់ឡោះហ្ញ៉ عز وجل យ៉ាងក្រអឺត ។ ហេតុដូច្នេះ កើតមានការរីងរាំងអស់បីឆ្នាំ ។
- ពួកអាដ់មិនព្រមមើលការពិតទេ នៅតែបួងសួងព្រះរូបចម្លាក់ ។ ព្រះសាស្តាហ៊ូដ ﷺ ប្រាប់ពួកគេឲ្យពួកគេស្តាយក្រោយដែលបានធ្វើខុស តែពួកគេមិនស្តាប់ព្រះអង្គ ﷺ ទេ ។ ព្រះសាស្តាហ៊ូដ ﷺ ក៏បានឈប់រវល់នឹងពួកគេទៀត ។
- ទណ្ឌកម្មអល់ឡោះហ្ញ៉ عز وجل បានមកដល់ ។ ពពកខ្មៅបានលេចឡើង ។ កើតមានខ្យល់គួរឲ្យខ្លាចដែលវាយរំលំសព្វសារពើ ។ ផ្លេកបន្ទោរបាញ់ចេញពីពពកខ្មៅមានខ្យល់ព្យុះអស់រយៈពេល ៨ ថ្ងៃ ។
- មុនខ្យល់ព្យុះ ព្រះសាស្តាហ៊ូដ ﷺ បានប្រមូលបក្សពួកព្រះអង្គ ﷺ ទៅកាន់កន្លែងមានសុវត្ថិភាព ។ មានតែពួកគេទេដែលរួចជីវិតពីទណ្ឌកម្មអល់ឡោះហ្ញ៉ عز وجل ។

## មេរៀនទី ២០

# ព្រះសាស្តា ស្វ៍លិះហ៍عليه السلام

ទឹកដីរបស់ព្រះជាជាតិអាដ់ត្រូវប្រជាជាតិស្វាមូដ្ទយក ។ ពួកគេធ្វើការផឹតនឿយហត់ ពួកគេបានសាងសង់សួនច្បារដំណាំនិងឧទ្យានដ៏ច្រើននិងសំណង់ឆើតឆាយ ។ ដើម្បីការពារខ្លួន ពួកគេសង់ផ្ទះនៅក្នុងភ្នំ ។ ពួកគេរស់នៅក្នុងភាពសម្បូរនិងសេចក្តីសប្បាយ ។ តែពួកគេមិនដឹងព្រះគុណអល់ឡោះហ្វ៍عز وجلទេដែលបានប្រទានអំណោយទាំងនេះឲ្យពួកគេ ពួកគេសរសើរខ្លួនឯង ។ ពួកគេគិតថាជីវិតសុខសាន្តរបស់ពួកគេនេះជាលទ្ធផលនៃកម្លាំងពួកគេ ។ ពួកគេគួរតែបែរទៅរកអល់ឡោះហ្វ៍عز وجل ផ្ទុយទៅវិញ ពួកគេបែរទៅរកភ្នំ ពួកគេគោរពសក្ការៈភ្នំដោយបូជាតង្វាយ ។ អល់ឡោះហ្វ៍عز وجلបានចាត់បញ្ជូនព្រះសាស្តាស្វ៍លិះហ៍عليه السلامទៅរកប្រជាជាតិស្វាមូដ្ទដើម្បីដឹកនាំពួកគេមករកផ្លូវត្រូវវិញ ។ ព្រះសាស្តាស្វ៍លិះហ៍عليه السلامជាប្រជាជាតិស្វាមូដ្ទដូចពួកគេដែរ គេគោរពព្រះអង្គعليه السلامព្រោះព្រះអង្គعليه السلامប្រកបដោយសប្បុរសធម៌និងប្រាជ្ញាញាណ តាំងពីនៅក្មេងវ័យម្ល៉េះ ។

**ជ្រុងពិចារណា**

ហេតុអ្វីបានជា សំខាន់បំផុត ព្រះសាស្តាស្វ៍លិះហ៍عليه السلامជាប្រជាជាតិស្វាមូដ្ទដូចពួកស្វាមូដ្ទដែរ ?

..............................................................................................................

..............................................................................................................

..........................................................................................

ព្រះសាស្តាស្វ៍លិះហ៍عليه السلام សូមឲ្យមនុស្សគោរពបូជាតែអល់ឡោះហ្វ៍عز وجلមួយ

គត់ដែលជាព្រះអ្នកបង្កើតពួកគេ ។ ព្រះអង្គﷷព្យាយាមពន្យល់ពួកគេថាធ្វើសក្ការៈភ្នំនោះពុំមានប្រយោជន៍ទេ វាមិនអាចធ្វើអាក្រក់និងធ្វើល្អចំពោះអ្នកណាមួយបានទេ ។ ព្រះអង្គﷷបានរំលឹកពួកគេថាព្រះអង្គﷷនិងពួកគេជាប្រជាជាតិតែមួយ ថាព្រះអង្គﷷចង់ឲ្យពួកគេល្អ ព្រះអង្គﷷមានវចនៈថា៖ "អស់លោកជាបងប្អូនខ្ញុំﷷ ។ ខ្ញុំﷷមិននិយាយអ្វីដែលអាចធ្វើឲ្យអស់លោកឈឺចាប់ទេ ។ ចូរបងប្អូនមកសូមខមាទោសអល់ឡោះហ្ទ៍ﷻ ព្រះអង្គﷻព្ទការបួងសួងរបស់បងប្អូន ព្រះអង្គﷷនឹងបំពេញបំណងបងប្អូន ។" តែពួកស្មាមូដូធ្វើមិនឮ ។ ពួកគេថា៖ "ស្វ៍លិះហ៊ុ៍ﷷអើយ យើងគិតថាអ្នកﷷជាមនុស្សដែលចេះយោគយល់ ។ យើងឃើញថាអ្នកﷷចិត្តល្អនិងមានការចេះដឹង យើងចង់បានអ្នកﷷជាទីប្រឹក្សាក្នុងគ្រាលំបាក ។ ហេតុអ្វីអ្នកﷷនិយាយផ្តេសផ្តាស ? អ្នកﷷចង់ឲ្យយើងឈប់ធ្វើសក្ការៈអ្វីដែលដូនតាយើងធ្លាប់តែធ្វើសក្ការៈឬ ? យើងមិនស្តាប់អ្នកﷷជាដាច់ខាត ។"

ព្រះសាស្តាស្វ៍លិះហ៊ុ៍ﷷព្យាយាមអត់ធ្មត់ប្រាប់ការពិតពួកគេ ។ ព្រះអង្គﷷបញ្ជាក់ថាព្រះអង្គﷷចង់ណែនាំពួកគេដើម្បីនឹងចង់ឲ្យពួកគេល្អទេ មិនចង់បានអ្វីពីពួកគេទេ ។ ព្រះអង្គﷷមានវចនៈថារង្វាន់របស់ព្រះអង្គﷷមកពីអល់ឡោះហ្ទ៍ﷻ ។ ព្រះអង្គﷷបានរំលឹកពួកគេអំពីព្រះអំណោយទាំងអស់ ដែលអល់ឡោះហ្ទ៍ﷻបានប្រទានឲ្យពួកគេ ។ ព្រះអង្គﷷបានប្រាប់ពួកគេឲ្យប្រយ័តទណ្ឌកម្មអល់ឡោះហ្ទ៍ﷻ បើពួកគេនៅតែធ្វើបែបនេះទៀត ។

កាលព្រះសាស្តាស្វ៍លិះហ៊ុ៍ﷷបានចាប់ផ្តើមបំពេញបេសកកម្ម ព្រះអង្គﷷមានព្រះជន្ម ១៦ ឆ្នាំ ។ ទោះបីព្រះអង្គﷷបានបន្តបេសកកម្មរហូតដល់អាយុ ១២០ ឆ្នាំក៏ដោយ មានតែមនុស្សមួយភាគដ៏តូចទេដែលជឿព្រះអង្គﷷ ។ ភាគច្រើនជេរប្រមាថព្រះអង្គﷷ ចោទព្រះអង្គﷷថានិយាយកុហក ថាព្រះអង្គﷷឆ្កួត ។ ព្រះសាស្តាស្វ៍លិះហ៊ុ៍ﷷឆ្លើយតបពួកគេថា៖ "ប្រជារាស្ត្រអើយ ខ្ញុំﷷមិនកុហកទេ ។ ខ្ញុំﷷមានអំណះអំណាងមាំមកពីអល់ឡោះហ្ទ៍ﷻដែលបញ្ជាក់ថាខ្ញុំﷷជាព្រះសាស្តា ។" អាជ្ញាធរស្មាមូដូមិនស្តាប់ព្រះសាស្តាស្វ៍លិះហ៊ុ៍ﷷទេ ខ្លាចព្រះអង្គﷷក្លាយទៅជាមានឥទ្ធិពល ខ្លាចខ្លួនឯងបាត់បង់ឋានៈជាអ្នកដឹកនាំសហគមន៍ ។ ពួកគេបានសម្រេចចិត្តប្រាប់មហាជនឲ្យដឹងចំណុចខ្សោយរបស់ព្រះ



សាស្តាស្វ៍លិះហ៊ ﷺ ។ ដូច្នេះ ពួកគេដាក់វិញ្ញាសាព្រះអង្គ ﷺ ធ្វើឲ្យមេអូដ្ឋចេញមកពីក្នុងថ្មភ្នំដែលពួកគេធ្វើសក្ការៈនោះ ដើម្បីជាភ័ស្តុតាងសម្ដីព្រះអង្គ ﷺ ។ ដោយសារអល់ឡោះហ្ ﷻ អនុញ្ញាតព្រះសាស្តាស្វ៍លិះហ៊ ﷺ បានបំពេញអព្ភូតហេតុអស្ចារ្យនេះ ។ មនុស្សមិនដែលឃើញមេអូដ្ឋណាដូចមេអូដ្ឋនេះទេមួយជីវិតពួកគេ ។ មេអូដ្ឋផឹកទឹកស្រុកនេះទាំងអស់មួយថ្ងៃ ថ្ងៃបន្ទាប់វាទុកទឹកឲ្យពួកអ្នកស្រុកផឹក ។ ថ្ងៃដែលវាផឹកទឹកទាំងអស់ វាផ្ដល់ទឹកដោះឲ្យពួកអ្នកស្រុកបានតាមចិត្ត ។ ព្រះគម្ពីរគួរអានចែងថាៈ

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَإِلَىٰ ثَمُودَ أَخَاهُمۡ صَٰلِحٗاۚ قَالَ يَٰقَوۡمِ ٱعۡبُدُواْ ٱللَّهَ مَا لَكُم مِّنۡ إِلَٰهٍ غَيۡرُهُۥۖ قَدۡ جَآءَتۡكُم بَيِّنَةٞ مِّن رَّبِّكُمۡۖ هَٰذِهِۦ
نَاقَةُ ٱللَّهِ لَكُمۡ ءَايَةٗۖ فَذَرُوهَا تَأۡكُلۡ فِيٓ أَرۡضِ ٱللَّهِۖ وَلَا تَمَسُّوهَا بِسُوٓءٖ فَيَأۡخُذَكُمۡ عَذَابٌ أَلِيمٞ ٧٣

*ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*៧៣. [យើងបានបញ្ជូន]ស្វ៍លិះហ៊មករកប្រជាជាតិស្សាមូដ្ឋ គេជាបងប្អូនពួកគេ ។ គេបានថ្លែងថាៈ "ប្រជារាស្ត្រអើយ ចូរអស់លោកគោរពបូជាអល់ឡោះហ្ ពុំមានព្រះផ្សេងពីព្រះអង្គទេសម្រាប់អស់លោក ។ ភ័ស្តុតាងមួយបានមកដល់អស់លោកពីព្រះម្ចាស់របស់អស់លោក ។ នេះគឺអូដ្ឋញីរបស់អល់ឡោះហ្សម្រាប់អស់លោកជាសញ្ញា [ជាមធ្យោបាយសម្រាប់ពិសោធ] ។ ចូរអស់លោកបណ្ដោយឲ្យវាស៊ីស្មៅនៅលើដីរបស់អល់ឡោះហ្ ហើយកុំធ្វើបាបវា ពុំនោះទេអស់លោក នឹងរងទណ្ឌកម្មដ៏ឈឺចាប់ ។* (ស៊ូរ៉ោះត្ុ៏ អាល់-អាក់រ៉ប្ហ៍, ៧:៧៣)

ហេតុការណ៍អស្ចារ្យនេះធ្វើឲ្យអ្នកស្រុកជឿសម្ដីព្រះសាស្តាស្វ៍លិះហ៊ ﷺ បែរមកកាន់សាសនាព្រះអង្គ ﷺ ។ រឿងនេះធ្វើឲ្យអាជ្ញាធរបារម្ភ ពីព្រោះពួកគេដឹងដែរថាដរាបណាមនុស្សនៅតែឃើញមេអូដ្ឋ ដរាបនោះពួកគេស្ដាប់ព្រះសាស្តាស្វ៍លិះហ៊ ﷺ ។ អាជ្ញាធរសាហាវបានសម្រេចចិត្តសម្លាប់មេអូដ្ឋ ទោះបីព្រះសាស្តាស្វ៍លិះហ៊ ﷺ បានប្រាប់ពួកគេហើយក៏ដោយថា ទណ្ឌកម្មអល់ឡោះហ្ ﷻ នឹងបាក់ស្រោចមកលើពួកគេបើមេអូដ្ឋរងរបួស ។ បុរសអាក្រក់ពីរបីនាក់បានព័ទ្ធចាប់មេអូដ្ឋ ពេលវា

ត្រឡប់ទៅផឹកទឹក ។ បុរសម្នាក់បាញ់ជើងមេអូដ្ឋមួយគ្រាប់ព្រួញ បាញ់ជើងក្រោយមួយគ្រាប់ទៀតដាច់សរសៃ មេអូដ្ឋដួល ។ បន្ទាប់មក បុរសម្នាក់ទៀតឈ្មោះ ក៏ដ្ឋារ បានកាត់កមេអូដ្ឋស្លាប់ ។ រួចហើយអាជ្ញាធរបានទៅជួបព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلام ប្រកាសយ៉ាងក្រអឺតថា៖ "ស្វ៍លិះហ៊ុ៍عليه السلامអើយ ចូរដាក់ទណ្ឌកម្មយើងមកបើអ្នកعليه السلام ជាព្រះសាស្តាមែននោះ ។" ព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلامបានប្រាប់ថាពួកគេបានសាងបាបធំមួយ ហើយព្រះអង្គعليه السلامឲ្យពួកគេត្រឡប់ទៅលំនៅវិញ កុំចេញពីក្នុងផ្ទះបីថ្ងៃ ដើម្បីសូមទោសអល់ឡោះហ្ទ៍عزوجل ។ តែពួកគេចំអកដាក់ព្រះអង្គعليه السلام ។ បីថ្ងៃក្រោយមក ព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلامបានទទួលព្រះបញ្ជាពីអល់ឡោះហ្ទ៍عزوجلឲ្យចាកចេញពីតំបន់ដោយនាំបណ្តាអ្នកតាមព្រះអង្គعليه السلامទៅផង ។ បន្ទាប់មក ទណ្ឌកម្មអល់ឡោះហ្ទ៍عزوجلធ្លាក់មកលើពួកស្ហាមូដ្ទ ។ រន្ទះបានផ្ទុះឡើងនៅលើមេឃ ផ្ទៃដីបុរីក៏បានរញ្ជួយ បំផ្លិចបំផ្លាញផ្ទះសម្បែងនិងសំណង់ធំៗទាំងអស់ ។ មនុស្សដួលស្លាប់ភ្លើងមកពីលើមេឃដុតកម្ទេចសាកសពពួកគេសល់តែផេះ ។ ពុំមានអ្នកណាមួយក្នុងតំបន់នេះរួចជីវិតទេក្នុងថ្ងៃដ៏រន្ធត់នោះ ។ ពេលព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلامបានឃើញអវសានខ្លោចផ្សារបស់ប្រជាជាតិព្រះអង្គعليه السلام ព្រះអង្គعليه السلامបានប្រាប់បណ្តាសាកសពដែលសេសសល់នៅជុំវិញព្រះអង្គعليه السلامថា៖ "ប្រជារាស្ត្រអើយ ខ្ញុំعليه السلامបានប្រាប់អស់លោកឲ្យដឹងព្រះរាជសាររអល់ឡោះហ្ទ៍عزوجلហើយ ហើយបានដឹកនាំអស់លោកនៅលើផ្លូវត្រូវ តែអស់លោកគិតថាខ្ញុំعليه السلامជាសត្រូវរបស់អស់លោក ។"

ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "បុគ្គលអាក្រក់បំផុតសម័យមុនៗគឺបុគ្គលដែលបានសម្លាប់មេអូដ្ឋឥតកំហុសរបស់ព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلام បុគ្គលអាក្រក់បំផុតសម័យនេះគឺបុគ្គលដែលនឹងសម្លាប់អ៊ីមុាំអាលីصلوات الله عليه والسلام ។"

## ផ្ទុងលំហាត់

ចូរស្រង់មេរៀនដែលអ្នកបានសិក្សាចេះដឹងពីប្រវត្តិព្រះសាស្តាស្វ៍លិះហ៊ុ៍عليه السلام និងប្រជារាស្ត្រស្ហាមូដ្ទ ។

................................................................................................

................................................................................................

..........................................................................................................

***ពេលនេះអ្នកដឹង...***

- ប្រជាជាតិស្សាមូដ្ឋរស់នៅក្នុងភាពសម្បូរនិងសេចក្តីសប្បាយ ។ ពួកគេបានសាងសង់សំណង់ឆើតឆាយ សួនច្បារដំណាំនិងឧទ្យាន ។ ពួកគេមិនបែរទៅរកអល់ឡោះហ៊្វ عز وجل ទេដើម្បីអរព្រះគុណព្រះអង្គ عز وجل តែពួកគេធ្វើសក្ការៈភ្នំដោយយកតង្វាយទៅថ្វាយភ្នំនោះ ។
- ព្រះសាស្តាស្វ៏លិះហ៊ عليه السلام ត្រូវចាត់បញ្ជូន ទៅណែនាំប្រជាជាតិស្សាមូដ្ឋលើផ្លូវត្រូវ ។ គេគោរពព្រះអង្គ عليه السلام ព្រោះព្រះអង្គ عليه السلام មានចិត្តសប្បុរសនិងមានប្រាជ្ញាញាណ ។
- ព្រះអង្គ عليه السلام បានបង្ហាត់មនុស្សឲ្យចេះធ្វើសក្ការៈអល់ឡោះហ៊្វ عز وجل ដោយពន្យល់ថាភ្នំមិនអាចធ្វើអាក្រក់និងធ្វើល្អចំពោះអ្នកណាមួយបានឡើយ ។ តែប្រជាជាតិស្សាមូដ្ឋមិនស្តាប់ទេ ។ ព្រះអង្គ عليه السلام បានរំលឹកពួកគេអំពីព្រះអំណោយដ៏ច្រើនដែលអល់ឡោះហ៊្វ عز وجل បានប្រទានឲ្យពួកគេ ។ ព្រះអង្គ عليه السلام បានព្រមានពួកគេអំពីទណ្ឌកម្មអល់ឡោះហ៊្វ عز وجل បើពួកគេនៅតែធ្វើទង្វើនេះ ។
- ព្រះអង្គ عليه السلام បានឃោសនាសាសនាតាំងពីព្រះអង្គ عليه السلام មានព្រះជន្ម ១៦ ឆ្នាំ រហូតដល់មានព្រះជន្ម ១២០ ឆ្នាំ ។ ក្នុងអំឡុងពេលនេះមានតែមនុស្សមួយភាគដ៏តូចប៉ុណ្ណោះដែលស្តាប់ព្រះអង្គ عليه السلام ។
- ថ្ងៃមួយ អាជ្ញាធរស្សាមូដ្ឋបានឲ្យព្រះសាស្តាស្វ៏លិះហ៊ عليه السلام បង្ហាញភ័ស្តុតាងសម្តីព្រះអង្គ عليه السلام ដោយបំពេញអព្ភូតហេតុអស្ចារ្យមួយ គឺធ្វើឲ្យមេអូដ្ឋចេញមកពីជញ្ជាំងភ្នំដែលពួកគេធ្វើសក្ការៈនោះ ។ ហេតុការណ៍អស្ចារ្យក៏បានកើតឡើងដោយការអនុញ្ញាតរបស់អល់ឡោះហ៊្វ عز وجل ។ ពួកស្សាមូដ្ឋភាគច្រើនស្រឡាំងកាំងព្រោះមេអូដ្ឋផឹកទឹកទាំងអស់របស់អ្នកស្រុកពួកគេ ហើយអាចផ្តល់ទឹកដោះឲ្យពួកគេបានតាមចិត្ត ។ ហេតុការណ៍អស្ចារ្យនេះធ្វើឲ្យមនុស្សជឿអល់ឡោះហ៊្វ عز وجل ។
- ពួកមេដឹកនាំបារម្ភ ខ្លាចមនុស្សបែរទៅរកព្រះសាស្តាស្វ៏លិះហ៊ عليه السلام ដូច្នេះពួកគេបានសម្រេចចិត្តសម្លាប់មេអូដ្ឋ ។ ពួកគេបាញ់ជើងមេអូដ្ឋដោយគ្រាប់ព្រួញ កាត់

ផ្កាច់សរសៃជើងក្រោយ ហើយក៏បានសម្លាប់មេអូដ្ឋនោះដោយកាប់កវានឹងដាវ ។

- ព្រះសាស្ដាស្វ៏លិះហ៊ ﷺ បានប្រាប់ថាពួកគេបានប្រព្រឹត្តបាបធំ ថាពួកគេនឹងត្រូវផ្ដន្ទាទោសបើពួកគេមិនសូមទោសអល់ឡោះហ្ ﷻ ទេ ។
- គេចំអកឲ្យព្រះអង្គ ﷺ ។ បីថ្ងៃក្រោយមក ព្រះសាស្ដាស្វ៏លិះហ៊ ﷺ បាននាំបណ្ដាអ្នកតាមព្រះអង្គ ﷺ ចេញពីក្នុងស្រុក ។ អល់ឡោះហ្ ﷻ បានទម្លាក់ទណ្ឌកម្មព្រះអង្គ ﷻ មកលើប្រជាជាតិស្សាមូដ្ឋ ។ រន្ទះបាញ់មកពីលើមេឃ ដីស្រុកនោះរញ្ជួយ ។ ពុំមានអ្នកណាមួយរស់ទេ ព្រោះភ្លើងមកពីលើមេឃបានដុតសាកសពសល់តែផេះ ។

# លំហាត់មេរៀនសាឡើងវិញ ៦

## ខណ្ឌ ក

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើព្រះសាស្តាអ៊ីដ្ទរីស عليه السلام និងព្រះសាស្តាអាដាំ عليه السلام មានទំនាក់ទំនងអ្វីនឹងគ្នា ?

២. តើស្តេចសម័យព្រះសាស្តាអ៊ីដ្ទរីស عليه السلام បានសួនច្បារបស់បុរសមានជំនឿដោយវិធីណា ?

៣. អល់ឡោះហ្ទ៍ عز وجل បានឲ្យព្រះសាស្តាអ៊ីដ្ទរីស عليه السلام ទៅជួបស្តេច ។ តើព្រះអង្គ عليه السلام ប្រាប់អ្វីស្តេចនោះ ?

៤. ហេតុអ្វីព្រះសាស្តាអ៊ីដ្ទរីស عليه السلام ត្រឡប់ទៅកាន់ស្រុកដដែលវិញ ២០ ឆ្នាំក្រោយមក ?

៥. ទីបំផុត អ្វីកើតឡើងចំពោះព្រះសាស្តាអ៊ីដ្ទរីស عليه السلام ?

## ខណ្ឌ ខ

ចូរឆ្លើយសំណួរតទៅគឺៈ

១. មនុស្សសម័យព្រះសាស្តានុះហ្ទ៍ عليه السلام ថាអ្វីដាក់ព្រះអង្គ عليه السلام ?

២. ព្រះសាស្តានុះហ្ទ៍ عليه السلام បានឃោសនាសាសនាអស់រយៈពេលប៉ុន្មានឆ្នាំ ?

៣. អល់ឡោះហ្ទ៍ عز وجل បានឲ្យចម្លើយអ្វីមកព្រះសាស្តានុះហ្ទ៍ عليه السلام កាលព្រះអង្គ عليه السلام បួងសួងអល់ឡោះហ្ទ៍ عز وجل ?

៤. តើអល់ឡោះហ្ទ៍ عز وجل បានស្រង់គ្រួសាររបស់ព្រះសាស្តានុះហ្ទ៍ عليه السلام ទាំងអស់គ្នាទេ ?

៥. តើសំពៅទៅចតនៅឯណា ? តើព្រះសាស្តាស្វ៏លិះហ្ទ៍ عليه السلام ត្រូវចាត់បញ្ជូនទៅរកប្រជាជាតិណា ? តើប្រជាជាតិនេះរស់នៅឯតំបន់ណា ?

## ខណ្ឌ គ

ចូរឆ្លើយសំណួរតទៅគឺៈ

១. តើអល់ឡោះហ្ទ៍ عز وجل បានប្រោសប្រណីពួកអាដ្ទ៍ដោយប្រទានអ្វីខ្លះឲ្យពួកគេ ?

២. តើព្រះសាស្តាហ៊្ហូដជាប្រជាជាតិអ្វី តើព្រះអង្គﷺនិងព្រះសាស្តានុះហ៍មានទំនាក់ទំនងអ្វីនឹងគ្នា ?
៣. ទណ្ឌកម្មដំបូងដែលអល់ឡោះហ្ជ៍បានដាក់មកលើប្រជាជាតិអាទ្ជ៍នោះ គឺទណ្ឌកម្មអ្វី ?
៤. ទណ្ឌកម្មបន្ទាប់ដែលអល់ឡោះហ្ជ៍បានដាក់មកលើប្រជាជាតិអាទ្ជ៍នោះ គឺទណ្ឌកម្មអ្វី តើទណ្ឌកម្មនោះបានប្រព្រឹត្តទៅអស់រយៈពេលយូរប៉ុណ្ណា ?
៥. តើព្រះសាស្តាហ៊្ហូដﷺបានធ្វើអ្វីពេលអល់ឡោះហ្ជ៍ដាក់ទណ្ឌកម្ម ?

## ខណ្ឌ ឃ

ចូរឆ្លើយសំណួរតទៅគឺះ
១. តើអល់ឡោះហ្ជ៍បានប្រោសប្រណីពួកស្សាមូដដោយប្រទានអ្វីខ្លះឲ្យពួកគេ ?
២. ពួកមេដឹកនាំប្រជាជាតិរបស់ព្រះសាស្តាស្វ៊លិះហ៍ﷺ ចង់បង្រ្កាបព្រះអង្គﷺដោយវិធីណា ?
៣. តើមេអូដ្ឋមានលក្ខណៈពិសេសអ្វី ?
៤. អ្វីកើតឡើងចំពោះមេអូដ្ឋ ?
៥. អ្វីកើតឡើងចំពោះបណ្តាអ្នកដែលមិនស្តាប់ព្រះសាស្តាស្វ៊លិះហ៍ﷺ ?

*sources:*
www.saba-igc.org
shia974.fr